សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា
KhmerPost USA
E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

Free

មាតិការរឿង Issue 178 from June 15th. to 29th. 2015

១-គោលដៅលំហែកាយថ្មី..........................០២
២-សិក្ខាសាលាគណបក្សសង្គ្រោះជាតិ...............០៣
៣-លោក វាសនា នួន ឈរឈ្មោះជាក្រុមប្រឹក្សា....០៤
៤-ទូកងខ្មែរជាសម្រាមនៅវត្តត្រៃរតនារាម...........០៥
៥-ព័ត៌មានសំខាន់អន្តរជាតិ.............................០៦
៦-ចាប់ផ្ដើមកម្មវិធីរដូវក្ដៅនៅក្រុងឡូវែល..............០៨
៧-ក្បួនដំណើរនៅឡូវែល.................................១១
៨-រុក្ខជាតិពិសិដ្ឋ : ដើមពុកមាត់ឆ្មារ.....................២២

**Office:** Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A Lowell, MA 01852

ទស្សនអ្នកអាន

# កសាងជំនឿឡើងវិញ

**ដោយ វិបុល ទូច និង សុផល សម**

កំណត់និពន្ធខ្មែរផុស: វិបុល ទូច នឹង សុផល សម ជាមនុស្សនៅក្នុងចំណោមអ្នកដែលបាត់បង់ជំនឿលើគណបក្សសង្គ្រោះជាតិដ៏ច្រើន បន្ទាប់ពីឃើញសមាជិកជាន់ខ្ពស់របស់ខ្លួនចូលសភាបញ្ឈប់ការប្រឈមមុខនឹងរដ្ឋាភិបាលដោយបាតុកម្ម ឬដោយការបន្ទោសដោយចំពោះពីចម្ងាយមិនតែប៉ុណ្ណោះថែមទាំងសហាគារជាមួយគណបក្សប្រជាជនដែលជាគូប្រឆាំងសំខាន់បំផុតរបស់គណបក្សសង្គ្រោះជាតិដោយយក"ទស្សនៈវប្បធម៌សន្ទនា" មកលាក់បំបាំងសហការដ៏មានអាថិកំបាំងទៀតផង។ ជាមួយនឹងទស្សនៈខ្លួនម្ចាស់អត្ថបទនៅមានសំណើរឱ្យមានការកែប្រែនយោបាយផ្ទៃក្នុងប្រកបដោយក្ដីសង្ឃឹមថា **តទៅទំព័រទី ១០**

## CheaSim, Long-Serving CPP President, Dead at 82 CPP President CheaSim Dead

**By Saing Soenthrith | June 8, 2015**

CheaSim, the long-serving president of the ruling CPP and president of the Senate, whose health had been in decline for more than a decade, died on Monday. He was 82.

CheaSim, who along with Prime Minister Hun Sen and National Assembly President HengSamrin had been a figurehead of the ruling party since the fall of the Khmer Rouge in 1979, died at his home on Monday afternoon, according to YimLeang, the head of his bodyguard unit.

"SamdechCheaSim died at 3:45 p.m. at his home," Mr. Leang said. **Continued to Page 16**

# លោក ជា ស៊ីម ប្រធានគណបក្សប្រជាជនកម្ពុជាទទួលមរណភាព

ដោយ សាំង សុឥន្ទរិទ្ធ និង អេឡិក វិល្លឹមមីនស៍ | June 10, 2015

លោក ជា ស៊ីម ឥស្សរជនលេចធ្លោនៅក្នុងរបបកុម្មុយនិស្ត **តទៅទំព័រទី ១៦**






REMEDIUM PHARMACY
ឱសថស្ថានរ៉េមីឌៀម
2 Vinal Square. North Chelmsford, MA 01863
ជាឱសថស្ថានបំរើការគ្រប់យ៉ាងដល់អ្នក
• ផ្ទេរឬផ្លាស់ប្ដូរសេវាកម្ម • ការវេចខ្ចប់ឱសថ
• ការលាយផ្សំឱសថ • បញ្ជូនឱសថដល់ផ្ទះដោយឥតគិតថ្លៃ
• ជួយធ្វើសំបុត្រទិញថ្នាំ • ផ្លាស់ប្ដូរយោបល់ដោយរាក់ទាក់
ឱសថស្ថានយើងខ្ញុំនិយាយភាសាខ្មែរ
FREE daily delivery | Bliterpack Packaging | Compounding Medication
Friendly consultations | Easy Transfers
Tel: 978-251-7070 | Fax: 978-251-7071



# គោលដៅលំហែរកាយថ្មី នៃឆ្នេរសមុទ្រមើរធីល(ភាគ២)

## Destination Myrtle Beach in South Carolina (Part 2)



**តពីលេខមុន**

ទៅ! នៅសណ្ឋាគារនោះ មានកន្លែងឱ្យក្មេងនឹងចាស់លេងទឹកបំបាត់អផ្សុកបានពេញមួយថ្ងៃ មិនមានធុញទ្រាន់ឡើយ។ ប៉ុណ្ណារ៉ូ មិនឈប់ទារទៅលេងទឹកដ៏គួរឱ្យសប្បាយនោះទេ ពេលព្រឹកគេទារទៅលេងឆ្នេរមាត់សមុទ្រថៃយ៉ាងស្អាតប្រកបដោយខ្សាច់លាតសន្ធឹងប្របសមុទ្រទឹកក្តៅអ៊ុនៗ ពេលរសៀល គេទារទៅលេងទឹកទីអាងទឹកកំសាន្តក្នុងសណ្ឋាគារ ដែលគេអាចរត់លេងពីព្រឹកទល់ល្ងាចមិនព្រមហត់បន្តិចសោះ នៅពេលល្ងាច គេទារទៅលេង"គ្លេម"ធ្វើឱ្យម៉ែឪអ្នកដេញតាមនោះវង្វេងរកពេលសម្រាកតែបន្តិចក៏មិនបានតែដោយសារនិស្ស័យ ឪម៉ែ នឹងកូនខឹងផងស្រឡាញ់ផង បំពេញចិត្តកូនបាន៨០ភាគរយដែរ។





រាត្រីទី៣ បន្ទាប់ពីយើងមកដល់"មើធីលប៊ីច" (Myrtle Beach) ម៉ូតូធុន "ហាកឡីដាវីដសុន"បើករោទិ៍ពេញថ្នល់នៅឡើយដើម្បីកំដរថ្ងៃបុណ្យ"ម៉េម៉ូរលដេយ Memorial Day" យើងចេញពីសណ្ឋាគារ"អូស៊ានរីហ្វ" (Ocean Reef) សំដៅទៅភោជនីយដ្ឋានដ៏អស្ចារ្យមួយស្ថិតនៅខាងជើងក្រុងមានឈ្មោះថា "បិនជមិនស៊ីហ្វូត Benjamin Seefood" ដែលស្ថិតក្នុងតំបន់ពាណិជ្ជកម្មផ្កាយ៥ហាងដ៏ធំធេងមួយតែងលំអជាសំពៅចោរសមុទ្រសម័យអតីតកាលតាំងពីទ្វារចូលទៅហើយ។ មិនខុសអីពីសារមន្ទីរចាប់ពីកន្លែងទទួលភ្ញៀវដែលអ្នកចាំបំរើស្លៀកពាក់ជាឯកសណ្ឋាននាវិក តាមជញ្ជាំង តាមផ្លូវដើរលើដំបូល មានតាំងលំអជារូបរាងនៅក្នុងសំពៅមានសត្វសមុទ្រក្នុងកែវមានកំរូនាវាទាំងយោធាទាំងសំពៅ ទាំងកុប៉ាល់គ្រូស័រតាំងអស់មានចំនួនមិនតិចជាង២០ទេ ធ្វើឱ្យភ្ញៀវដ៏ច្រើន នារាត្រីថ្ងៃសៅរ៍នោះ រំភើបនឹងភ្ញាក់ផ្អើលនឹងរបស់មិនដែលប្រទះ ក្រៅតែពីឃើញក្នុងកុន។ ម្ហូបអាហាររាប់រយមុខសុទ្ធតែជាគ្រឿងសមុទ្រគ្រប់ប្រភេទមានតាំងពីក្តាម បង្កង បង្គា ត្រី សាច់ បន្លែបង្កាស៊ុប ឆា សាច់អាំង ដាក់តាំងទាំងគរ គួរឱ្យស្រក់ទឹកមាត់ ចង់ហូប...បង្អែមនឹងផ្លែឈើច្រើនសិបមុខញញឹមដាក់ភ្ញៀវដែលចង់ហូបប៉ុន្មានក៏បានដែរ។ ខ្ញុំសំដៅរកជើងស្តេចក្តាមវែងៗសាច់ពេញៗមួយចានពោរ ប៉ុណ្ណារ៉ូ ទៅដួសយកកូនបង្កង"ក្របហ្វិស"មួយចាន រ៉ែដ៏រយកបង្គាចៀននឹងគ្រឿងសមុទ្រចំអិនហូបរួចទៅយកម្ហូបពោរពាសបំពេញចិត្តភ្ញៀវបន្តកន្ទុយដឹកជញ្ជូនចំណីដែលម្ចាស់ហាងផ្សព្វផ្សាយថា ជាហាងម្ហូបសមុទ្រធំជាងគេក្នុងលោក។

ចេញពីភោជនីយដ្ឋានមកវិញនៅម៉ោង១១យប់យើងមិនដឹងថា ត្រូវហៅជាភោជនីយដ្ឋាន ឬក៏ហៅថា ជាសារមន្ទីរនោះទេ តែអារម្មណ៍យើងមិនរំសាយពីទស្សនីយភាពក្នុងសំពៅនឹងចោរសមុទ្រដូចមែនទែនអ្វីៗហាក់ដូចជាសិល្បៈនៃការសម្តែងធ្វើឱ្យអតីតកាលចោរសមុទ្ររស់ឡើងវិញយ៉ាងរវើក...តែយើងខកចិត្តបន្តិចដោយត្រូវចាំតាក់ស៊ីប្រមាណ១ម៉ោងទើបបាន១ ដើម្បីត្រឡប់មកសណ្ឋាគារវិញ ព្រោះតែយប់នេះជាយប់ពិសេសនៅមើធិប៊ីចដោយសារថ្ងៃ "មេមូរិយលដេយ" នេះ មានការជួបប្រជុំអ្នកជិះម៉ូតូក្នុងប្រទេសនៅមើធិលប៊ីចនេះ ធ្វើឱ្យតាក់ស៊ីជាប់ផ្លូវគ្រប់កន្លែង ។

មកដល់សណ្ឋាគារវិញ ប្រមាណជាម៉ោង១២អាធ្រាត យើងជជែកគ្នាលេងបន្តិចអំពីការរៀបចំទទួលនឹងទាក់ទាញភ្ញៀវម្ចាស់ភោជនីយដ្ឋាន គេគិតធំធេងគេគ្រោងទទួលភ្ញៀវច្រើនអនុវត្តន៏គំនិតរបស់គេច្រើនឆ្នាំបណ្តាលឱ្យទិដ្ឋភាពនៃផ្លូវតាមផ្លូវក្បែរៗមាត់ឆ្នេរសមុទ្រក្លាយជាធំទូលាយ លំអដោយគំនូរ ចម្លាក់ សួនច្បារថែទាំមិនខកខានហាងនិមួយៗតែភ្ញៀវឆ្លងកាត់ម្តងហើយ ពិបាកនឹងភ្លេចទៅវិញ ពីព្រោះគេសង់ជាវត្ថុពិសេសអ្វីមួយតាំងពូមុខ ដូចជាភោជនីយដ្ឋាន"បិនចាមិន"គេតាំងចម្លាក់រូបចោរសមុទ្រយ៉ាងធំបរិវេណខាងមុខរៀបចំជារបៀបកកុប៉ាល់សមុទ្រតាំងពីទ្វារចូល...នៅភោជនីយដ្ឋានមួយទៀតឆ្ងាយបន្តិចគេតាំងរូបក្តាមសមុទ្រយក្សមួយគួរឱ្យចាប់ភ្នែក...នៅមានហាងលក់គ្រឿងលេងតាមឆ្នេរខ្សាច់ច្រើនរាប់មិនអស់សុទ្ធតែលំអដោយរូបគំនូរធំៗចម្លែកៗ មើលពីផ្លូវទៅគួរឱ្យចង់ឈប់ចូលទៅមើល។

ស្អែកឡើង មុននឹងបញ្ចប់វិស្សមកាលយើងឆ្លៀតទៅឆ្នេរខ្សាច់ខាងផ្នែកកណ្តាលក្រុងវិញម្តង នៅទីនោះសម្បូរតែហាងលេងកំសាន្តមានរោងកុនរោងល្បែងហ្គេមភ្ញាល់មានជិះរទេះកង់ធំវិញឡើងលើមេឃមានហាងលក់ឥវ៉ាន់សម្រាប់ទៅលេងទឹកសមុទ្រ... ដែលនៅទីនោះមានប្រជុំជនកកកុញមកដើរលេង ឬមើលការប្រកួតកីឡាលើដីខ្សាច់នឹងសម្លេងភ្លេងភ្លាត់តាំងពីព្រឹកដល់យប់ ។ នៅតំបន់"មើលធីលប៊ីច"មិនសម្បូរដោយសំណល់អតីតកាលដែលចាត់ទុកជាប្រវត្តិសាស្ត្រទេ អ្វីៗសុទ្ធតែទំនើប សូម្បីតែទីលានលេងកូនគោលបើទោះជាមានប្រវត្តិដល់រយឆ្នាំក៏ដោយ ក៏មានការថែរទាំឥតខ្ចោះប្រើបានរហូតដល់សព្វថ្ងៃមិនអាចដឹងថា ជារបស់វ៉ែយចំណាស់បានទេ តែបើចង់រៀនសូត្រពីប្រវត្តិនៃតំបន់ខាងត្បូងនៅក្បែរ មើធីលប៊ីច គេទៅកំសាន្តនៅ "ខនវ៉ែយ៏" ឌេលនៅមានសំណល់អតីតកាលបន្តិចបន្តួច បើមិនដូច្នោះទេ គេត្រូវទៅតំបន់ឆ្ងាយបន្តិចហៅថា ឆាឡេស្តុន។

យើងបន្តកម្មវិធីរបៀបដដែលៗនេះ បានជិតមួយអាទិត្យ ឋាមពលពេញខ្លួន ទើបសម្រេចចិត្តចេញទៅលេងក្រុង"ឆាឡេសតុន"ដែលនៅប្រមាណជា២ម៉ោងតាមរថយន្តទើបទៅដល់ភូមិចាស់ដែលរក្សាអនុស្សាវរីយ៏នៃអតីតកាលមានជាប់ទាក់ទងនឹងប្រវត្តិក្រុងឡូវ៉ែលខ្លះៗ បានប្រសើរណាស់ ហើយប្លែកជាងតំបន់នេះ។

នៅមើធីលប៊ីច ក៏ដូចជានៅតំបន់ឯទៀតៗនៃស.រ.អា. ទេសចរមានការងាយស្រួលនឹងដឹងថា គេនឹងនៅកន្លែងរបៀបណា? នឹងមានអ្វីខ្លះ? គុណភាពរបៀបណា? យ៉ាងច្បាស់លាស់ជាមុនដោយបច្ចេកទេសអេឡិត្រូនិកនឹងបច្ចេកទេសផ្សព្វផ្សាយ...គេរៀបទេសចរគេរបៀបនេះដើម្បីនាំទេសចរមកស្គាល់នឹងកំសាន្តតំបន់របស់គេ គឺលើកដំកើងសេដ្ឋកិច្ចនៃពាណិជ្ជកម្មនិមួយៗនឹងជីវភាពអ្នកនៅក្នុងតំបន់ផង។ នៅតាមផ្លូវលេខ១៧ទៅឆាឡេតុន គេឃើញមានតូបជាច្រើនតាមដងផ្លូវដែលប្រជាពលរដ្ឋនាំគ្នាដាក់លក់ស្នាដៃចាក់កន្ទេល ជាល ថាស ផូផ្កា ដែលធ្វើពីស្បូវ ឬពីស្លឹកត្នោតពូចម្យ៉ាងមានសន្លឹកតូចឆ្មារ

**តទៅទំព័រទី ២១**



# សិក្ខាសាលាគណបក្សសង្គ្រោះជាតិ

**ដោយ សុខផល ប៉ែន**



សុខផល ប៉ែន

**ឡូវែល:** នៅថ្ងៃទី៣០-៣១ ខែឧសភា គណបក្សសង្គ្រោះជាតិ MA បានរៀបចំសិក្ខាសាលាស្តីពីការជំនាញដឹកនាំជាសាធារណៈ (ភាពជាអ្នកដឹកនាំសម្រាប់សមាជិកគណបក្សសង្គ្រោះជាតិ។

វគ្គបណ្តុះបណ្តាលនេះត្រូវបានផ្តល់ដោយ Voop de Vulpillieres ដែលបានចំណាយពេលជាងមួយភាគបួននៃជីវិតជាអ្នកដឹកនាំការសិក្សា និងបង្រៀនជាគ្រូបង្វឹកនៅសាកលវិទ្យាល័យ Harvard ។ នៅទីនោះនាងរៀនបានបរិញ្ញាបត្របន្ទាប់មកបានក្លាយអ្នកស្រាវជ្រាវមួយរូបប្បបន្ទាប់មកបន្តរការសិក្សាជានិស្សិតថ្នាក់អនុបណ្ឌិត និងនៅបង្រៀនសិស្សសម្រាប់វគ្គអ្នកដឹកនាំ និងគ្រប់គ្រងជាច្រើន។ នាងបានទទួលបានពានរង្វាន់ឆ្នើមរបស់ព្រឹទ្ធបុរសមហាវិទ្យាល័យសម្រាប់ឧត្តមភាពនៅក្នុងសិស្សបង្រៀន។ ជម្រៅនៃចំណេះដឹងរបស់វូព បានបង្កើនឡើង នៅពេលទៅធ្វើការនៅកម្ពុជាបួនឆ្នាំរបស់នាងនៅក្នុងវាលការងារប្រឆាំងនឹងជម្ងឺអេដស៍ , នីតិរដ្ឋនិងសិទ្ធិមនុស្ស។

សិក្ខាកាមដែលបានមកចូលរួមក្នុងវគ្គសិក្សាសាលានេះ គឺជាសមាជិកគណបក្សសង្គ្រោះជាតិជាង២០នាក់ដែលជាលើកដំបូងបង្អស់ផ្តើមយកការសិក្សាមកបំពេញកិច្ចកាងារនយោបាយ។ ពួកគេយល់ថា គេបានធ្វើការជ្រើសរើសសមាជិកថ្មីនិងរៃអង្គាសថវិកាអស់ជាច្រើនទសវត្សរ៏មកហើយក្នុងកាងារគ្មានជំនាញបច្ចេកទេសទំនើបក្នុងគោលបំណងដើម្បីបង្កើនការអំណាចនយោបាយគណបក្សរបស់ខ្លួនរបស់ខ្លួនឱ្យអាចធ្វើការដូចនេះឱ្យរឹតតែ

**តទៅទំព័រទី ១៤**

# CNRP Workshop Leadership by

**Laure "Voop" de Vulpillieres from Harvard professors**

**Sok Paul Pen CNRP Youth in MA. USA)**

**NaretMoeung (Organizer and Translator)**



Voop de Vulpillieres



On May 30-31 CNRP MA organized a Public Narrative Workshop (Leadership Skill for CNRP members. CNRP members have been working for decades to recruit new members and fundraise, in order to increase its political power.How can we do this better? How can we recruit more people, more money? This training focused on how to engage others to join you action. We explored how to connect with others meaningfully, to build solid relationships of trust, so that others understand why you have been called to do this work, and to be excited to join us. These techniques were developed during the American Civil Rights Movement, and honed by Harvard professors and community organizers, into a training that has been taught to activists all over the world, including in Cambodia.

The training was provided by Laure "Voop" de Vulpillieres has spent over a quarter of her life studying and teaching leadership and coaching at Harvard. There, **Continued to Page 14**



# លោក វ៉ាស្នា នួន ឈរឈ្មោះជាក្រុមប្រឹក្សាក្រុងម្តងទៀត

**កំណត់ និពន្ធដោយខ្មែរផុសស.រ.អា.**

*"លោក វ៉ាស្នា នួន ជាអតីតសមាជិកក្រុមប្រឹក្សាក្រុងឆ្នាំ២០១២-១៣ បានចេញមកឈរឈ្មោះជាថ្មីម្តងទៀត សម្រាប់អាណត្តិ២០១៦-១៧ បន្ទាប់ពីភ្លាត់មិនបានជាប់ឆ្នោតក្នុងអាណត្តិ២០១៣-១៤។ គណកម្មការគាំទ្របេក្ខភាពដែលមិនបានបញ្ចេញឈ្មោះបានបញ្ជូនលិខិតគាំទ្រនឹងគោលជំហ៊ានយោបាយដែលនាំឱ្យលោក វ៉ាស្នា ចង់មកឈរឈ្មោះឱ្យពលរដ្ឋឡូវែលបោះឆ្នោតជូនលោកសាជាថ្មីដែលយើង សូមជូនអត្ថន័យទាំងស្រុង ដូចខាងក្រោមនេះ :"*

ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៥

ជូនចំពោះមិត្តភ័ក្តិទាំងអស់ជាទីគោរពរាប់អាន,



យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការជួយគាំទ្រដល់យុទ្ធការលោកវាសនាកាលពីពេលកន្លងមក។ ការជួយជ្រោមជ្រែងដ៏ស្វិតស្វាញរបស់អស់លោកអ្នក ដើម្បីជួយលោក វាសនា គឺជាទឹកចិត្តស្មោះសមិនអាចកាត់ថ្លៃបាន និងមានសារសំខាន់ខ្លាំងរហូតជួយឱ្យលោក វាសានា ជាប់ឆ្នោតជាមន្ត្រីក្រុមប្រឹក្សាក្រុងឡូវែលក្នុងឆ្នាំ២០១១។ ដូចអស់លោកអ្នកបានជ្រាបស្រាប់ហើយ ឥឡូវនេះលោក វាសនា បានសម្រេចចិត្តឈរឈ្មោះដើម្បីធ្វើជាមន្ត្រីមន្ត្រីក្រុមប្រឹក្សាក្រុងឡូវែលម្តងទៀត។ គោលបំណងចម្បងក្នុងការឈានជើងប្រឡូកក្នុងឆាកនយោបាយម្តងទៀតនេះគឺដោយសារតែលោកវាសានាមានទស្សនវិស័យចំពោះការគ្រប់គ្រងសាលាក្រុងឡូវែល។ គាត់មានជំនឿមុតមាំថា បើដឹកនាំបានត្រឹមត្រូវល្អនៅកម្រិតសាលាក្រុងគាត់អាចកែលម្អកម្រិតជីវភាពរស់នៅរបស់ប្រជាជនបានប្រសើរជាងនេះ។ គាត់ជឿជាក់ថា ដើម្បីអាចកែប្រែជីវភាពរស់នៅរបស់ប្រជាជនបាន គឺមានតែចូលរួមកាន់កិច្ចការនៅសាលាក្រុងឡូវែល។

លោក វាសនា មានបទពិសោធន៏ការងារក្នុងវិស័យពង្រឹងការអនុវត្តច្បាប់។ បទពិសោធន៏នេះ ធ្វើឱ្យគាត់រឹតតែមានកម្លាំងចិត្ត និងការប្តេជ្ញាចិត្តខ្ពស់ ដើម្បីកែលម្អបញ្ហាសុវត្ថិភាពឱ្យមានលក្ខណៈល្អប្រសើរជាងមុនសម្រាប់ប្រជាជនទីក្រុងឡូវែលទាំងអស់។

កាលក្នុងអាណត្តិដែលគាត់ជាប់ឆ្នោតជាមន្ត្រីក្រុមប្រឹក្សាក្រុង លោក វាសនា បានបំពេញការងារយ៉ាងយកចិត្តទុកដាក់បំផុត ជាមួយមន្ត្រីក្រុមប្រឹក្សាក្រុងដទៃទៀត ដើម្បីជួយកាត់បន្ថយពន្ធអាករយើងទាំងអស់គ្នា, ជួយកែលម្អស្ថានភាពផ្លូវថ្នល់យើង និងតំបន់ជិតខាង, ជួយរិះរកគ្រប់មធ្យោបាយ ដើម្បីឧបត្ថម្ភគាំទ្រដល់ផ្នែកពន្លត់អគ្គីភ័យ,ជួយពង្រឹងសេវាប៉ូលីស ដើម្បីរក្សាសុវត្ថិភាពនៅតាមដងផ្លូវ និងតាមភូមិឋានជិតខាងគ្រប់ពេលវេលា។

យុទ្ធនាការដែលអាចជោគជ័យ គឺអាស្រ័យកត្តាសំខាន់ពីរ: ការខិតខំធ្វើការ និងមានមូលនិធិគ្រប់គ្រាន់។ យើងខ្ញុំប្តេជ្ញាចិត្តបំពេញការងារដោយមិនខ្លាចនឿយហត់ ដើម្បីជួយផ្សព្វផ្សាយសាររបស់លោកវាសនាដោយផ្តោតលើការធ្វើឱ្យទីក្រុងឡូវែលជាទីក្រុងមានលក្ខណៈល្អប្រសើរជាងមុនទាំងខាងសេដ្ឋកិច្ច និងប្រជាធិបតេយ្យ និងប្តេជ្ញាបន្តថែរក្សា និងកែលម្អសុវត្ថិភាពសាធារណៈ និងសេវាទីក្រុងឱ្យមានភាពល្អប្រសើរជាងមុនជាលំដាប់។ ការជួយផ្តល់វិភាគទានជាថវិការបស់អស់លោកអ្នកទាំងអស់ពិតជាមានសារសំខាន់ និងអត្ថន័យយ៉ាងជ្រាលជ្រៅចំពោះលោក វាសនា។

ជាថ្មីម្តងទៀត យើងខ្ញុំសូមថ្លែងអំណរគុណដែលអស់លោកអ្នកទាំងអស់បានជួយគាំទ្រលោក វាសនា។ យើងខ្ញុំសង្ឃឹមថា អស់លោកអ្នកអាចជួយផ្តល់វិភាគទានដើម្បីជួយយុទ្ធនាការរបស់គាត់ថ្ងៃនេះ។

សូមទទួលនូវសេចក្តីគោរព និងរាប់អានអំពីយើងខ្ញុំ!

គណៈកម្មាធិការជ្រោមជ្រែងឱ្យលោក វាសនា នួន

បានជាប់ឆ្នោតជាមន្ត្រីក្រុមប្រឹក្សាក្រុង

704 Middlesex Street

Lowell, MA 01851


THE LOWELL FLOWER HOUSE

Flower arrangement and Decoration for all occasions

209 Chelmsford St, Lowell, MA 01851

Tel: 978-455-0999, (978) 529-8627

By Sereysophana Yauk, a Talent Cambodian Artist








# ទូកងខ្មែរជាសម្រាមនៅវត្តត្រៃរតនារាម

**ដោយ ខ្មែរផុសស.រ.អា -**
**រូបថតដោយ ណារ៉ាត**

ទូកង៥គ្រឿងមានទូក១ទំហំ១០៥ហ្វិត នឹងទូក៤ទៀតទំហំពាក់កណ្ដាលទូកធំ ទុកចោលជាសម្រាមច្រើនឆ្នាំនៅកៀនរបងវត្តត្រៃរតនារាម បានត្រូវព្រះសង្ឃនឹងប្រធានវត្តសម្រេចកំទេចចោលកាលពីថ្ងៃទី២៤ឧសភា ឆ្នាំ២០១៥ ដោយសារទូកគ្មានម្ចាស់គ្មាននរណាថែទាំពុករលួយអស់ទៅហើយធ្វើឱ្យវត្តក្លាយជាកន្លែងក្រខ្វក់កំពុងទទួលការស្ដីបន្ទោសពិក្រុមត្រួតពិនិត្យសាលាក្រុង។ នាយកកាសែតខ្មែរផុស ពិន សំខុន បានទៅទាន់ព្រឹត្តិកាណ៍នោះ បានទូលស្នើសុំព្រះសង្ឃឱ្យរក្សាទូកដែលនៅសល់មិនទាន់កាត់ជាកង់តូចទុកឱ្យលោកយកទៅរៀបចំជួសជុលឡើងវិញសម្រាប់ទុកជូនជាមរតកកេរដំណែលដល់សហ-គមន៏ខ្មែរ ។ ទូកដែលនៅសល់មាន ទូកតូច២ នឹងទូកធំនៅសល់តែក្បាលនឹងកន្ទុយទូក តួកណ្ដាលខ្លួនបានត្រូវចិញ្ច្រាំចោលរួចស្រេចទៅហើយ ។ បើតាមសម្ដីលោក ប៊ុនរីទ្ធ ឡាច ដែលបានផ្ដល់បទសម្ភាសន៏ដល់ខ្មែរផុសថ្មីៗនេះ បានឱ្យដឹងថា ទូកធំនេះជាអំណោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន



រីឯលោក ប៊ុនរីទ្ធ ជាអ្នកចេញសោហ៊ុយដឹកពីភ្នំពេញយកមកឡូវែលជាមួយនឹងទូក៤ទៀតដែលទិញដោយអ្នកស្រុកឡូវែលមានទាំងទិញស៊ីក្លូ១០គ្រឿងដាក់មកជាមួយទៀតផង សម្រាប់យកមកចូលរួមពិធីអុំទូកនៅឡូវែលនេះ។ ជាអកុសលទូកក៏បានក្លាយទៅជាសម្រាមនឹងជាចំណីដំស្មៃរ ឬធុងសម្រាម រីឯស៊ីក្លូខ្មែរក៏បាត់បង់អស់គ្មានឃើញសល់មួយទេ។

បច្ចុប្បន្ននេះ ទូកតូចមានផ្នែកបាក់បែកដោយអន្លើនឹងពុកខ្លះទៅហើយ រីឯទូកធំ ក៏បាត់បង់កណ្ដាលខ្លួនទូកទៅហើយដែរ ទូកទាំងអស់មានធ្លុះធ្លាយគ្រប់កន្លែង ហើយពណិសម្បុរក៏របើករបាញអស់ហើយដែរ ដែលការជួសជុលឡើងវិញត្រូវការគំនិតថ្មីនឹងសោហ៊ុយច្រើន។

ជាការពិតទូកងថ្វីត្បិតតែក្លាយជាសម្រាមទៅហើយក្ដី ក៏នៅមានបង្កប់នូវប្រវត្តិនៃការមកតាំងទីរបស់ប្រជាពលរដ្ឋខ្មែរនៅឆ្នេរខាងកើតស.រ.អា.នេះ រាប់មិនអស់។ ដូច្នេះបើទូកនោះនៅមានម្ចាស់នៅឡើយ ហើយប្រាថ្នាមិនឱ្យនរណាប៉ះពាល់ សូមឱ្យដំណឹងមក "ខ្មែរផុសស.រ.អា" ក្នុងរយពេល១ខែ ចាប់ពីពេលផ្សាយអត្ថបទនេះ



ទៅមុននឹងយើងប្ដើមសកម្មភាពស្រោចស្រង់សម្រាមដ៏មានន័យនេះឡើងវិញ។ ព្រះតេជគុណឡែម នៃវត្តត្រៃរតនារាមថា "ចាំពិគ្រោះជាមួយគណកម្មការវត្តសិន" រីឯព្រះតេជគុណ សារិន អតីតវត្តក្រោមថា "សមាគមខ្មែរគេយកមកចោលនៅទីនោះគ្មានទាក់ទងអ្វីនឹងវត្តទេ"៕



# ព័ត៌មានសំខាន់អន្តរជាតិ និងទាន់សភាពការណ៍ខ្លីៗ

រៀបរៀងដោយៈ បុគ្គលិកស្ម័គ្រចិត្ត KO
*ដកស្រង់ចេញពីកាសែតញ៉ូយ៉កថែម (NewYorkTime)*

**●ទីក្រុង ឡូស្ស អង្ជឺលិស្ស (Los Angeles) បានដំឡើងប្រាក់ឈ្នួលសំរាប់កម្មករដល់ទៅ១៥ ដុល្លារក្នុងមួយម៉ោង**

ថ្ងៃអាទិត្យ ទី១៧ ខែឧសភា ឆ្នាំ២០១៥

ការដំឡើងប្រាក់ឈ្នួលនេះគឺជាភាពជោគជ័យដ៏ប្រសើរបំផុតនៃទីក្រុង ឡូស្ស អង្ជឺលិស្ស (Los Angeles) ដែលជាទីក្រុងទីពីរធំជាងបង្អស់ក្នុងសហរដ្ឋអាមេរិក ។ ក្រុមប្រឹក្សាក្រុងបានបោះឆ្នោតអនុម័តលើសំណើរនេះអោយមានឥទ្ធិពលដល់ឆ្នាំ២០២០ ដោយមានសំលេង១៤គាំទ្រ និង១ប្រឆាំង។

ការដំឡើងប្រាក់ឈ្នួលសំរាប់កម្មករនៃទីក្រុងនេះបានធ្វើឱ្យមានការរំជើបរំជួលដល់ចលនាកម្មករដ៏ទៀតទូទាំងសហរដ្ឋការមេរិក ពួកគេនាំគ្នារៀបចំធ្វើបាតុកម្មដើម្បីទាមទារដំឡើងប្រាក់ឈ្នួលរបស់ពួកគេ ក្រុមហ៊ុនធំៗដូចជា ហ្វេប៊ុក(Facebook) ហើយនឹង វ៉ុលម៉ាត (Walmart) បានដំឡើងប្រាក់បៀវត្សដល់កម្មកររបស់ខ្លួនទៅហើយ ។

ទីក្រុងជាច្រើនទៀតដូចជាៈ សាន ហ្វ្រានសិស្កូ (San Francisco), ស៊ីអាតូល (Seattle) and អុកក្លាន់ (Oakhan) នៃរដ្ឋកាលីហ្វញ៉ា បានបោះឆ្នោតសំរេចដើម្បីដំឡើងប្រាក់ឈ្នួលសំរាប់កម្មកររបស់ពួកគេ និងមានទីក្រុងជាច្រើនថែមទៀតបានធ្វើដូចគ្នានឹងទីក្រុងខាងលើនេះដែរ ។

នាឆ្នាំ២០១៤ រដ្ឋមួយចំនួនដូចជាៈ អាឡាស្កា (Alaska) ហើយ និងរដ្ឋ សៅ ដាកូតា (South Dakota) ដែលជារដ្ឋមានទំនោរខាងសាធារណរដ្ឋនិយមបានសំរេចដំឡើងប្រាក់ឈ្នួលដល់កម្មកររបស់គេនេះធ្វើឡើងដោយប្រជាមតិ។

ក៏ប៉ុន្តែចំពោះទីក្រុង ឡូស្ស អង្ជឺលិស្ស (Los Angeles) គឺមានឥទ្ធិពលខ្លាំងជាងគេពីព្រោះថា យោងតាមការសន្និដានមួយចំនួនកម្មករជាង៤០ភាគរយនៃទីក្រុងនេះ ធ្វើការក្នុងតំលៃប្រាក់ឈ្នួលតិចជាង១៥ដុល្លារក្នុងមួយម៉ោង។ ព័ត៌មានពិស្តារ សូមអានៈ http://news.yahoo.com/los-angeles-mayor-signs-15-hour-minimum-wage-010243754--finance.html

**● រថភ្លើងអាម ត្រាក (Amtrak)**

ថ្ងៃអាទិត្យ ទី១៧ ខែឧសភា ឆ្នាំ២០១៥

រថភ្លើងអាម ត្រាក (Amtrak) ដែលធ្លាប់តែមានសេវាកម្មរបស់ខ្លួនរវាងទីក្រុង ញ៉ូយ៉ក (New York) ហើយនឹងទីក្រុង ហ្វីលឡាដែលហ្វៀ (Philadelphia)ត្រូវបានបន្តសេវាកម្មរបស់ខ្លួនឡើងវិញហើយបន្ទាប់ពីបានផ្អាកសេវាកម្មរបស់ខ្លួនអស់រយៈពេលជាច្រើនថ្ងៃមកដោយសារតែរថភ្លើងអាមត្រាក (Amtrak) នេះធ្វើដំណើរខុសផ្លូវរភ្លើងរបស់ខ្លួននៅទីក្រុងហ្វីលឡាដែលហ្វៀ (Philadelphia)។ គ្រោះថ្នាក់នេះបានធ្វើឱ្យអ្នកដំណើរ៨នាក់បាត់បងជីវិតនិងអ្នកដំណើរជាង ២០០នាក់ទៀតរងរបួស។


ប្រធានហ្វីហ្វា


ណាស់ រង្វាន់ណូបែល ខាងគណិតវិទ្យា

-បណ្ឌិត Jonh Dash ដែលជាអ្នកឈ្នះពាន់រង្វាន់ ណូបែល (Nobel) ផ្នែកគណិតវិទ្យានៅលើពិភពលោកហើយ និងត្រូវបានគេបង្ហាញពីប្រវត្តិលោកបណ្ឌិតក្នុងខ្សែភាពយន្តរឿង "ខួរក្បាលពោរពេញទៅដោយទេពកោសល្យ"(ABeautiful Mind) ត្រូវបានទទួលមរណៈភាពដោយសារគ្រោះថ្នាក់ចរាចរ នាថ្ងៃសៅរ៍ទី២៣ឧសភា ឆ្នាំ២០១៥

**● ថ្ងៃអាទិត្យទី២៤ ខែឧសភា ឆ្នាំ២០១៥ Jonh Dash Jr. គណិតវិទូដែលបានទទួលពាន់រង្វាន់ណូបែល Nobel ពិភពលោកនៅក្នុងឆ្នាំ១៩៩៤** ផ្នែកសេដ្ឋកិច្ចចំពោះឥទ្ធិពលក្នុងសម័យទំនើបរបស់ទ្រឹស្តីសេដ្ឋកិច្ចដែលអាចសំរេចនូវសក្តានុពលរបស់ខ្លួន (Game Theory, Differential Geometry, and Differential Equation) ។ លោកបណ្ឌិតមានជំងឺខួរក្បាលដ៏ធ្ងន់ធ្ងរអស់រយៈរាប់ទសវត្សរ៍តែក្រោយមកបានជាសះស្បើយឡើងវិញ។ ជីវប្រវត្តិរបស់គាត់ត្រូវបានគេពិពណ៌នាក្នុងខ្សែភាពយន្តរឿង "ខួរក្បាលពោរពេញទៅដោយទេពកោសល្យ"(ABeautiful Mind)។ បណ្ឌិតបានទទួលមរណៈភាពដោយសារគ្រោះថ្នាក់ចរាចរនៅថ្ងៃសៅរ៍ទី២៣ឧសភាឆ្នាំ២០១៥ ក្នុងរដ្ឋ ញូ ជើស៊ី (New Jersey) ក្នុងអាយុ៨៦ឆ្នាំ។


គ្រោះថ្នាក់រថភ្លើងនៅហ្វីឡាដែលហ្វៀ

តាមសំដីរបស់លោកពលបាលង្កេង្ហី វៀល លៀម្ស (Gregory Williams) នៃស្នងការនគរបាលក្នុងរដ្ឋ ញូ ជើស៊ី (New Jersey) បានឱ្យដឹងថា លោក ណាស្ស (Nash) ហើយនិងភរិយារបស់គាត់អាលីសៀ (Alicia) ដែលមានអាយុ៨២ឆ្នាំ ត្រូវបានធ្លាក់ចេញពីរថយន្តតាក់ស៊ី (Taxi) និងស្លាប់នៅទីកន្លែងកើតហេតុតែម្តងដោយសារតែអ្នកបើកបររថយន្តតាក់ស៊ី (Taxi) នេះបានបាត់បង់លំនឹងរបស់ខ្លួន ហើយបានទៅបុកបង្កាន់ដៃសំរាប់ការពារផ្លូវនឹងទៅបុករថយន្តមួយទៀតនៅពេលអ្នកបើកបររថយន្តតាក់ស៊ី (Taxi) នេះព្យាយាមវ៉ារថយន្តនៅតាមដងផ្លូវ។ អ្នកបើកបររថយន្តតាក់ស៊ី (Taxi) នឹងអ្នកបើកបររថយន្តមួយទៀតនោះត្រូវបានគេយកទៅព្យាបាលនៅមន្ទីរពេទ្យតែរបួសរបស់ពួកគាត់មិនប៉ះផាល់ដល់អាយុជីវិតនោះទេ។ ក្នុងឱកាសនេះមិនទាន់មានការផ្តន្ទា ទោសពីបទឧក្រិដ្ឋនៅឡើយ ចំពោះភាពគ្រោះថ្នាក់នេះទេ។ គ្រោះថ្នាក់ចរាចរនេះកើតឡើងនៅលើវិថី ញ៉ូ ជើស៊ី ថើនផៃ(New Jersey Turnpike) ក្នុងរដ្ឋ ញ៉ូជើស៊ី (New Jersey) ។

បណ្ឌិត ណាស្ស (Nash) គឺជាគណិតវិទូដ៏ល្បីល្បាញម្នាក់នៅក្នុងសតវត្សទី២០ ស្តីពីទសន្ទនៈដំបូងបង្អស់របស់គាត់ដែលគាត់មិនខ្លាច និងដោះស្រាយបញ្ហាលំបាកៗមួយចំនួនដែលពួកគណិតវិទូដទៃទៀតមិនហ៊ានដោះស្រាយ។ យោងតាមលិខិតមួយដែលសរសេរគាំទ្រនូវនិក្ខេបទនៃកម្មវិធីបណ្ឌិតផ្នែកគណិតវិទ្យានៃសកលវិទ្យាល័យព្រីនស្តូន (Princeton) របស់គាត់បានត្រូវគេឱ្យឈ្មោះគាត់ថា "ជាបុរសដែលមានទេពកោសល្យខ្ពស់"(This man is genius)

ទ្រឹស្តីមិនសហការរបស់គាត់ដែលបានបោះពុម្ពផ្សាយក្នុងឆ្នាំ១៩៥០ត្រូវគេអោយឈ្មោះថាតុល្យភាពរបស់លោកណាស្ស (Nash) ដែលស្តីពីៈ ទ្រឹស្តីងាយស្រួលក៏ប៉ុន្តែវាជាទ្រឹស្តីគណិតវិទ្យាដ៏សំខាន់សំរាប់ការវិភាគពីភាពប្រកួតប្រជែងផ្សេងៗដែលជាប្រយោជន៍សំរាប់ឱ្យក្រុមហ៊ុនផ្សេងៗដើម្បីលើកតំរោងឡើងនិងតាក់តែងធ្វើច្បាប់របស់ខ្លួន។ គោលការណ៍របស់បណ្ឌិត ណាសហបច្ចុប្បន្នត្រូវបានគេប្រើប្រាស់ជាច្រើនក្នុងវិស័យសេដ្ឋកិច្ច និងវិស័យវិទ្យាសាស្ត្រសង្គមបន្ថែមលើសពីនេះទៅទៀត ត្រូវបានគេប្រើបាស្រ់ទ្រឹស្តីរបស់គាត់ជាប្រចាំក្នុងវិស័យផ្សេងៗទៀតដូចជាៈ ក្នុងការវិវត្តន៍នៃជីវវិទ្យាជាដើម។ ព័ត៌មានពិស្តារស្តីពីជីវិតរបស់បណ្ឌិតណាស្ស សូមចូលទៅគេហទំព័រៈ

http://www.pbs.org/wgbh/amex/nash/peopleevents/p_jnash.html

**●តាមព័ត៌មានជាផ្លូវការបានអោយដឹងថាៈ នាយករបស់ស្ថាប័ន ហ្វីហ្វា (FIFA) ត្រូវមានគេស៊ើបអង្កេតពីបទពុករលួយរបស់គាត់ ។**

ថ្ងៃអង្គារ ទី២ មិថុនា ឆ្នាំ២០១៥

លោក សិប ប្លែតតឺ (SeppBlatter) ដែលត្រូវបានជាប់ឆ្នោតម្តងទៀតជាប្រធាននៃស្ថាប័នសហព័ន្ធនៃសមាគមបាល់ទាត់ពិភពលោកដែលហៅគាត់ថា ហ្វីហ្វា (FIFA) ក្នុងអាណត្តិទី៥នេះ។ យោងតាមមន្ត្រីជាផ្លូវការផ្នែកប្រត្តិបត្តិច្បាប់បានបញ្ជាក់ថាៈ លោក ប្លែតតឺ (Blatter) នឹងលាលែងពីតំណែងរបស់គាត់នាថ្ងៃអង្គារនេះព្រោះថា គាត់ត្រូវបានសហព័ន្ធសហរដ្ឋការមេរិកស៊ើបអង្កេតអំពីករណីពុករលួយរបស់គាត់។ លោក ប្លែតតឺ (Blatter) មានពេលមួយចំនួន ដើម្បីព្យាយាមដកខ្លួនចេញពីភាពចម្រូងចម្រាស់នេះក៏ប៉ុន្តែមន្ត្រីសហរដ្ឋអាមេរិកមួយចំនួនដែលសុំមិនបញ្ចេញឈ្មោះបានប្តឹងតវ៉ាពីបទពុករលួយរបស់លោក។ មន្ត្រីសហរដ្ឋអាមេរិកទាំងនោះសង្ឃឹមថានឹងមានការសហការផងដែរពីសំណាក់មន្ត្រី ហ្វីហ្វា (FIFA) មួយចំនួនដែលត្រូវក្រុមលោកប្លែតតឺបានចោទប្រកាន់ដល់ពួកគេ **តទៅទំព័រទី ២៥**

# REMEDIUM PHARMACY

2 VINAL Square
N. Chelmsford, MA 01863

Phone: (978) 251-7070

## FREE Daily Home Delivery



**Blisterpack Packaging**

**Friendly Consultations**

**Compounded Medications**

**Easy Transfers**

បុគ្គលិកទាំងអស់របស់ឱសថស្ថានរីមីឌីមយើងខ្ញុំមានបទពិសោធន៍គ្រប់គ្រាន់ក្នុងការបំរើសេវាផ្តល់ឱសថជូនដល់សហគមន៍ខ្មែរ។ គេទាំងអស់គ្នាបានត្រៀមរួចជាស្រេចដើម្បីជួយ និង ត្រៀមបំរុងជានិច្ច ដើម្បីប្រើគ្រប់ជំនាញ និងការពិសោធន៍ក្នុងការបំរើលោកអ្នក។

ឱសថស្ថានរីមីឌីម ផ្តល់ជូនលោកអ្នកនូវៈ

**ជូនឱសថឲ្យដល់លំនៅស្ថានដោយឥតគិតថ្លៃ**
**ដាក់ឱសថក្នុងបន្ទះបែងចែកឱសថសំរាប់ប្រើតាមពេល**
**ការពិគ្រោះយោបល់យ៉ាងរាក់ទាក់ស្និទស្នាល**
**មានផ្តល់ជូនម្សៅថ្នាំលាយ**
**ភាពងាយស្រួលក្នុងការផ្ទេរចេញចូល**






**Cristina គ្រីស្ទីណាៈ**
គ្រីស្ទីណាមានការពិសោធន៍គ្រប់គ្រាន់នៅក្នុងកិច្ចការបំរើសហគមន៍ខ្មែរក្រុងឡូវែលអស់រយៈពេលជាង៣ឆ្នាំមកហើយ។អ្នកស្រីគឺជាឱសថការិនីដែលគ្រប់គ្រងឱសថស្ថាន រីមីឌីម នេះ ហើយគាត់ក៏អាចធ្វើការពិគ្រោះអំពីឱសថ ជូនលោកអ្នកដល់ផ្ទះផងដែរ។ ដោយសារការផ្តល់នូវសេវាកម្មផ្នែកឱសថនេះ បានច្បាស់លាស់ទើប អ្នកស្រីអាចបង្កើត បាននូវចំណងមិត្តភាពយ៉ាងល្អប្រពៃក្នុងសហគមន៍ខ្មែរក្នុងក្រុងឡូវែល ហើយអ្នកស្រីមានសេចក្តីរីករាយណាស់ដើម្បីរង់ចាំបំពេញនូវបំណងរបស់លោកអ្នកដែលត្រូវការឱសថ។



**Pahim លោកប៉ាហ៊ីមៈ**
គឺជាបុគ្គលម្នាក់ដែលមានការគោរពច្រើននៅក្នុងសហគមន៍ខ្មែរ គាត់ក៏ជាសមាជិកម្នាក់នៅក្នុងគណកម្មការវត្តត្រៃរតនារាម ហើយធ្លាប់មានការពិសោធន៍ជាច្រើនឆ្នាំក្នុងការជួយសហគមន៍ដែលត្រូវការព្យាបាលជម្ងឺ។ ក្នុងរយៈកាលកន្លងមក គាត់ធ្លាប់បានធ្វើការយ៉ាងច្រើនជួយគាំទ្រដល់អ្នកជម្ងឺនៅមជ្ឈមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែលនិងមណ្ឌលសុខភាពពេទ្យមេត្តា ព្រមទាំងធ្លាប់បានចូលរួមចំណែកក្នុងការថែទាំដោយឱសថសំរាប់សហគមន៍ខ្មែរក្រុងឡូវែលអស់រយៈពេលជាង២ឆ្នាំផងដែរ។ ក្នុងនាមជសមាជិកម្នាក់នៃឱសថស្ថានរីមីឌីម គាត់នឹងបន្តធ្វើការបំរើឱ្យកាន់តែខ្លាំងខ្លាថែមទៀតដើម្បីបំពេញនូវតំរូវការក្នុងការផ្តល់ឱសថដល់លោកអ្នក។



**Dary ដារីៈ**
តែងបានយកចិត្តទុកដាក់ជាប់ជានិច្ចក្នុងសេវាកម្មផ្តល់ឱសថ ដើម្បីបំពេញតាមតំរូវការនៃសហគមន៍ខ្មែរក្រុងឡូវែលអស់រយៈជាង២ឆ្នាំមកហើយ ហើយតែងទទួលបាននូវការកោតសរសើរពីសំណាក់អតិថិជនដែលបានជួបប្រាស្រ័យជាមួយគាត់។ ក្នុងឋានៈជាអ្នកបច្ចេកទេសម្នាក់របស់ឱសថស្ថាន គាត់មានការយល់ដឹងយ៉ាងជ្រៅជ្រះអំពី តំរូវការ និងប៉ិនប្រសប់ក្នុងការផ្តល់សេវាជូនលោកអ្នកនិងចេះសំដែងនូវការគោរពយ៉ាងទន់ភ្លន់ចំពោះលោកអ្នកផងដែរ។



**Kelly ខែលលីៈ**
គឺជាឱសថការិនីយើងដែលអាចនិយាយភាសាខ្មែរហើយដែលយកចិត្តទុកដាក់ចេះជួយលោកអ្នក។ គាត់ជាឱសថការិនី ចេញពីមហាវិទ្យាល័យឱសថសាស្ត្ររដ្ឋម៉ាសាឈូសេត និង ពេញចិត្តធ្វើការបំរើសហគមន៍ខ្មែរដែលគាត់ក៏ជាសមាជិកម្នាក់នៃសហគមន៍នេះដែរ។



**Daniela ដានីញែលឡាៈ**
មានជំនាញច្បាស់លាស់ក្នុងការវេចខ្ចប់ឱសថដាក់ក្នុងបន្ទះពង្រាយថ្នាំសំរាប់ប្រើតាមពេល ហើយធ្លាប់ឆ្លងកាត់ការថែទាំអ្នកជម្ងឺខ្មែរដែលរស់នៅក្នុងក្រុងឡូវែលនេះអស់រយៈពេលជាង៣ឆ្នាំមកហើយ។ ប្រសិនបើលោកពេញចិត្តនឹងការប្រើថ្នាំដាក់ក្នុងបន្ទះបែបនេះ ដានីញែលឡាពេញចិត្តណាស់នឹងធ្វើកិច្ចការនេះជូនលោកអ្នក។



**Kassandraកាសាន់ដ្រាៈ**
គឺជាបុគ្គលិកដែលមានការពិសោធន៍ច្រើនក្នុងការធ្វើទំនាក់ទំនងជាមួយសហគមន៍ខ្មែរ និងស្បានិសសដែលរស់កក្នុងងក្រុងឡឡូវែលលនេះ។
លោកអ្នកអាចនឹងពេញចិត្តអំពីភាពរាក់ទាក់រាល់ពេលនិយាយឆ្លើយឆ្លងតាមទូរស័ព្ទជាមួយនាង និងប៉ិនប្រសប់ក្នុងការរៀបចំឱសថជូនលោកអ្នកនៅរាល់ពេលដែលលោកអ្នកត្រូវការ។

# ចាប់ផ្តើមកម្មវិធីរដូវក្តៅនៅក្រុងឡូវែល

**ដោយលោក Henri Marchand,**

**ប្រែសម្រួលដោយ ខ្មែរផុស**

ទីក្រុងឡូវែលនៃរដ្ឋមាសាឈូសិត,នៅថ្ងៃសុក្រ ទី១៩ខែមិថុនា, និងថ្ងៃសៅរ៍ទី២០, ក្រុងឡូវែលនឹងចាប់ផ្តើមកម្មវិធីបុណ្យរដូវក្តៅមួយដែលមានខ្នាតតូច,នៅក្នុងបរិវេណនៃទីប្រជុំក្រុង ,ដែលមានបង្ហាញវិចិត្រករ, សកម្មភាពរបស់កុមារ, តន្ត្រី,ល្បែង។ គូរគំនូរកណ្តាលវាល។ និងល្បែងច្រើនទៀត។ ក្រុមគ្រួសារដែលចូលចិត្តជាងគេនៅឡូវែល, មានគ្រួសារ ហ្គាតើ (Gator), កាណាលី ហ្គាតើ(Canaligator), មីលី ហ្គាតើ ( Millie-Gator), និងអាលី ហ្គាតើ (Allie Gator) នឹងមានការបំរុងជាស្រេចដើម្បីជួបស្វាគមន៍អ្នកគាំទ្រជាច្រើនរបស់ពួកគេ។

ពេលវេលាសម្រាប់ឱកាសនេះ, គឺថ្ងៃសុក្រពីម៉ោង២រសៀល - ៧ល្ងាច, និងថ្ងៃសៅរ៍ពីម៉ោង១២ថ្ងៃត្រង់ -ម៉ោង៦ល្ងាច, ផ្លូវប៉មមើ (Palmer Street)នឹងត្រូវបានបិទ, ចាប់ពីផ្លូវម៉ាកឃិត ( Market St) និងផ្លូវ មិដុល (Middle), បន្តបិតពីមិដុល (Middle) រហូតដល់ផ្លូវ មេរីម៉ែក (Merrimack St) ក្នុងអំឡុងពេលធ្វើពិធីបុណ្យ ២ថ្ងៃនោះ។

នៅថ្ងៃសុក្រនេះនឹងផ្តោតទៅលើសិល្បៈនិងតន្ត្រី, មានសិល្បករមួយចំនួនបានរៀបចំការដាក់តាំងតវ៉ាន់របស់ពួកគេ, អ្នកផ្សេងទៀតរៀបចំជើងទ្រូរូបភាពរបស់ពួកគេ។ ទស្សនៈវិស័យសិល្បៈនៃឈុតឆាកទីប្រជុំជនក្នុងក្រុង, ទិដ្ឋភាពកំពុងជជែកគ្នាក្នុងការរស់នៅរបស់ពួកគេ។ ក្រុមតន្ត្រីនឹងប្រគុំចេញពីភោជនីយដ្ឋានដែលចូលមករួម។

នៅថ្ងៃសៅរ៍សិល្បករនឹងត្រូវបានចូលរួម

ដោយបុគ្គលិកក្រុងនាយកដ្ឋានផ្នែកបង្កើតល្បែងកំសាន្តសំរាប់កុមារឡូវែល, និងក្រុមរវៃកប្បាសដោយពណ៌ និងល្បែងត្រសូលចូលជិតវត្ថុដែលជាទីគាប់ចិត្ត (Cuddly mascots) សិល្បៈករវ័យក្មេងត្រូវបានអញ្ជើញដើម្បីបង្ហាញពីទេពកោសល្យសិល្បៈរបស់ខ្លួនដែលបានបង្កើតសិល្បៈដោយដីសតាមចិញ្ចើមផ្លូវ។

"កម្មវិធីបុណ្យរដូវក្តៅជាពិធីមួយដ៏ល្អសម្រាប់ផ្តើមរដូវថ្មី,នឹងបង្ហាញឱ្យឃើញនូវអ្វីដែលសាលា ក្រុងអាចជូនបាន លោកខែវិន មើភី (Kevin Murphy) អ្នកគ្រប់គ្រងក្រុង បានថ្លែងបន្ថា ជាមួយនឹងសហគមន៏សិល្បករកាន់តែរីធំ ភោជនីយដ្ឋានតែំយយ និងការទាក់ទាញក្រុមគ្រួសារមិត្តភាព, វាពិតជាមានអ្វីច្រើនទៀត ដែល



គួរឱ្យចូលចិត្តអំពីក្រុងឡូវែលនៅរដូវក្តៅនេះ! ។

អាហារនឹងការសម្តែងសិល្បៈទៅពីដៃមួយទៅដៃមួយទៀត និងមិនធ្វើឱ្យភ្ញៀវធ្វើទស្សនៈកិច្ចហត់ហេវតែនឹងមិនខ្វះជម្រើសជាច្រើនបែបដើម្បីរីករាយនឹងចំណីអាហាររួមជាមួយគ្នា ឬចូលភោជនីយដ្ឋានល្អជាច្រើន, ឬទិញនៅទីផ្សាដែលបានរៀបចំដោយអង្គការ, ឬនៅមៀល ស៊ីទី (Mill City Grows mobile market.) ឬទិញនៅតាមផ្លូវដើរចូលរួមជាមួយអ្នកអជីវកម្ម និងមានការបញ្ចុះថ្លៃជាពិសេស, កន្លែងចំណត់ឡាននៅ: Leo Roy Garage, លើផ្លូវ Market Street, ដោយឥតគិតថ្លៃក្នុងឱកាសថ្ងៃបុណ្យនេះ។

ចុងសប្តាហ៏នេះក៏បានកត់សម្គាល់ដោយការចាប់ផ្តើមខ្សែរតន្ត្រីចម្រៀងរដូវក្តៅនៅឱទ្យាន Boardinghouse, ការបើកឆាកពិធីបុណ្យរដូវក្តៅត្រូវបានធ្វើឡើងដោយសាលាក្រុងឡូវែល, ការិយាល័យកិច្ចការវប្បធម៌ និងព្រឹត្តិកាណ៏ពិសេស,សមាគមពាណិជ្ជពាណិជ្ជករនៅប្រជុំជនឡូវែល, សមាគមអ្នកជិតខាងនៃទីប្រជុំជនឡូវែល។

សម្រាប់ព័តិមានលម្អិតពេញលេញ, ចូលមើល: Lowell.org ឬទូរស័ព្ទ (978) 674-4260

# CITY OF LOWELL KICK'S OFF SUMMER

**By Henri Marchand**

Lowell, MA - Friday, June 19 and Saturday, June 20, Lowell will kick off the summer season with a mini-festival in the heart of the downtown, featuring artist booths, children's activities, music, en plein air painters and more. Lowell's favorite 'gator family-Canaligator, Millie-Gator and Allie-Gator-will also be on hand to meet and greet their many fans.

Hours for the event will be Friday from 2 p.m. - 7 p.m. and Saturday from 12 p.m. - 6 p.m. Palmer Street will be closed between Market and Middle and between Middle and Merrimack Streets during the event on both days.

Friday will focus on art and music as some artists set up their booths while others set up their easels. Watch as artists' visions of downtown scenes come alive on their canvasses. Music will flow from participating restaurants.

On Saturday the artists will be joined by staff from the City of Lowell's Recreation Department who will organize games for children and by the Lowell Spinners' colorful and cuddly mascots. Youngsters are invited to display their artistic talents by creating sidewalk chalk art.

"The Summer Kickoff Festival is a great way to begin the season and to showcase all that the City has to offer," said City Manager Kevin Murphy. "With a growing artist community, unique restaurants and family friendly attractions, there certainly is a lot to like about Lowell this summer!"

Food and festivals go hand-in-hand and hungry visitors will have no shortage of options as they enjoy a meal or a snack at one of Lowell's many fine restaurants or pick up locally and organically grown goodies at the Mill City Grows mobile market. Sidewalk sales at participating businesses will offer special deals for shoppers. Parking in the Leo Roy Garage on Market Street will be free during the event.

The weekend also marks the start to the Lowell Summer Music Series at Boardinghouse Park.

The Summer Kickoff Festival is made possible by the City of Lowell, The Lowell Office of Cultural Affairs and Special Events, Downtown Lowell Merchant's Association, Lowell Downtown Neighborhood Association and Made in Lowell. For complete details, visit Lowell.org or call (978) 674-4260.

ការិយាល័យ មេធាវី
ចំមាស ស្តាលីយ៉ាណូស
Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852
- Immigration •អន្តោប្រវេសន៏
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ
សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766

adventures await
Greater Merrimack Valley
Convention & Visitors Bureau
For more fun things to see & do
and great places to eat & stay, visit...
www.merrimackvalley.org

ទោង ជាង ចេនា



LEGEND

## AUTO BODY INC.

(978) 458-2085

**Services**

- Auto Body
- Auto Mechanics
- Foreign and Domestics
- State and Insurance Certified

Towing - **978-815-9957** (K.C)

**មានបម្រើ**

- ជួសម៉ាស៊ីនយានយន្ត
- ប្រភេទយានយន្តក្នុង និងក្រៅប្រទេស

**តួយានយន្ត**

- បញ្ជាក់ប័ណ្ណធានារ៉ាប់រងទទួលស្គាល់ដោយរដ្ឋ

**ដឹកឡានត្រូវចូវ** 978-815-9957 (**ខេ-ស៊ី**)



**115 Rock St. Unt #7 Lowell, MA 01854**



## U-SAVE

CAR & TRUCK RENTAL®

Car & Truck Rental

DCR Enterprises, Inc.

U-Save Auto Rental

1625 Middlesex Street / Lowell, MA 01851

978-453-2000

**រថយន្ត & និងឡានដឹកឥវ៉ាន់សម្រាប់ជួល**

- Cars
- SUV's
- Passenger Vans
- Insurance Replacement

- រថយន្ត
- រថយន្តស៊ុយវីស៍
- រដយន្តដឹកភ្ញៀវ
- ផ្លាស់ប្តូរការធានារ៉ាប់រង



Free Pick Up: ទៅទទួលលោកអ្នកឥតគិតថ្លៃ

ទូរស័ព្ទលេខ: 978-453-2000



# GATEWAY FAMILY DENTAL

www.gatewayfamilydental.com • **(978) 455-5044**

**151 WARREN STREET, SUITE 120 LOWELL, MA 01852 (Same building as Social Security/near the courthouse)**



**DR. SERENA B. CHUOP**

Dr. Serena B. Chuop was born in Cambodia. She received her Bachelor of Science from Boston University and went on to graduate from Boston University Goldman School of Dental Medicine in the year 2000. For over 13 years, she has been in private practices providing all aspects of General Dentistry. Her state of the art dental practice includes digital x-rays, paperless patient chart system, and new dental equipments.



**WE PROVIDE ALL SERVICES INCLUDING: យើងផ្តល់នូវសេវាដូចខាងក្រោមនេះ**

- CLEANING
- FILLINGS
- BONDINGS
- COSMETIC DENTISTRY
- CROWNS/BRIDGES
- DENTURES
- IMPLANTS
- EXTRACTIONS
- TEETH WHITENING
- VENEERS
- EMERGENCY DENTAL TREATMENT
- ROOT CANAL TREATMENT
- DENTAL SERVICES TO CHILDREN

- សំអាតធ្មេញ
- បំពេញធ្មេញប្រហោង
- ថ្នាំសំរាប់ការពារធ្មេញ
- ធ្មេញពាក់ជុំនួសធ្មេញដែលបាក់
- ក្រាសធ្មេញពាក់
- ដាំធ្មេញតាមរន្ធធ្មេញចាស់
- ដកធ្មេញ
- ធ្វើធ្មេញឱ្យសស្អាត
- វីវនីស្រោបធ្មេញ
- ព្យាបាល និងការពារធ្មេញជាទៀងទាត់
- ព្យាបាល ឫសថ្គាមធ្មេញ
- សេវាព្យាបាលសំរាប់កុមារ

Free Teeth Whitening Kit

(with new patient´s x-ray, exam, cleaning at regular price)

**MOST DENTAL INSURANCES ACCEPTED**

**INCLUDING MASSHEALTH**

**FINANCING AVALIABLE**

**យើងទទួលនូវគ្រប់ អ៊ិន ស៊ូរិន**

**Masshealth**

**យើងសំរួលការបង់ថ្លៃព្យាបាលប្រចាំខែ**

**CALL FOR YOUR FREE CONSULTATION**

**(978) 455-5044**

## តមកទំព័រទី ០១ កសាងជំនឿឡើងវិញ

គណបក្សសង្គ្រោះជាតិនៅមានកម្លាំងនឹងឈ្នះឆ្នោតនៅឡើយ ។ សូមអញ្ជើញអានអត្ថបទដកស្រង់សង្ខេបជាភាសាអង់គ្លេសដូចខាងក្រោមនេះ :

May 30th, 2015

# • Rebuilding Trust

**By Vibol Touch and Sophal Sam**

The enigmatic deal between CNRP President Sam Rainsy and Cambodian Prime Minister Hun

Sen on July 22nd, 2014 to end the political deadlock following the July 2013 national election

has been perceived by most Cambodians as a betrayal to the voters who were so certain that Hun

Sen had lost that election. It is generally held that the recent so-called "culture of dialogue" is

largely viewed more as a political plot than a fundamental reform for Cambodia…

The disenchantment among the Cambodian people was motivated by the CNRP top leaders who

promised them justice and pledged to honor their will, but failed miserably to deliver. The voters

accused them of violating the principles of democracy and neglecting the existential issues, such

as economic land concessions, land disputes, corrupt justice system, and the threat of Vietnam's

expansionism. First and foremost, the people's concerns need to be fully understood and dealt

with in a serious and transparent manner.

People's main concerns:

• Politicians have violated the principles of democracy. Politicians broke their promises to

uphold the people's will and did not ask the people to weigh in on major and significant

political deals between parties.

• Elected officials have been known for their irresponsibility and non-responsiveness to the

current growing issues, such as inflationary food prices, land grab, deforestation,

economic land concessions, corruption, etc.

• Cambodia most likely will become another Laos where Vietnamese nationals have

become the leaders controlling every level of the Lao government.

• The Cambodian government's incompetency in dealing with Vietnam's expansionist

policies that run counter to the interest and well-being of Cambodia and the Cambodian

people, such as the unchecked influx of illegal Vietnamese immigrants granted with

illegal voting rights.

• The National Election Committee (NEC) is not independent and the electoral process

would never be transparent as it is still controlled by the Cambodian government.

Without any doubt, the disenchantment among the Cambodian voters and activists is due to the

lack of strong CNRP leadership and the CNRP leaders' failure to live up to their commitment to

the people. …

However, all is not lost and there is still hope. On the flip side, by comparison to other political

parties, the CNRP has the most compassionate and intellectual human resources with a lot of

supporters putting in considerable volunteering time in hope of seeing real change. This attribute

alone cannot be dismissed and overlooked. It's a matter of rebuilding trust as follow:

1. Reforming and strengthening the party structures:…

2. Rebuilding trust with overseas supporters and the Cambodian people:

a. The CNRP leaders must put out a clear vision for Cambodia in contrast with that of the

CPP's and consistently take actions in line with this vision.

b. The CNRP must demonstrate that the CNRP is responsible and capable of holding itself

(i.e. each other) accountable for its actions.

c. The CNRP must demonstrate strong commitments to the Cambodian people. Every **Continued to page 19**


វិធីព្យាបាលដោយកាយវប្បកម្មនៅមេរីម៉ែក-វ៉ាលី, និងនៅ វូបឿន

Merrimack Valley Physical Therapy And

Physical Therapy of Woburn

**Mission Statement:** សេចក្ដីថ្លែងការអំពីគោលបំណង

ផ្ដល់គុណភាពក្នុងការថែរក្សាសុខភាព, ធ្វើឲ្យមានសុខភាពប្រសើរឡើង និងដំណើរជីវិតឲ្យមានភាពសកម្មជាងមុន, យើងមានជើថាការជំជួយដល់មនុស្សឲ្យមានរាងកាយនិងស្មារតីមាំមួនតាមរយះការព្យាបាលធ្វើលំហាត់ប្រាណ,និងជួយដល់អ្នកជម្ងឺបានជាសះស្បើយឡើងវិញបាន.

To provide quality health care in order to promote healthier and more active lifestyles. We believe in helping people strengthen their bodies and minds through therapeutic exercise and helping people recover from injuries.

- Back Issue Program :ការបញ្ចេញកម្មវិធីផ្នែកខាងក្រោយ
- Pre-natal Program :កម្មវិធីមុនកំណើតកូន
- Pre and Post-Operative Care :ថែទាំមុននិងក្រោយពេលព្យាបាលជម្ងឺ
- Injuries dues to auto accident :របួសមកពីគ្រោះថ្នាក់ពីរថយន្ត
- Worker's Compensation Claims :ទាមទារសំណងសម្រាប់អ្នកពលកម្ម
- Slips and Falls :រំអិលដួល
- Sport Injuries :របួសកីឡា
- Experience in documentation for litigation purposes :បទពិសោធន៍ឯកសារមានប្រយោជន៍ក្នុងការវិវាទ
- Translations in Khmer and Vietnamese now available:មានការបកប្រែជាភាសាខ្មែរនិងវៀត-ណាម

សូមទាក់ទងនិង:សេរីណា វ៉ាន-យ៉ាញ, ទូរស័ព្ទលេខ:៩៧៨-៥៦៩-៣១២០,Contact Serina Van-Danh at 978-569-3120,

ការណាត់ជួបជាមួយយើងខ្ញុំតាមរយះអាសយដ្ឋាន២កន្លែងខាងក្រោម៖

To schedule an appointment, please contact us at one of our 2 locations:

Lawrence :
225 Essex St. Unit 1E
Lawrence, MA 01840
Tel: 978-208-0402/978-258-2908

Woburn :
00 West Cummings Park, Suite 1400
Woburn, MA 01801
Tel: 781-938-1223

# ក្បួនដំណើរនៅឡូវែល

**ដោយលោក រីឆឹត ហាវ Jr.**
**ប្រែសម្រួលដោយ ថាច់ វណ្ណា**


Richard Howe

ក្បួនដំណើរឡូវែលសំដៅទៅដំណើរទេសចរណ៏ជាក្រុមដើរទៅក្នុងទិប្រជុំជនក្រុងឡូវែលនៅព្រឹកថ្ងៃសៅរ៍នារដូវក្តៅនេះ។ ដំណើរទស្សនកិច្ចនីមួយៗមានប្រធានបទផ្សេងគ្នាដែលដឹកនាំដោយអ្នកនាំភ្ញៀវស្ម័គ្រចិត្តផ្សេងៗគ្នា។ ដំណើរទេសចរណ៏ទាំងអស់ចាប់ផ្តើមនៅម៉ោង ១០:00 A.M. ពីមជ្ឈមណ្ឌលឧទ្យានប្រវត្តិសាស្រ្តជាតិនៅឡូវែល, លេខ២៤៦ ផ្លូវ Market Street ក្នុងក្រុងឡូវែល, គោលបំណងនៃក្បួនយាត្រានេះដើម្បីដើរចែករំលែកប្រវត្តិសាស្រ្តនិងវប្បធម៌នៃទីក្រុងឡូវែល។ ក្នុងខណៈពេលនេះដែរ ក៏បាននាំយកមនុស្សជាច្រើនទៀត ចូលទៅក្នុងទិប្រជុំជននៅថ្ងៃសៅរ៍, ដូច្នេះពួកគេក៏អាចទទួលទានអាហារឬទិញឥវ៉ាន់តាមហាង។ ដំណើរទេសចរណ៏នេះឥតគិតថ្លៃ, ហើយមិនតម្រូវឱ្យមានការចុះឈ្មោះជាមុនឡើយ។

នៅក្នុងសរទរដូវនិងនិទាឃរដូវយើងសង្ឃឹមថា និងរៀបចំក្បួនដំណើរក្រុងឡូវែល និងដំបន់ជិតខាង, ជាឧទាហរណ៏: ធ្វើដំណើរផ្តោតទៅលើតំបន់ដែលគ្រប់គ្រងដោយអាស៊ានអជីវកម្ម, 



អាច និងចាប់ផ្តើមពី Cupples Square និងបញ្ចប់នៅទីប្រជុំជនប៉ៃលិនផ្លាហ្សា។

ដំណើរទស្សនកិច្ចលើកដំបូងត្រូវបានប្រារព្ធឡើងនៅថ្ងៃទី៦ ខែមិថុនាឆ្នាំ ២០១៥, ប្រធានបទនេះ **តទៅទំព័រទី ២១**

# Lowell Walks

**By Richard P. Howe Jr.**

Lowell Walks is a series of guided walking tours of downtown Lowell on Saturday mornings throughout the summer. Each tour has a different topic led by a different volunteer tour guide. All tours begin at 10:00 A.M. from the Lowell National Historical Park Visitor Center at 246 Market Street in Lowell. The purpose of Lowell Walks is to share the history and culture of Lowell while at the same time bringing more people into the downtown on Saturdays so they can also dine or shop. The tours are free and require not advance registration.

In the fall and spring, we hope to organize other Lowell Walks in the city's neighborhoods. For example, a great walk that focused on Asian-owned businesses might start at Cupples Square and end at Pailin Plaza.

The first Lowell Walks tour was held on June 6, 2015. The topic was Preservation Success Stories. The tour guide, Fred Faust, showed examples of many buildings in downtown that have been preserved through the years and that now look as beautiful as the day they were built. The second tour, on June 13, 2015, explored the city's downtown Public Art Collection of outdoor sculptures.

June 20, 2015 - Inside Lowell High School with Brian Martin

June 27, 2015 - Literary Lowell and the Pollard Memorial Library

July 4, 2015 - Independence Day - NO TOUR

July 11, 2015 - The Irish and the Acre

July 18, 2015 - Green Lowell (Energy efficient buildings)

**Continued to Page 21**


**យើងខ្ញុំយកចិត្តទុកដាក់ដើម្បីឲ្យលោកអ្នកញញឹម។**
***លោកអ្នកទទួលបានសេវាកម្មទន្តពេទ្យដោយមិនបង់ប្រាក់!***



លោកអ្នកទទួលបានអត្ថប្រយោជន៍ទាំងអស់របស់លោកអ្នកនៅក្នុងកម្មវិធីស្តង់ដារ **MassHealth** និងកម្មវិធី **Medicare** រួមទាំងសេវាកម្មជាច្រើនទៀត។

- លោកអ្នកទទួលបានសេវាកម្មទន្តពេទ្យដោយមិនបង់ប្រាក់ ដែលរួមមាន៖ *
  - **ពិគ្រោះយោបល់នៅការិយាល័យ និងសម្អាតធ្មេញ**
  - **ដាក់ក្រាសធ្មេញទាំងមូលនិងដោយផ្នែក**
  - **ប៉ះធ្មេញ**
  - **ដាំធ្មេញ**
- ចំណាយបដិភាគ $0 សម្រាប់គ្រប់សេវាកម្ម
- ប័ណ្ណ លោកអ្នកមានសុខភាពល្អ សម្រាប់ទិញទំនិញពាក់ព័ន្ធនឹងសុខភាពដែលមិនមានវេជ្ជបញ្ជា (រហូតដល់ $140ក្នុងមួយឆ្នាំ / $35 ក្នុងមួយត្រីមាស) *
- សេវាកម្មដឹកសមាជិកទៅកាន់និងមកពីកន្លែងណាត់ជួប *
- អាចហៅទូរស័ព្ទទៅកាន់សមាជិកក្រុមការងារនៃគម្រោង SWH បាន 24/7



SENIOR WHOLE HEALTH®
**Simple. Secure. Independent.**

សម្រាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទទៅ:
**1-888-566-3526**(ខ្សែទូរស័ព្ទឥតគិតថ្លៃ) **TTY/TDD:711**
**www.seniorwholehealth.com/SNP**
យើងខ្ញុំបើកដំណើរការចាប់ពីម៉ោង 8 ព្រឹកដល់ម៉ោង 8 យប់ ប្រាំពីរ (7) ថ្ងៃក្នុងមួយសប្តាហ៍។

ប្រសិនបើលោកអ្នកមានសេវាកម្មធានារ៉ាប់រងក្នុងកម្មវិធីស្តង់ដារ MassHealth ក៏ប៉ុន្តែមិនមានសេវាកម្មធានារ៉ាប់រងក្នុងកម្មវិធី Medicare ផ្នែក A និង/ឬក៏ផ្នែក B លោកអ្នកប្រហែលជា អាចចុះឈ្មោះនៅក្នុងកម្មវិធីជម្រើសថែទាំសុខភាពមនុស្សចាស់ MassHealth Senior Care Options (SCO) របស់យើងខ្ញុំបាន។
លោកអ្នកដែលឆ្លើយតបទៅនឹងលក្ខខណ្ឌខាងលើអាចចុះឈ្មោះបានគ្រប់ពេលវេលារៀងរាល់ឆ្នាំ។

** លក្ខខណ្ឌកំណត់អាចត្រូវបានអនុវត្ត*

គម្រោងសុខភាពទាំងមូលរបស់មនុស្សចាស់ គឺជាគម្រោងថែទាំសុខភាព HMO SNP ដែលមានការសម្របសម្រួល និងកិច្ចសន្យាផ្តល់- ទទួលសេវាកម្មនៃកម្មវិធី Medicare និងកិច្ចសន្យាជាមួយ Commonwealth of Massachusetts/កម្មវិធី EOHHS MassHealth។ ការចុះឈ្មោះធ្វើឡើងដោយស្ម័គ្រចិត្ត និងអាស្រ័យទៅលើការបន្តកិច្ចសន្យាប្រចាំឆ្នាំ។ ព័ត៌មានអំពីអត្ថប្រយោជន៍នៅក្នុងឯកសារនេះ គឺជាសេចក្តីសង្ខេបមួយ មិនមែនជាសេចក្តីពិពណ៌នាលម្អិតអំពីអត្ថប្រយោជន៍ទេ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងការិយាល័យគម្រោង។ លក្ខខណ្ឌកំណត់ ប្រាក់បដិភាគ ឬក៏លក្ខខណ្ឌកម្រិតផ្សេងៗទៀតអាចត្រូវបានអនុវត្ត។អត្ថប្រយោជន៍ រូបមន្ត បណ្តាញអ្នកផ្តល់សេវាកម្ម និងបណ្តាញឱសថស្ថាន អាចត្រូវបានផ្លាស់ប្តូរនៅថ្ងៃទី 1 ខែមករា នៃឆ្នាំនីមួយៗ។ លោកអ្នកត្រូវតែបន្តបង់បុព្វលាភផ្នែក B របស់លោកអ្នក ប្រសិនបើបុព្វលាភនោះមិនកំពុងត្រូវបានបង់ដោយភាគីណាមួយផ្សេងទៀតនៅឡើយទេ។ គម្រោងនេះត្រូវបានបង្កើតឡើងសម្រាប់មនុស្សដែលមានអាយុចាប់ពី 65 ឆ្នាំឡើងទៅ ដែលមានជំនួយវេជ្ជសាស្រ្តដែលទទួលបានទាំងពីរដ្ឋ និងកម្មវិធី Medicare។
H2224_2015_104kh Accepted 12/7/2014

**KHMERS KAMPUCHEA-KROM FEDERATION**
Asia – Australia – Europe – North America
P.O. Box 0193 • Pennsauken • NJ • 08110 • U.S.A.
Tel: (856) 655-3838 • Fax: (856) 583-1503
www.khmerkrom.net / www.khmerkrom.org • Email: giap.tran@khmerkrom.org

# ពិធីខួប ៦៦ ឆ្នាំ នៃ ទិវា ៤ មិថុនា

## នឹង កម្មវិធីសហព័ន្ធខ្មែរកម្ពុជាក្រោម

យើងខ្ញុំជាគណៈកម្មការសហព័ន្ធខ្មែរកម្ពុជាក្រោម នាតំបន់ **ញូអិងក្លែង** New England បានមូលមតិរួបរួមគ្នានឹង ប្រារព្ធខួប ៦៦ ឆ្នាំ នៃ “ទិវា ៤ មិថុនា” ឬ “ទិវាកម្ពុជាក្រោម ឋិតនៅក្រោមអាណានិគមយួន” នៅក្នុងខែមិថុនានេះ ដើម្បីរំឭកដល់ ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏ ឈឺចាប់ របស់ខ្លួន ដែលបារាំងបានផ្ទេរដែនដីកម្ពុជាក្រោម ឬ ដែនដីកូស័ងស៊ីន ឲ្យឋិតនៅក្រោមរដ្ឋអំណាច យួន កាលពី ថ្ងៃ ទី ៤ ខែ មិថុនា ឆ្នាំ១៩៤៩ ។

## កម្មវិធីបុណ្យ

ថ្ងៃ សៅរ៍ ទី ២០ ខែ មិថុនា ឆ្នាំ ២០១៥ (Saturday June 20, 2015)

- ម៉ោង ៨ - ១០ : ប្រគេនយាគូរព្រះសង្ឃ - នមស្សការសមាទានសីល
- ម៉ោង ១១ : វេរភត្តាហារប្រគេនព្រះសង្ឃ - ដារបង្សុកូល
- ម៉ោង ១២ : ពុទ្ធបរិស័ទជិតឆ្ងាយទទួលភោជនាហារ
- ម៉ោង ១-៣ : ពិធីខួប ៦៦ ឆ្នាំ នៃ ទិវា ៤ មិថុនា<br>នឹង កម្មវិធីសហព័ន្ធខ្មែរកម្ពុជាក្រោម
- ម៉ោង **៦-១២** : មាន **តូរ្ត្រី** លេង កំសាន្តរហូតដល់ ម៉ោង ១២ អាធ្រាត ។

អាស្រ័យដូចបានជំរាបខាងលើនេះ គណៈកម្មការយើងខ្ញុំ សូមអញ្ជើញ អស់លោក-លោកស្រី អ្នកនាងកញ្ញា កុមារាកុមារី ពុទ្ធបរិស័ទជិតឆ្ងាយទាំងអស់ មកចូលរួមជាមួយយើងខ្ញុំ អោយបានច្រើនកុះករ ។ គណៈកម្មការសហព័ន្ធ យើងខ្ញុំ សូមប្រសិទ្ធិពរ ឆ្នាំថ្មី អោយជួបតែសេចក្តីសុខចំរើនតរៀងទៅ កុំបីឃ្លៀងឃ្លាតឡើយ ។

ថ្ងៃ ទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥
គណៈកម្មការសហព័ន្ធ
Vuth Ly

**Sompao Meas Hall**
450 Chelmsford Street
Lowell, MA 01851
Tel: (978) 421-5246 or (978) 421-5256

**For more information call:**

| New England Representatives | Springfield, MA | Worcester, MA | Lowell, MA | Lynn, MA | Rhode Island |
|---|---|---|---|---|---|
| Vanna Ly (603) 560-2721 | Many Ngoc Son (My) | Samith Thach | Bopea Sok | Trung Kim (Phorn) | Hui Ly |
| Vuth Ly (774) 329-6484 | (413) 364-9202 | (508) 791-5198 | (978) 551-1109 | (781) 244-8418 | (401) 256-9356 |

## Neighborhood Physical Therapy




337 Westford Street. Lowell, MA 01851

978-455-4320

- Auto Accident Injuries
- Work Injuries
- We provide transportation

- គ្រោះថ្នាក់ចរាចរណ៍
- គ្រោះថ្នាក់នៅកន្លែងធ្វើការ
- យើងខ្ញុំមានផ្តល់ការជញ្ជូន សម្រាប់លោកអ្នក

## សាលាថែទាំកុមារឡូវែល

LOWELL DAY NURSERY ASSOCIATION

119 HALL STREET
LOWELL, MASS.01854
978-454-5981

- កំពុងបើកទទួលសិស្សានុសិស្សកុមារ អាយុ១៥ខែ រហូតដល់២ឆ្នាំ៩ខែ
- សាលាមុនថ្នាក់មតេយ្យ
- មានបុគ្គលិកប្រកបគរុកោសល្យល្អ
- ជាសាលាល្អចំណាត់ថ្នាក់ប្រចាំឆ្នាំ

- OPENINGS AVAILABLE! TODDLERS -15 MONTHS THRU 2YEARS 9 MONTHS
- PRESCHOOL AND KINDERGARTEN
- GREAT CURRICULUM WITH SEASONED STAFF
- NATIONAL DIRECTOR OF THE YEAR

www.lowelldaynursery.com
or Like us on Facebook – Lowell Day Nursery Association





## វិជ្ជាស្ថានរៀន ថែសម្ផស្សមុខនិងត្រចក

ទើបបើកថ្មី

## Chelmsford Beauty Academy

60 Chelmsford St.,2nd Floor Chelmsford, MA. 01824
Tel: (978)328-9722 ឬ (978) 250-4488





- យើងខ្ញុំបានបើកវគ្គបង្រៀនធ្វើត្រចក និងថែសម្ផស្សមុខ គ្រូបង្ហាត់ មានការដកពិសោធន៍ច្រើនឆ្នាំ មានថ្នាក់រៀនក្រៅម៉ោង និងពេញម៉ោង្ឋ៧ថ្ងៃក្នុង១សប្តាហ៍
- យើងខ្ញុំបើកវគ្គសិក្សា៣០០ម៉ោង សម្រាប់ថ្នាក់ថែសម្ផស្សមុខ និងវគ្គ ១០០ម៉ោង
- សម្រាប់ថ្នាក់ធ្វើត្រចក ។
- សូមចុះឈ្មោះជាប្រញាប់ !

ជួយណែនាំរកការងារធ្វើ ពេលចប់ការសិក្សា

Chelmsford Beauty Academy មានចម្ងាយ៥នាទីពីក្រុង Lowell, និង១៥នាទីពីក្រុង Lawrence, ចម្ងាយ១០នាទីពី Burlington Mall, និង១០នាទី Andover.

ព័ត៌បន្ថែមទាក់ទងជាមួយយើងខ្ញុំថ្ងៃនេះតាមទូរស័ព្ទលេខ : (978)328-9722 ឬលេខ : (978)250-4488

ឌី ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសំរួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌី ខេមបូឌា ដេលី

តមកទំព័រទី ០៣

## សិក្ខាសាលាគណបក្សសង្គ្រោះជាតិ

បានល្អប្រសើរជាងមុនតើគេធ្វើដូចម្ដេចទើបអាចធ្វើបាន? យើងធ្វើដូម្ដេច ទើបបានជ្រើសរើសមនុស្សឱ្យកាន់តែច្រើន? ធ្វើរបៀបណាទើបប្រមូលថវិការជួយគណបក្សឱ្យកាន់តែបានច្រើនបន្ថែមទៀត?...វគ្គបណ្ដុះបណ្ដាលនេះផ្ដោតទៅលើរបៀបស្វែងរកសមាជិក ដើម្បីឱ្យអ្នកដទៃទៀត មកចូលរួមក្នុងសកម្មភាពរបស់អ្នក។ យើងបានស្វែងរកអំពីរបៀបភ្ជាប់ទំនាក់ទំនងជាមួយអ្នកដទៃពីការកសាងទំនាក់ទំនងរឹងមាំដោយការជឿទុកចិត្តលើក្រុមយើង ដើម្បីឱ្យអ្នកដទៃយល់ថា ហេតុអ្វីបានជាអ្នកត្រូវបានអញ្ជើញឱ្យមកធ្វើការងារនេះ, និងដើម្បីឱ្យមានការរំភើបទៅចូលរួមជាមួយពួកយើង។ បច្ចេកទេសទាំងនេះត្រូវបានបង្កើតឡើងក្នុងអំឡុងពេលដែលចលនាសិទ្ធិស៊ីវិល-អាមេរិក និងបានសម្រិតសម្រាំងដោយសាស្ត្រាចារ្យមហាវិទ្យាល័យ Harvard និងជាអ្នករៀបចំសហគមន៍, ចូលទៅក្នុងការបណ្ដុះបណ្ដាលដែលត្រូវបានបង្រៀនឱ្យសកម្មជនទាំងអស់នៅលើពិភពលោករួមទាំងនៅកម្ពុជាផងដែរ។

សិក្ខាកាមនៅពេលបញ្ចប់វគ្គសិក្សា២ថ្ងៃបានសម្ដែងនូវការពេញចិត្តនឹងអរគុណក្រៃលែងចំពោះគ្រូបង្ហាត់ទាំង២រូប នូវចំណេះថ្មីដែលគេ





និយាយថា ងាយស្រួលយល់ជាពិសេសធ្វើឱ្យមានការចាប់អារម្មណ៍ ថាវានឹងមានប្រយោជន៏សម្រាប់ការងារបំរើនយោបាយប្រកបដោយក្ដីសង្ឃឹមបាន ។

បច្ចុប្បន្ននេះការVoopបម្រើការងារជានាយកប្រតិបត្តិបណ្ដោះអាសន្ននៃសមាគមជំនួយទៅវិញទៅមករវាងប្រទេសកម្ពុជានឹងឡូវែលរដ្ឋម៉ាសាឈូសិត ៕

Continued from page 03

## CNRP Workshop Leadership

she was first an undergraduate, then a researcher, then a Masters student and Teaching Fellow for numerous leadership and management courses. She was awarded the Dean's Award for Excellence in Student Teaching.

Voop's depth of knowledge was enriched by her four years workingin Cambodia. During her time there, she worked extensively withthe US Agency for International Development, the United Nations, and prominent non-profits in the fields of HIV/AIDS, rule of law, and human rights.




Recently, Voop served as Interim Executive Director of the Cambodian Mutual Assistance Association in Lowell, MA. There, she had a transformative impact: reinvigorating staff, recruiting a large volunteer corps, launching income-generating programs and bringing the organization to financial health.

Attachments area

Preview attachment SokPaul Pen.png

SokPaul Pen.png

6.6 MB

## ជនភៀសខ្លួនក្រុមដំបូងមកពីប្រទេសណូរូ បានមក់ដល់កម្ពុជាហើយ

**ដោយ អូន ភាព និង ហ្សមប៊រ ភីធើរ** | **June 5, 2015**

បន្ទាប់ពីការចរចាដ៏គួរឱ្យព្រួយបារម្ភ និងការរៀបផែនការសម្ងាត់ជាមួយកម្ពុជាអស់រយៈពេលជាច្រើនខែរួចមកប្រទេសអូស្ត្រាលីបានបញ្ជូនជនភៀសខ្លួនចំនួនបួននាក់ដំបូងមកកាន់រាជធានីភ្នំពេញកាលពីម្សិលមិញ ក្រោមកិច្ចព្រមព្រៀងដ៏ចម្រូងចម្រាសមួយដែលនឹងអាចបញ្ជូនជនភៀសខ្លួនរាប់សិប និងរាប់រយនាក់បន្ថែមទៀតមកកាន់កម្ពុជា។

ជនជាតិអ៊ីរ៉ង់ចំនួនបីនាក់ និងបុសជនជាតិរ៉ូហ៊ីងយ៉ាម្នាក់មកពីប្រទេសភូមាបានមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញតាមរយៈជើងហោះហើរពេលព្រឹករបស់ក្រុមហ៊ុនអាកាសចរណ៍ Malaysia Airlines ហើយត្រូវបានគេនាំចូលក្នុងរថយន្តមួយគ្រឿងដែលកំពុងតែរង់ចាំដោយមានបាំងវាំងនន និងដែលក្រោយមកបានដឹកពួកគេទៅកាន់ផ្ទះថ្មីនៅក្នុងខណ្ឌច្បារអំពៅភាគខាងត្បូងរាជធានីភ្នំពេញ។

ភូមិគ្រឹះដ៏ធំទូលាយ និងដែលមានរបងហ៊ុមព័ទ្ធត្រូវបានរៀបចំសម្រាប់ជនភៀសខ្លួនទាំងនេះដោយអង្គការអន្តរជាតិទេសន្តប្រវេសន៏ (IOM) ដែលកំពុងជួយក្នុងការតាំងទីលំនៅថ្មីសម្រាប់ជនភៀសខ្លួន។



បុរសរ៉ូហ៊ីងយ៉ាយកដៃបិទមុខ ក្នុងខណៈដែលគាត់ចាកចេញពីព្រលានយន្តហោះអន្តរជាតិភ្នំពេញ កាលពីម្សិលមិញ បន្ទាប់ពីមកដល់ជាមួយជនភៀសខ្លួនបីនាក់ទៀតដែលបានយល់ព្រមមកតាំងលំនៅនៅប្រទេសកម្ពុជា ជាផ្នែកមួយ នៃកិច្ចព្រមព្រៀងដ៏ចម្រូង ចម្រាសដែលរដ្ឋាភិបាលបានចុះហត្ថលេខាជាមួយប្រទេសអូស្ត្រាលីកាលពីខែកញ្ញា។ រូបថត: ស៊ីវ ចាន់ណា,The Cambodia Daily

អង្គការនេះបានលើកឡើងនៅក្នុងសេចក្ដីថ្លែងការណ៏មួយថា "ក្រុមជនភៀសខ្លួននេះ ត្រូវបានបញ្ជូនទៅ **តទៅទំព័រទី ១៧**

## First Refugees From Nauru Arrive in Cambodia

**BY ZSOMBOR PETER AND AUN PHEAP | JUNE 5, 2015**

After months of fraught negotiations and secretive planning with Cambodia, Australia on Thursday flew the first four refugees into Phnom Penh under a highly controversial deal that could bring dozens-or hundreds-more in their wake.

Three Iranians and a Rohingya man from Burma landed at Phnom Penh International Airport on the morning's sole Malaysia Airlines flight and were escorted into a waiting van with drawn curtains that whisked them to their new home in the city's southern ChbarAmpov district.

The spacious, gated villa was arranged for them by the International Organization for Migration (IOM), which is helping with the resettlements.

"The group [was] transferred to temporary accommodation in Phnom?Penh, where IOM will begin to provide essential support, including language training, cultural and social orientation, education services, health services and employment services," the organization said in a statement.

Only weeks ago, the four were among hundreds of refugees Australia is holding in camps on the South Pacific island of Nauru, having caught them trying to reach its shores.

Under a tough new immigration policy, Australia is **Continued to Page 17**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណើរប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# សហប្រជាជាតិប្រាប់ក្រុមហ៊ុនក្នុងស្រុកថា យើងចង់បានមុខជំនួញរបស់អ្នក

**ដោយ កង សុធា និង គ្រិស ម៉ូល្សឺរ** |

**JUNE 5, 2015**

បេសកកម្មអ៊ុនតាក់អស់ប្រាក់១,៦ពាន់លានដុល្លារនាដើមទសវត្សរ៍ឆ្នាំ១៩៩០បានចាក់បញ្ចូលប្រាក់ដ៏ច្រើនទៅក្នុងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។ ឥឡូវនេះ អង្គការសហប្រជាជាតិចង់ដាក់បញ្ចូលរាប់លានដុល្លារទៀតមកក្នុងប្រទេសនេះ គឺលើកនេះដោយការទិញយកសេវាកម្មរបស់ក្រុមហ៊ុនក្នុងស្រុក។

ក្នុងសិក្ខាសាលានៅក្រសួងពាណិជ្ជកម្មកាលពីថ្ងៃព្រហស្បតិ៍តំណាងអង្គការសហប្រជាជាតិជាច្រើនរូបបានពន្យល់ប្រាប់ដោយសង្ខេបដល់ម្ចាស់ជំនួញកម្ពុជាប្រហែល៣០នាក់ អំពីរបៀបដែលពួកគេអាចរកប្រាក់បានរាប់លានដុល្លារ ដោយការលក់ផលិតផល ឬសេវារបស់ខ្លួនឱ្យទីភ្នាក់ងារអង្គការសហប្រជាជាតិនៅក្នុងប្រទេសកម្ពុជា និងនៅជុំវិញពិភពលោក។

លោក ឌីមីទ្រី ដូវហ្គោប៉ូលី (Dmitri Dovgopoly) នាយកផ្នែកលទ្ធកម្មរបស់អង្គការសហប្រជាជាតិបាននិយាយថា "ទំហំសរុបនៃទីផ្សាររបស់អង្គការសហប្រជាជាតិមានរវាង១៦ពាន់លានដុល្លារទៅ១៧ពាន់លានដុល្លារនៅទូទាំងពិភពលោកជារៀងរាល់ឆ្នាំ"។

ទោះជាមានសក្តានុពលរកចំណេញបានច្រើនតាមរយៈការលក់ទៅឱ្យអង្គការសហប្រជាជាតិក៏ដោយក៏លោក ដូវហ្គោប៉ូលី បាននិយាយថា នៅឆ្នាំ២០១៣ពាណិជ្ជកម្មកម្ពុជាបានលក់ទំនិញ និងសេវាមានត្រឹមតែ២៤,៦លានដុល្លារប៉ុណ្ណោះឱ្យអង្គការសហប្រជាជាតិ។ យោងតាមធនាគារពិភពលោកបានឱ្យដឹងថា នៅឆ្នាំដដែលនោះ ប្រទេសអាហ្វហ្គានីស្ថានដែលមានផលិតផលក្នុងស្រុកសរុប២៥ភាគរយច្រើនជាងផលិតផលសរុបក្នុងស្រុករបស់ប្រទេសកម្ពុជារកបាន៧០០,៩លានដុល្លារពីកិច្ចសន្យាអង្គការសហប្រជាជាតិ។

លោក ដូវហ្គោប៉ូលី បាននិយាយថា "យើងធ្វើជំនួញតិចតួចណាស់ក្នុងប្រទេសកម្ពុជាដោយសារកង្វះចំណេះដឹងក្នុងចំណោមសហគមន៍ជំនួញក្នុងស្រុកអំពីឱកាសធ្វើជំនួញដែលយើងអាចផ្តល់ឱ្យ"។

យោងតាមរបាយការណ៍លទ្ធកម្មឆ្នាំ២០១៣របស់អង្គការសហប្រជាជាតិបានឱ្យដឹងថា ប្រទេសកម្ពុជាលក់ទំនិញរាប់សិបមុខទៅឱ្យអង្គការសហប្រជាជាតិមានចាប់ពីឧបករណ៍ពេទ្យ និងម៉ូតូរហូតដល់សម្ភារការិយាល័យនិងឯកសណ្ឋាន។ ប្រទេសកម្ពុជាក៏ផ្តល់សេវាមួយចំនួនដែរ មានដូចជាភ្នាក់ងារអចលនទ្រព្យនិងសេវាបោះពុម្ព។

លោក ដូវហ្គោប៉ូលី បានបន្ថែមថា ទន្ទឹមនឹងមានតែក្រុមហ៊ុនកម្ពុជាប្រហែល១០០ប៉ុណ្ណោះលក់ទៅឱ្យអង្គការសហប្រជាជាតិនោះ លោកជឿថា ក្រុមហ៊ុនក្នុងស្រុកមានលទ្ធភាពច្រើនផ្តល់ឱ្យខ្លួនមិនមែនផ្តល់តែផលិតផលប៉ុណ្ណោះទេ ក៏ប៉ុន្តែមានសេវាផងដែរ។ លោកបានមានប្រសាសន៍ថា "ខ្ញុំគិតថា ប្រទេសកម្ពុជាមានសក្តានុពលច្រើន"។

លោក នួន រតនា សមាជិកក្រុមប្រឹក្សារបស់ក្រុមហ៊ុន RDL Logistics ជាអ្នកចូលរួមសិក្ខាសាលាម្នាក់នៅថ្ងៃព្រហស្បតិ៍បាននិយាយថា ក្រុមហ៊ុនរបស់លោកមិនដែលបានធ្វើជំនួញជាមួយអង្គការសហប្រជាជាតិទេ ពីព្រោះខ្លួនមិនដឹងរបៀបធ្វើ។

លោក រតនា បាននិយាយថា "យើងមិនមានជើងសារជំនួញដែលអនុញ្ញាតឱ្យយើងបង្ហាញផលិតផលរបស់យើងដល់អង្គការសហប្រជាជាតិ ហើយខ្ញុំគិតថា នេះជាលើកដំបូងហើយដែលអង្គការដ៏ធំនេះបានផ្តល់ឱកាសដល់ក្រុមហ៊ុនរបស់យើង ដើម្បីយល់ដឹងពីរបៀបធ្វើជំនួញជាមួយអង្គការសហប្រជាជាតិ"។

លោក ម៉ៅ ថូរ៉ា រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មដែលបានជួយរៀបចំសិក្ខាសាលានេះបានមានប្រសាសន៍ថា ការប្រឈមធំបំផុតចំពោះក្រុមហ៊ុនកម្ពុជា គឺការយកឈ្នះការដេញថ្លៃរបស់អង្គការសហប្រជាជាតិ។

លោកបានមានប្រសាសន៍ថា "ឧទាហរណ៍មានក្រុមហ៊ុនល្អៗដែលមិនពុករលួយ ប៉ុន្តែពួកគេមិនអាចឈ្នះការដេញថ្លៃដោយសារកត្តាផ្សេងៗ ដូចជាចំនួននៃតម្រូវការ ឬដោយសារពេលវេលាហួសពីលទ្ធភាពរបស់អ្នកផ្គត់ផ្គង់"។

ថ្លែងបន្ទាប់ពីសិក្ខាសាលានោះ លោក ដូវហ្គោប៉ូលី បាននិយាយថា ទិដ្ឋភាពសំខាន់បំផុតមួយនៃការធ្វើជំនួញជាមួយអង្គការសហប្រជាជាតិ គឺការធ្វើទៅតាមការព្រមព្រៀងជាសាកលរបស់ខ្លួនដែលតម្រូវឱ្យមុខជំនួញមិនជាប់ពាក់ព័ន្ធនឹងអំពើពុករលួយ ការរើសអើង និងការរំលោភពលកម្ម។ លោកបាននិយាយថា ក្រុមហ៊ុនទាំងឡាយណាដែលគេរកឃើញថាបានរំលោភបំពានការព្រមព្រៀងពាណិជ្ជកម្មនេះ អាចទទួលរងទណ្ឌកម្មជាច្រើនឆ្នាំ និងជាប់ក្នុងបញ្ជីខ្មៅទៀតផង។

លោកបានឱ្យដឹងថា "អាជីវករម្នាក់ៗត្រូវតែបញ្ជាក់ដោយខ្លួនឯងថា ខ្លួនមិនពុករលួយ" ហើយលោកបានបន្ថែមថា ក្រុមហ៊ុនក៏ត្រូវគេពិនិត្យលើទិន្នន័យផ្សេងៗដែរ។

លោកបាននិយាយថា "ពិតហើយ វាមិនផ្តល់ឱ្យអ្នកនូវការធានា១០០ភាគរយទេ ប៉ុន្តែយើងទទួលបានភាគច្រើនបំផុត"។

លោកស្រី ម៉ាតា អេសកូរីហ្វូអេឡា មន្ត្រីលទ្ធកម្មនៅសាលាក្តីកាត់ទោសខ្មែរក្រហមដែលគាំទ្រដោយអង្គការសហប្រជាជាតិដែលបានចំណាយរវាង១លានដុល្លារទៅ១,៥លានដុល្លារលើផលិតផលនិងសេវាកម្ពុជារាល់ឆ្នាំ បានទទួលស្គាល់ថាអំពើពុករលួយក្នុងចំណោមក្រុមហ៊ុនក្នុងស្រុកជាបញ្ហាមួយ។

លោកស្រីបាននិយាយថា "នោះជាបញ្ហាដែលដំណើរការឈ្នះលទ្ធកម្មរបស់យើងក្នុងប្រទេសកម្ពុជាប្រហែលត្រូវការពេលយូរបន្តិច"។

លោក ព្រាប កុល នាយកអង្គការតម្លាភាពកម្ពុជាបានមានប្រសាសន៍តាមរយៈអ៊ីម៉េលថា ឱ្យក្រុមហ៊ុនអនុវត្តតាមច្បាប់របស់អង្គការសហប្រជាជាតិនឹងលើកទឹកចិត្តឱ្យមុខជំនួញលុបបំបាត់អំពើពុករលួយ ប៉ុន្តែលោកបាននិយាយថា ការរៀបចំមួយបែបនេះនឹងលំបាកចំពោះអង្គការសហប្រជាជាតិក្នុងការអនុវត្ត។

លោកបានមានប្រសាសន៍ថា "ចំពោះក្រុមហ៊ុនជាច្រើនក្នុងប្រទេសកម្ពុជាអំពើពុករលួយ និងលុយទឹកតែជាការពិតមិនអាចគេចផុតទេ ហើយវាលំបាកមើលឃើញថាបញ្ហានេះត្រូវគេតាមដាននិងដាក់ពិន័យដោយរបៀបណាណាស់"៕ **និត**

# We Want Your Business, UN Tells Local Firms

The $1.6-billion Untac mission of the early 1990s injected a huge amount of money into Cambodia's economy. Now, the U.N. wants to pump millions more into the country-this time by buying up the offerings of local businesses.

At a seminar at the Commerce Ministry on Thursday, U.N. representatives briefed some 30 Cambodian business owners on how they could potentially make millions of dollars by selling their products or services to U.N. agencies in Cambodia and around the world.

"The overall size of the United Nations' market is between $16 billion and $17 billion worldwide every year," said Dmitri Dovgopoly, director of the U.N.'s procurement division.

Despite the potential for huge profits through selling to the U.N., Mr. Dovgopoly said that in 2013, Cambodian businesses sold just $24.6 million worth of goods and services to the U.N. That same year, Afghanistan-which has a gross domestic product that is 25 percent larger than Cambodia's, according to the World Bank-made $700.9 million from U.N. contracts.

"We do very little business in Cambodia because of a lack of knowledge among local business communities about the business opportunities that we can offer," Mr. Dovgopoly said.

According to the U.N.'s 2013 procurement report, Cambodia sells dozens of different products to the U.N., ranging from medical equipment and motorbikes to office supplies and uniforms. It also offers a number of services, including real-estate agents and commercial printing.

Mr. Dovgopoly added that while there were only about 100 Cambodian companies selling to the U.N., he believed local firms had much to offer it, not only by providing products but services as well. "I think Cambodia has a lot of potential," he said.

One of the attendees of Thursday's seminar, Nuon Ratana, a board member of RDL Logistics, said his company had never done business with the U.N. simply because it did not know how.

"We don't have brokers who let us present our products to the U.N. and I think this is the first time that this big organization has offered us the opportunity to understand how to do business with it," Mr. Ratana said.

Mao Thora, a secretary of state at the Commerce Ministry who helped organize the seminar, said the biggest challenge for Cambodian firms would be winning the U.N. bids.

"For example, there are good companies that are not corrupt, but they cannot win bids due to various factors, such as the quantity of demand, or because the timeframe is beyond the ability of the supplier," he said.

Speaking after the seminar, Mr. Dovgopoly said that one of the most important aspects of doing business with the U.N. is abiding by its Global Compact Initiative, which requires businesses to refrain from engaging in corruption, discrimination and labor abuses. Companies found violating the compact, he said, could be sanctioned for years, even blacklisted.

"Each and every vendor must self-certify that they are not corrupt," he said, adding that companies are also screened against various databases.

"Of course, it doesn't give you a 100 percent guarantee, but we catch most," he said.

Marta Escorihuela, a procurement officer for the U.N.-backed Khmer Rouge tribunal, which spends between $1 million to $1.5 million on Cambodian goods and services each year, admitted that corruption among local companies is an issue.

"That's the reason why our soliciting process in Cambodia may take a bit longer," she said.

Preap Kol, director of Transparency International Cambodia, said in email that getting companies to follow the U.N.'s rules would encourage businesses to stamp out corruption, but said such an arrangement would be hard for the U.N. to enforce.

"For many businesses in Cambodia, corruption and tea money are inescapable realities, and it is hard to see how this can all be monitored and penalized," he said.

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ជំនាន់ថ្មីប្រែសម្រួលពីភាសាអង់គ្លេស    អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

តមកពីទំព័រទី ០៧

## លោក ជា សុីម ប្រធានគណបក្សប្រជាជន...

នាទសវត្សរ៍ឆ្នាំ១៩៨០ក្រោយពីការផ្តួលរំលំរបប ប៉ុល ពត ហើយបន្ទាប់មកបានក្លាយជាប្រធានស្ថាបនិករបស់គណបក្សប្រជាជនកម្ពុជាបានទទួលមរណភាពក្នុងក្រុងភ្នំពេញកាលពីថ្ងៃចន្ទ។ លោកមានអាយុ៨២ឆ្នាំ។

យោងតាមលោក យឹម លាង ប្រធានអង្គរក្សរបស់លោកឱ្យដឹងថា ជាមេដឹកនាំគណបក្សប្រជាជនកម្ពុជាកាន់តំណែងយូរដែលទទួលរងការដាច់សរសៃឈាមខួរក្បាលក្នុងឆ្នាំ២០០០ ហើយបន្ទាប់មកមិនបានបង្ហាញខ្លួនជាសាធារណៈត្បិតមានសុខភាពដុនដាបបានទទួលមរណភាពនៅឯភូមិគ្រឹះរបស់លោកនៅក្បែរព្រឹទ្ធសភានៅម៉ោងប្រហែល៣ និង៤៥នាទីរសៀល។

យោងតាមលោក ជា សុន អតីតនាយខុទ្ទ-កាល័យឱ្យដឹងថា លោក ជា សុីម បានធ្លាក់ខ្លួនឈឺធ្ងន់កាលពីសប្តាហ៍មុនដែលបណ្តាលឱ្យលោកទទួលមរណភាព។ លោក សុន បានមានប្រសាសន៍ថាមានការរៀបចំពិធីដើម្បីបូជាសពរបស់លោកនៅឯសួនច្បារវត្តបទុម។

កើតនៅក្នុងស្រុករមាសហែកខេត្តស្វាយរៀងក្នុងខែវិច្ឆិកា ឆ្នាំ១៩៣២ លោក ជា សុីម បានសិក្សាបាលីក្នុងវត្តអារាមមុននឹងចូលរួមក្នុងចលនាឥស្សរៈប្រឆាំងនឹងអាណានិគមរបស់លោក សុីន ង៉ុកថាញ់តាំងពីលោកនៅជំទង់ក្នុងដើមឆ្នាំ១៩៥២។

ដោយចូលរួមគណបក្សប្រជាជនបដិវត្តន៍កម្ពុជាគាំទ្រដោយវៀតណាមក្នុងឆ្នាំ១៩៥៩ លោកបានក្លាយជាលេខាបក្សស្រុកប្រចាំទិសបូព៌ា ដោយបន្តបម្រើការនៅទីនោះជាមេដឹកនាំថ្នាក់កណ្តាលរហូតដល់មានជ័យជម្នះឆ្នាំ១៩៧៥របស់ខ្មែរក្រហមនិងក្រោយមកទៀត។

ក្នុងពេលដែលមានការធ្វើវិសុទ្ធិកម្មកាន់តែខ្លាំងឡើងចំពោះថ្នាក់ដឹកនាំតំបន់បូព៌ាដោយរបបប៉ុល ពត ដែលកម្ចាត់ចោលនូវថ្នាក់ដឹកនាំកាន់តំណែងយូរភាគច្រើន លោក ជា សុីម នៅពេលនោះជាមេបញ្ជាការតំបន់បានភៀសខ្លួនជាមួយអ្នកដទៃទៀតទៅកាន់ប្រទេសវៀតណាមក្នុងឆ្នាំ១៩៧៨។

រួមជាមួយលោក ហេង សំរិន ដែលបច្ចុប្បន្ននេះជាប្រធានសភា និងលោក ប៉ែន សុវណ្ណ បច្ចុប្បន្នជាតំណាងរាស្ត្រគណបក្សប្រឆាំងនោះលោក ជា សុីមបានវិលត្រឡប់មកកម្ពុជាវិញនៅឆ្នាំនោះ ក្នុងឋានៈជាមេដឹកនាំស្ថាបនិកមួយរូបក្នុងបណ្តាស្ថាបនិកទាំងអស់នៃរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាដែលគាំទ្រដោយវៀតណាម។

នៅថ្ងៃទី២ធ្នូ ឆ្នាំ១៩៧៨ មានប្រារព្ធពិធីនៅក្នុងខេត្តក្រចេះក្រោមអធិបតីភាពដោយមេដឹកនាំកុម្មុយនិស្តវៀតណាម លោក ឡឺ ឌឹកថូ លោក ជា សុីមទទួលបានការតែងតាំងជាអនុប្រធានរណសិរ្សរបស់លោក សំរិន។

លោក អុីវ៉ាន ហ្គុតធិសម៉ែន បានសរសេរទាក់ទងនឹងពិធីនោះក្នុងសៀវភៅចេញផ្សាយនាឆ្នាំ២០០៤ របស់លោកថា "លោក ជា សុីម មានអាយុ៤២ឆ្នាំ គឺមានវ័យចាស់ជាងលោក សំរិន ពីរឆ្នាំ។ ដោយមានមាឌក្រអាញសក់ខ្លីក្រាស់លោកសុីមទំនងជាខ្មែរមួយចំនួនតូចដែលមិនទទួលរងការខ្វះអាហារូបត្ថម្ភទេ"។

ក្នុងពេលដែលវៀតណាមផ្តួលរំលំរបបប៉ុលពតនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ លោក ជា សុីម ត្រូវបានតែងតាំងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃនៃរបបថ្មីដោយរង់ចាំការបោះឆ្នោតក្នុងឆ្នាំ១៩៨១ ហើយមិនយូរប៉ុន្មានលោកក៏បានធ្វើបានល្អជាងទាំងលោក សំរិន ទាំងលោក សុវណ្ណ ក្នុងការកសាងមូលដ្ឋាននយោបាយដែលធ្វើឱ្យលោកមានសារៈសំខាន់ចំពោះមេដឹកនាំវៀតណាមរបស់លោក។

លោក ហ្គុតធិសម៉ែន បានកត់សម្គាល់ក្នុងសៀវភៅរបស់លោកដែលផ្អែកលើកំណត់ត្រាពិស្តារនៃកិច្ចប្រជុំគណៈរដ្ឋមន្ត្រីក្នុងទសវត្សរ៍ឆ្នាំ១៩៨០ថា "ក្នុងចំណោមអតីតកម្មាភិបាលខ្មែរក្រហមលោក ជា សុីម រដ្ឋមន្ត្រីក្រសួងមហាផ្ទៃមានអំណាចបំផុត"។

លោក ហ្គុតធិសម៉ែន សរសេរថា "លោកសុីម គឺជាអ្នកនយោបាយចាស់ទុំខ្មែរមួយរូបដែលយល់ដឹងអំពីវិធីបណ្តុះប្រព័ន្ធបក្សពួកនិយម និងវិធីបណ្តុះភក្តីភាពចំពោះអ្នកដើរតាមលោក។ ឱ្យតម្លៃដោយវៀតណាមចំពោះសមត្ថភាពរបស់លោកក្នុងការប្រមែប្រមូលអ្នករត់ចោលជួរខ្មែរក្រហមលោក ជា សុីម បានជ្រើសរើសកម្មាភិបាលតំបន់បូព៌ាបានយ៉ាងច្រើន ហើយភ្លាមនោះ ក៏បានកសាងមូលដ្ឋានអំណាចផ្ទាល់ខ្លួនតែម្តង"។

ផ្ទុយទៅនឹងទ័ពខ្មែរក្រហមដែលនៅពេលនោះបានកំពុងបះបោរពីព្រំដែនថៃលោក ជា សុីម ក្លាយជាតំណាងឱ្យកុម្មុយនិស្តខ្មែរ គឺផ្តោតលើអតីតតំបន់បូព៌ាដែលមានទំនាក់ទំនងល្អកល្អិនជាមួយវៀតណាម។

លោក ជែកស៊ីបេឃីត អ្នកឆ្លើយឆ្លងព័ត៌មានប្រចាំកម្ពុជារបស់កាសែតបាងកកប៉ុស្តិ៍ក្នុងទសវត្សរ៍ឆ្នាំ១៩៨០ បានកត់សម្គាល់ថា លោក ជា សុីមប្រកាន់ខ្ជាប់នឹងវោហារសាស្ត្រដែលលើកតម្កើងដោយវៀតណាមក្នុងកុម្មុយនិស្តឥណ្ឌូចិន ទោះបីជាពេលលោកថ្លែងសុន្ទរកថាទៅកាន់ក្រុមមនុស្សសាសនាក៏ដោយ។

លោក បេឃីត បានសរសេរបន្ទាប់ពីសុន្ទរកថាឆ្នាំ១៩៨៤ដែលលោក ជា សុីម បានថ្លែងទៅកាន់ខ្មែរឥស្លាមថា "ពេលអបអរសាទរបដិវត្តដ៏ភ្លឺស្វាងនៃប្រទេសឥណ្ឌូចិនទាំងបីលោក សុីម បានវាយប្រហារខ្លាំងៗលើពួកវាតទីនិយម-អនុត្តរនិយមប៉េកាំង ចក្រពត្តិអាមេរិកាំង ហើយ និងក្រុមកាន់អំណាចថៃ។

ដោយលោក ហ៊ុន សែន ជាអតីតរដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបនោះ និងជាមន្ត្រីលេចធ្លោដែលទទួលបានតំណែងជានាយករដ្ឋមន្ត្រីក្នុងខែមករា ឆ្នាំ១៩៨៥ ក្នុងអាយុ៣៣ឆ្នាំ នៅពេលនោះ លោក ជា សុីម មានអាយុ៥២ឆ្នាំ និងដោយមានឥទ្ធិពលខ្លាំងលើកងកម្លាំងសន្តិសុខមានគូបដិបក្សម្នាក់ថ្មីនៅក្នុងបក្ស។

ក្នុងពេលដែលទសវត្សរ៍ឆ្នាំ១៩៨០បានកន្លងផុតទៅលោក ហ៊ុន សែន ដែលចេះតែកែទម្រង់ខ្លាំងឡើងៗ បានរិះរកការផ្លាស់ប្តូរគាំទ្រទីផ្សារដែលមានលក្ខណៈស្រដៀងគ្នានឹងការផ្លាស់ប្តូរអនុវត្តនៅក្នុងប្រទេសចិនកុម្មុយនិស្តដោយជៀសមិនផុតពីការប្រឈមមុខនឹងបណ្តាញចាក់ស្រែះរបស់លោក ជា សុីម និងការប្តេជ្ញារឹងត្អឹងទៅនឹងស្ទីលសង្គមនិយមចាស់។

ប៉ុន្តែក្នុងពេលដែលប្រទេសខិតជិតដល់ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសនាឆ្នាំ១៩៩១ ដែលទីបំផុតផ្លាស់របបដោយមានប្រព័ន្ធទីផ្សារ និងមានអំណោយផលដល់គោលបំណងរបស់លោក ហ៊ុន សែននោះ លោក ជា សុីមនឹងបន្តមានឥទ្ធិពលលើលោកនាយករដ្ឋមន្ត្រីនៅក្នុងរចនាសម្ព័ន្ធបក្សដែលនៅតែគ្របសង្កត់លើរដ្ឋដដែល។

ដោយលោក ហ៊ុន សែន ត្រូវគេមើលឃើញថា ជាអ្នកគាំទ្រនៃការខិតខំប្រឹងប្រែងចម្លែក ប៉ុន្តែមិនបានសម្រេចនៅខាងក្នុងរបបនេះ ដើម្បីបើកគណបក្សប្រឆាំងដែលគាំទ្រដោយរដ្ឋក្នុងឆ្នាំ១៩៨៩នោះ លោក ជា សុីម ដោយមានមូលដ្ឋានរបស់លោកនៅឡើយក្នុងកងកម្លាំងសន្តិសុខបានចាប់ផ្តើមដណ្តើមអំណាចដោយកម្ចាត់ក្រុមអ្នកកែទម្រង់ដែលស្និទ្ធនឹងនាយករដ្ឋមន្ត្រី។

សេចក្តីរាយការណ៍ព័ត៌មានកាសែតញូវយ៉កថាមស៍ នាខែសីហាឆ្នាំ១៩៩០ ដែលមានចំណងជើងថា "គូបដិបក្សនយោបាយប្រជែងគ្នានៅក្រុងភ្នំពេញ" បានសរសេរថា "បន្ទាប់ពីមានការចាប់ខ្លួន ការរុះរើ និងការកែសម្រួលជាថ្មីជាបន្តបន្ទាប់នោះ តទៅទំព័រទី ២៤

Continued from page 01

## CheaSim, Long-Serving CPP ...

Once one of the most powerful politicians in Cambodia, CheaSim has largely stayed out of public life in recent years.

CheaSim was born in November 1932 in SvayRieng province, where he studied at a Buddhist temple and was eventually recruited into the Khmer People's Revolutionary Party in 1959, according to the Historical Dictionary of Cambodia.

A military commander under the Khmer Rouge, CheaSim fled to Vietnam in 1978 and was among the founding members of the United Front for the National Salvation of Kampuchea, the Vietnam-backed group that toppled Pol Pot in 1979.

CheaSim was first elected as the president of a reformed CPP in 1991. In April, Mr. Hun Sen announced that he would replace CheaSim as the party's president when he died.



លោក ហេង សំរិន    លោក ជា សុីម    លោក ហ៊ុន សែន

តមកពីទំព័រទី ១៤

# ជនភៀសខ្លួនក្រុមដំបូងមកពី...

កាន់លំនៅបណ្ដោះអាសន្នក្នុងរាជធានីភ្នំពេញ ជាទីដែល IOM នឹងចាប់ផ្ដើមផ្ដល់សេវាកម្មដ៏សំខាន់រួមមានដូចជាការបង្ហាត់បង្រៀនឱ្យចេះភាសាឱ្យយល់ដឹងពីវប្បធម៌ និងសង្គម សេវាកម្មអប់រំផ្សេងៗ សេវាកម្មសុខភាព និងការជួយរកការងារឱ្យពួកគេជាដើម"។

កាលពីប៉ុន្មានសប្ដាហ៍មុន ជនភៀសខ្លួនទាំងបួននាក់នេះ គឺស្ថិតនៅក្នុងចំណោមជនភៀសខ្លួនរាប់រយនាក់ដែលប្រទេសអូស្ដ្រាលីកំពុងឃុំខ្លួននៅក្នុងជំរំលើប្រទេសដែនកោះណូរូ បន្ទាប់ពីពួកគេព្យាយាមចូលទៅក្នុងទឹកដីប្រទេសអូស្ដ្រាលី។ ដោយអនុវត្តតាមគោលនយោបាយអន្តោប្រវេសន៍ថ្មីដ៏តឹងរ៉ឹងប្រទេសអូស្ដ្រាលីបានបដិសេធមិនទទួលយកជនភៀសខ្លួនទាំងនេះឡើយ ហើយកាលពីខែកញ្ញាបានបញ្ចុះបញ្ចូលកម្ពុជាឱ្យជួយតាំងទីលំនៅថ្មីសម្រាប់ជនភៀសខ្លួនក្នុងចំនួនមួយដែលគេមិនបង្ហាញជាថ្នូរនឹងកញ្ចប់ជំនួយក្នុងទំហំទឹកប្រាក់៣១,២ លានដុល្លារ។

ប៉ុន្តែការបញ្ចុះបញ្ចូលជនភៀសខ្លួននៅក្នុងប្រទេសណូរូឱ្យយល់ព្រមមកតាំងលំនៅថ្មីនៅកម្ពុជា គឺជួបការលំបាកយ៉ាងខ្លាំង ទោះបីជារដ្ឋាភិបាលអូស្ដ្រាលីបានបង្ហាញឯកសារជាក់ស្ដែងដែលរៀបរាប់ថា នៅកម្ពុជាមានស្ថេរភាពនយោបាយមានសេវាកម្មសុខាភិបាល និងមានសន្តិសុខល្អដល់ជនភៀសខ្លួនរួចហើយក៏ដោយ។

ឥឡូវនេះជនភៀសខ្លួនចំនួនបួននាក់បានមកដល់កម្ពុជាហើយ ហើយប្រទេសអូស្ដ្រាលីសង្ឃឹមថា ការមកដល់នេះនឹងអាចជួយបញ្ចុះបញ្ចូលជនភៀសខ្លួនផ្សេងៗទៀតឱ្យធ្វើតាមពួកគេ។

ចាប់តាំងពីដើមទីមកម្ល៉េះ កិច្ចព្រមព្រៀងនេះទទួលរងការរិះគន់ឥតឈប់ឈរពីសំណាក់សមាជិកសភាមកពីគណបក្សប្រឆាំង និងអង្គការសិទ្ធិមនុស្សនៅក្នុងប្រទេសទាំងពីរដោយចោទប្រកាន់ប្រទេសអូស្ដ្រាលីថា គេចវេះពីកាតព្វកិច្ចអន្តរជាតិរបស់ខ្លួនដោយយកជនភៀសខ្លួនទៅទម្លាក់ចោលក្នុងប្រទេសមួយដែលស្ថិតក្នុងចំណោមប្រ-ទេសក្រីក្រ និងពុករលួយបំផុតលើពិភពលោក។

ពួកគេក៏បានព្រួយបារម្ភផងដែរខ្លាចក្រែងប្រទេសកម្ពុជាមិនមានលទ្ធភាពក្នុងការមើលថែទាំងជនភៀសខ្លួនមកពីប្រទេសណូរូ មួយឆ្នាំក្រោយនៅពេលប្រទេសអូស្ដ្រាលីឈប់ធានារ៉ាប់រងលើការចំណាយនានាសម្រាប់ជនភៀសខ្លួន។

ប្រទេសកម្ពុជាមានប្រវត្តិមិនល្អឡើយរហូតមកទល់ពេលនេះ។កម្ពុជាកំពុងទទូចសុំឱ្យមានការស្វែងរកប្រទេសទីពាសម្រាប់ជនជាតិភាគតិចម៉ុងតាញ្ញាមកពីប្រទេសវៀតណាមចំនួន១៣នាក់ដែលខ្លួនទទួលយកក្នុងពេលថ្មីៗនេះ ហើយបាននិរទេសជនជាតិភាគតិចម៉ុងតាញ្ញារាប់សិបនាក់បន្ថែមទៀតឱ្យដែលចូលមកមកម្ពុជាបន្ទាប់ពីអ្នកទាំង១៣នាក់នេះ ដោយមិនអនុញ្ញាតឱ្យពួកគេសុំសិទ្ធិជ្រកកោនឡើយ។ កម្ពុជាក៏បានធ្វើដូច្នេះចំពោះជនជាតិភាគតិចវីហ្គួចំនួន២០នាក់កាលពីឆ្នាំ២០០៩ផងដែរដោយនិរទេសពួកគេទៅប្រទេសចិនវិញ។

លោក ភៀល រ៉ូប៊ឺតសុន (Phil Robertson) អនុប្រធានអង្គការឃ្លាំមើលសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីបានលើកឡើងក្នុងសេចក្ដីថ្លែងការណ៍មួយកាលពីម្សិលមិញថា "ប្រទេសអូស្ដ្រាលីបានជះប្រាក់រាប់



ថយន្តតូរិសដែលដឹកជនភៀសខ្លួនបួននាក់កាលពីម្សិលមិញ មកដល់ផ្ទះវីឡាមួយនៅក្នុងក្រុងភ្នំពេញដែលជាកន្លែងស្នាក់នៅបណ្ដោះអាសន្នរបស់ពួកគេ។ រូបថតៈ ស៊ីវ ចាន់ណា,The Cambodia Daily

លានដុល្លារលើប្រទេសកម្ពុជាឱ្យយល់ព្រមទទួលយកជនភៀសខ្លួនទាំងនេះ ទោះបីជាក្នុងពេលថ្មីៗនេះប្រទេសកម្ពុជាមានប្រវត្តិច្រានចោលអ្នកស្វែងរកសិទ្ធិជ្រកកោនមកពីប្រទេសវៀតណាម និងគំរាមបណ្ដេញអ្នកស្វែងរកសិទ្ធិជ្រកកោនផ្សេងទៀតប្រសិនបើគ្មានប្រទេសផ្សេងព្រមតាំងទីលំនៅថ្មីឱ្យពួកគេនោះក៏ដោយ"។

លោកបានលើកឡើងបន្ថែមថា "កម្ពុជាពិតជាគ្មានបំណង ឬសមត្ថភាពក្នុងការធ្វើឱ្យជនភៀសខ្លួនអាចរស់នៅដោយចុះសម្រុងក្នុងសង្គមកម្ពុជាបានរហូតនោះឡើយ។ ជនភៀសខ្លួនទាំងបួននាក់នេះគឺជាមនុស្សដែលត្រូវបានយកមកដកពិសោធដូចសត្វជ្រូក ដោយប្រទេសអូស្ដ្រាលីដែលច្រានចោលការពិតទាក់ទិននឹងប្រទេសកម្ពុជា ដែលគេដឹងរួចមកហើយថា មិនអាចធ្វើឱ្យជនភៀសខ្លួនរស់នៅដោយចុះសម្រុងក្នុងសង្គមរបស់ខ្លួន ហើយបានបញ្ជូនជនភាគតិចម៉ុងតាញ្ញា និងជនជាតិភាគតិចវីហ្គួត្រឡប់ទៅប្រទេសវៀតណាម និងប្រទេសចិនវិញរួចទៅហើយនោះ "។

ប៉ុន្តែផ្ទុយទៅវិញប្រទេសអូស្ដ្រាលីបានខិតខំគ្រប់បែបយ៉ាងដើម្បីព្យាយាមធ្វើឱ្យជនភៀសខ្លួនទាំងបួននាក់នេះដែលមកដល់កម្ពុជាកាលពីម្សិលមិញ **តទៅទំព័រទី ២៣**

**Continued from page 14**

# First Refugees From Nauru...

refusing to take in the refugees and in September convinced Cambodia to resettle an unspecified number of them instead-in return for an aid package worth AU$40-million (US$31.2-million).

But convincing the refugees on Nauru to come to Cambodia has been tough, even after the Australian government distributed a "fact" sheet to refugees that was full of outright lies about the state of crime, healthcare and politics in the country.

Now that the four have arrived, Australia hopes their example will convince more to follow them.

From the start, the plan has drawn strident rebuke from opposition lawmakers and rights advocates in both countries who accuse Australia of shirking its international obligations by shunting the refugees off to one of the poorest and most corrupt countries in the world.

They are worried, too, that Cambodia will not be able to take care of the refugees from Nauru after a year, when Australia stops covering their basic living expenses.

Cambodia has a shoddy record to date. It is insisting on finding a third country for 13 Montagnard refugees from Vietnam it took in recently, and deported dozens more who followed without letting them apply for asylum. It did the same to 20 Uighurs in 2009, forcibly deporting them back to China.

"Australia is throwing tens of millions of dollars at Cambodia to take these refugees, despite Cambodia's recent record of ejecting asylum seekers from Vietnam and its threat to throw out even more if some other country doesn't agree to resettle them," Phil Robertson, deputy director of Human Rights Watch's Asia division, said in a statement Thursday.

"Cambodia clearly has no will or capacity to integrate refugees permanently into Cambodian society," he said. "These four refugees are essentially human guinea pigs in an Australian experiment that ignores…the fact that Cambodia has not integrated other refugees and has already sent Montagnards and Uighur asylum seekers back into harm's way in Vietnam and China."

But Australia has pulled out all the stops to try to make a good impression with the four refugees who arrived Thursday.

According to refugee advocacy groups, the four were promised thousand of dollars each for agreeing to move to Cambodia. Australia has also promised to set them up with bank accounts, provide them with case managers, get them job training and help them find stable employment.

"They will be encouraged and supported to integrate into the Cambodian community and become self-reliant as quickly as possible," the IOM said.

But for the time being, the IOM has made every effort to keep them hidden, and away from the press-at the refugees' own request, according to the IOM.

The deal Australia struck with Cambodia in September promises to let them apply for Cambodian citizenship if they wish. The vast majority of refugees who do resettle in Cambodia, however, either find a third country or simply run away, said Denise Coghlan, director of the Jesuit Refugee Service in the country.

"It will be interesting to see how many of these refugees [from Nauru] plan to stay; I'll be very curious to see that," she said.

Of the roughly 60 refugees already in Cambodia, none is from Iran. The dozen or so Rohingya from Burma are looking for a third country.

peter@cambodiadaily.com, pheap@cambodiadaily.com

## PUBLIC NOTICE

### Public Outreach Meetings LRTA Comprehensive Service Plan

The Lowell Regional Transit Authority (LRTA) will hold public meetings to outline its Draft Comprehensive Service Plan. This Plan is intended to review existing bus routes and identify areas for improvement.

The LRTA will be holding these Public Outreach Meetings at the following locations and times:

Chelmsford Senior Center
Wednesday, June 24, 2015
10:00 AM - 12:00 PM
75 Groton Road
N. Chelmsford MA

Chelmsford Town Hall
Wednesday, June 24, 2015
2:00 PM - 4:00 PM
50 Billerica Road
Chelmsford MA

Pollard Memorial Library
Wednesday, July 1, 2015
5:00 PM - 7:00 PM
401 Merrimack Street
Lowell MA

Hosted by the Lowell Regional Transit Authority.

Interpretation services available upon request. If needed, please contact Trisha Gasper at patricia.gasper@lrta.com or 978-459-0164 x201 by June 19, 2015.

## កិច្ចប្រជុំផ្សព្វផ្សាយជាសាធារណៈ

LRTA គំរោងសេវាកម្មដ៏ធំទូលាយ អាជ្ញាធរដឹកជញ្ជូនដំបន់ឡូវែល,ហៅកាត់ (LRTA) និងប្រារព្ធកិច្ចប្រជុំសាធារណៈស្ដីពីគំរោងសេវាកម្មដ៏ធំទូលាយរបស់ខ្លួន, ក្នុងគំរោងនេះបានគ្រោងការពិនិត្យឡើងវិញនៅផ្លូវរថយន្តដឹកជញ្ជូនភ្ញៀវដែលមានរួចមកហើយ ,ស្វែងរកតំបន់ដែលអាចធ្វើឱ្យប្រសើរឡើងបាន។

LRTA និងធ្វើកិច្ចប្រជុំជាសាធារណៈដែលមានទីតាំងនិងពេលវេលាដូចខងក្រោមនេះ:

នៅ Chelmsford Senior Center:

ថ្ងៃពុធ,ទី២៤ខែមិថុនា, ឆ្នាំ២០១៥, ពីម៉ោង ១០-១២ថ្ងៃត្រង់

នៅលេខ: ៧៥ Groton Road, N. Chelmsford, MA

នៅ Chelmsford Town Hall :

ថ្ងៃពុធ, ទី២៤ ខែមិថុនា, ឆ្នាំ២០១៥, ពីម៉ោង២-៤រសៀល

នៅលេខ: ៥០ Billerica Road, Chelmsford, MA

នៅ Pollard Memorial Library:

ថ្ងៃពុធ,ទី១ខែកក្កដា, ឆ្នាំ២០១៥, ពីម៉ោង ៥-៧ល្ងាច

401 Merrimack Street, Lowell, MA

ប្រារព្ធឡើងដោយអាជ្ញាធរដឹកជញ្ជូនតំបន់ឡូវែល,ប្រសិនបើត្រូវការអ្នកបកប្រែសូមទាក់ទងនៅថ្ងៃទី១៩ ខែមិថុនា, ឆ្នាំ២០១៥, តាមរយៈអ៊ីម៉ែល ឬលេខទូរស័ព្ទនៅខាងក្រោម: Trisha Gasperat patricia.gasper@lrta.com or 978-459-0164 ext-201




## PUBLIC NOTICE

### MEETING

The Northern Middlesex Metropolitan Planning Organization (NMMPO) will meeton Tuesday,June 16, 2015,2:00 P.M., at the Northern Middlesex Council of Governments office, 40 Church Street, Suite 200, Lowell, MA.The NMMPO will vote on whether to release three Federal Certification Documents for a 30-day public comment period: theDraft FFY 2016 Unified Planning Work Program (UPWP), the Draft FFY 2016-2019 Transportation Improvement Program (TIP), and the Draft FFY 2016-2040 Regional Transportation Plan (RTP). The MPO will also take action on threeproposed FFY 2015-2018 TIP amendments and one administrative adjustment. The NMMPO will also receive an updateon the MPO's Title VI annual report.

Notice: This location is accessible to people with disabilities and is near public transportation. NMCOG offers secure bicycle parking on the second floor. The NMMPO provides reasonable accommodations and/or language assistance, free of charge, upon request (including but not limited to interpreters in American Sign Language and languages other than English, open or closed captioning for videos, assistive listening devices and alternate material formats), as available. For assistance, please contact Justin Howard at (978) 454-8021, ext 121 or at jhoward@nmcog.org . Requests should be made as soon as possible for services requiring advanced arrangements, including sign-language, CART or language translation or interpretation.

## ជូនដំណឹងនៃកិច្ចប្រជុំសាធារណៈ

**ប្រែសម្រួលដោយ ថាច់ វណ្ណា**

ផែនការក្រុងតំបន់មីឌុលសិច Middlesex ខាងជើង (ហៅអង្គការ NMMPO) នឹងជួបប្រជុំគ្នានៅថ្ងៃអង្គារទី ១៦ ខែមិថុនាឆ្នាំ ២០១៥ ម៉ោង ២:០០រសៀល នៅក្រុមប្រឹក្សា Middlesex ការិយាល័យរដ្ឋាភិបាល ៤០ Church Street, Suite 200, Lowell, MA ។

NMMPOនឹងបោះឆ្នោតដើម្បីធ្វើការសម្រេចចិត្តលើឯកសារបញ្ជាក់របស់សហព័ន្ធសម្រាប់ឱ្យសាធារណជនបញ្ចេញយោបល់រយៈពេល៣០ថ្ងៃ: លើសេចក្ដីព្រាងកម្មវិធីបង្រួបបង្រួមពលកម្មនៅឆ្នាំ FFY2016. ហៅកាត់ថា : (UPWP), លើសេចក្ដីព្រាង FFY 2016-2019 ស្ដីអំពីការកែលំអកម្មវិធីដឹកជញ្ជូន,ហៅកាត់ : (TIP), និងលើសេចក្ដីព្រាង FFY ឆ្នាំ ២០១៦-២០៤០ ផែនការដឹកជញ្ជូនក្នុងតំបន់ហៅកាត់ (RTP) . MPO នេះក៏នឹងធ្វើសកម្មភាពទៅតាមគំរោងទាំង៣ឆ្នាំ២០១៣-២០១៨ TIPដែលបានស្នើធ្វើវិសោធនកម្ម នឹងកែរតម្រូវតាមរដ្ឋបាលមួយ ។NMMPO នេះក៏នឹងទទួលបាននៅអត្ថបទចុងក្រោយលើចំណងជើងទី៦នៃរបាយកាណ៏ប្រចាំឆ្នាំ។

**កត់សំគាល់:** ទីតាំងនេះ ជនពិការអាចប្រើបាន និងស្ថិតនៅជិតផ្លូវដឹកជញ្ជូនសាធារណៈ។ NMCOG ផ្ដល់កន្លែងចតកង់(bicycle)មានសុវត្ថិភាពនៅលើជាន់ទីពីរ។ NMMPO បានផ្ដល់នូវការស្នាក់នៅសមរម្យ និង, ឬជំនួយជាភាសាដោយឥតគិតថ្លៃ តាមការស្នើសុំ (រួមបញ្ចូលតែមិនបានកំណត់ត្រឹមកម្មវិធីបកប្រែក្នុងភាសាសញ្ញាអាមេរិក និងភាសាផ្សេងពីអង់គ្លេស, បើក ឬបិទចំណងជើងសម្រាប់វីដេអូ,ឧបករណ៏ស្ដាប់ជំនួយ និងទ្រង់ទ្រាយសម្ភារៈជំនួស) ដែលអាចមានឱ្យប្រើប្រាស់។ បើត្រូវការជំនួយ សូមទាក់ទងទៅចាស្ទីន ហូវ៉ឺធ (Justin Howard ទូរស័ព្ទលេខ (៩៧៨)៤៥៤-៨០២១, ខេត ១២១ឬ អ៊ីម៉ែល ទៅ jhoward@nmcog.org ។ ការស្នើសុំគួរតែធ្វើឱ្យបានកាន់តែឆាប់កាន់តែល្អ, សម្រាប់ការផ្ដល់សេវាទាមទារឱ្យមានការរៀបចំកម្រិតខ្ពស់ជាមុន,រាប់ទាំងភាសាសញ្ញា-រទេះរុញសម្រាប់ជនពិការ, ឬការប្រែភាសា ឬអ្នកបកប្រែ៕

Continued from page 10

# Rebuilding Trust

CNRP MP must be able to address the people's grievances over today's widespread crises, such as economic land concessions, land disputes, border encroachments by neighboring countries, illegal immigrants, and environment degradation as in the Areng valley area.

d. The CNRP must establish a clear long-term goal for de-dollarizing the economy in an effort to bring back the value of the local currency. This involves a fundamental reform of the government structures as a whole, such as eliminating corruption, implementing new strategies and principles to serve the national interest rather than the foreign interest, creating a transparent national budget, enforcing protection laws, and launching immigration reforms, economic reforms, etc.

3. Foreign policies and strategic alliance:

a. The CNRP's foreign policies must be clear and unyielding to address the threat of both China's influences and Vietnam's expansionism over Cambodia and the whole of South East Asia, taking into account the fact that the current U.S. foreign policies are in favor of Vietnam against China.

b. The CNRP must build trust with the "Free World" on which the CNRP is dependable, trustworthy, and capable of helping to improve Cambodia's economy, restoring/ maintaining peace and stability in Cambodia.

c. The CNRP must seek a long-term strategic alliance with the United States, which shares the common core values and principles of economic freedom and opportunities,democracy and human rights, and individual liberty with the Cambodian people.

There are scores of Cambodians and overseas supporters who still entertain the hope that the CNRP is that party that can bring positive changes to their lives and their beloved country. …

Therefore, we recommend the CNRP to fully understand the people's concerns, to fully commit to the people, to reforming/strengthening the party structures, and to rebuild trust that have the best chance of success as prescribed above.

Contributed by Vibol Touch and Sophal Sam. They can be reached via e-mail at TVibol123@gmail.com and SophalSam@gmail.com respectively.


Allstate. You're in good hands.

Veasna Chhay
Licensed Sales Producer
Home/Auto/Life MA & RI

Allstate Insurance Company
1535 Smith Street
North Providence, RI 02911

Phone 508-282-5820/Cell 401-588-4358
veasnachhay2@allstate.com



Personalized service.
Trusted advice.

Your classify ad is here for only $50 per month

ពាណិជ្ជកម្មរបស់អ្នកនៅទីនេះ

ចំណាយចំណាយត្រឹមតែ

$50 ក្នុង១ខែ

CALL:
978.677.7163

EMAIL: SOBENPIN@KHMERPOST.US

សិក្សាពីឥស្លាម

សួរ : មានចម្ងល់អ្វីទេពីឥស្លាម?

ឆ្លើយ : សូមទៅមើលគេហទំព័រ www.peacetv.tv ឬគេហទំព័រមួយទៀត www.gainpeace.com.

Q) Any Questions on Islam?

A)watch www.peacetv.tv

visit www.gainpeace.com.



CONWAY
INSURANCE AGENCY

រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវេយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។

យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :

ការធានារ៉ាប់រងគ្រួសារ
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បះ
- វត្ថុបុរាណ

ការធានារ៉ាប់រងជំនួញ
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- វិកខីខម (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការ៉ាស់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY
INSURANCE AGENCY

77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

ខូម័រ សិប្បកម្មឆ្លាក់ផ្នូរសំណាកក្រានីត
COLMER MONUMENT WORKS

Memorials of Distinction
អាស័យដ្ឋាន:1025 Lawrence Street Lowell, MA 01852-4898
(978) 452-7821



- Granite Memorials ផ្នូររាងបញ្ឈរធ្វើពីថ្មក្រានីត
- Granite & Bronze Markers ផ្នូរផ្តេកមានឆ្លាក់សំរិទ្ធលើថ្មក្រានីត
- Cemetery Lettering in Khmer មានឆ្លាក់អក្សរខ្មែរលើថ្មនៃផ្នូរ

COLMER
Monument Works

ភាពថ្លៃថ្នូរ កិត្តិយស និងការគោរពជូនលោកអ្នក
Honor. Dignity. Respect for All

## តមកពីទំព័រទី ១១ ក្បួនដំណើរ...

គឺការអភិរក្សទទួលបានជោគជ័យ ។ អ្នកដឹកនាំទេសចរណ៍លោក Fred Faust បានបង្ហាញឧទាហរណ៍នៃអគារជាច្រើននៅក្នុងទីក្រុងដែលត្រូវបានរក្សាទុករយៈពេលជាច្រើនឆ្នាំកន្លងមកតែឥឡូវនេះមើលទៅដូចជាស្រស់ស្អាតដូចជាថ្ងៃដែលគេទើប និងសាងសង់ឡើង ។

ដំណើរទស្សនកិច្ចលើកទីពីរនៅថ្ងៃទី១៣ ខែមិថុនាឆ្នាំ២០១៥, ទស្សនាទីក្រុងពិនិត្យការថែរក្សាវិចិត្រសិល្បៈសាធារណៈរូបចម្លាក់សិល្បៈដែលនៅក្រៅផ្ទះយកមករក្សាទុក ។

ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៥ -នៅក្នុងសាលាអនុវិទ្យាល័យជាមួយនឹងលោក ប្រៃអីន-ម៉ាទីន ( Brian Martin)

ថ្ងៃទី២៧ ខែមិថុនាឆ្នាំ ២០១៥ -ខាងអក្សរសាស្ត្រឡូវែលនិងអនុស្សាវរីយ៍បណ្ណាល័យ "ផលឡឹដ"

ថ្ងៃទី ៤ ខែកក្កដាឆ្នាំ ២០១៥ - ទិវាឯករាជ្យ -គ្មានក្បួនដំណើរទេ

ថ្ងៃទី១១ ខែកក្កដាឆ្នាំ ២០១៥ -អៀរឡង់និង Acre

ទី១៩ ខែកក្កដាឆ្នាំ ២០១៥ - ឡូវែលពណ៌បៃតង ( ថាមពលអគារដែលមានប្រសិទ្ធិភាព)

ថ្ងៃទី២៥ ខែកក្កដាឆ្នាំ ២០១៥ -ឡូវែលពិធីបុណ្យប្រជាប្រិយ -គ្មានក្បួនដំណើរទេ

ថ្ងៃទី១ ខែសីហាឆ្នាំ ២០១៥ -ការលើកលែងទោសមុនសង្គ្រាមស៊ីវិលនៅឡូវែល

ថ្ងៃទី៨ខែសីហា, ២០១៥- ប្រឡាយ ស្រុក Hamilton

ថ្ងៃទី១៥ ខែសីហា, ២០១៥ -កន្លែងធម្មជាតិនៅឡូវែល

ថ្ងៃទី២២ ខែសីហាឆ្នាំ ២០១៥ -ឡូវែលសិល្បករ, អតីតកាលនិងបច្ចុប្បន្ន

ថ្ងៃទី២៩ ខែសីហា, ២០១៥ -ឡូវែលបូជនីយដ្ឋាន

ថ្ងៃទី៥ ខែកញ្ញា ២០១៥ - ផ្លូវរថភ្លើង និង-ផ្លូវ ត្រូលឡេ ក្រុងឡូវែល

Continued from page 11

# Lowell Walks

July 25, 2015 - Lowell Folk Festival - NO TOUR

August 1, 2015 - Pre-Civil War Abolitionists in Lowell

August 8, 2015 - Hamilton Canal District

August 15, 2015 - Natural Places in Lowell

August 22, 2015 - Lowell Artists, Past and Present

August 29, 2015 - Lowell Monuments

September 5, 2015 - Trains and Trolleys in Lowell

September 12, 2015 - Renewing the Acre

## តមកពីទំព័រទី ០២ គោលដៅលំហែរកាយថ្មី...

តែជាប់ណាស់ ដើមទាំងនោះមានតែនៅក្នុងតំបន់ឆាឡេតុននោះទេ ជាដើមដែលនាំមកពីអាហ្វ្រិកាតាំងតែពីជំនាន់ក្រុមទាសករមកដល់កាលពីជាង១០០ឆ្នាំមុនមកម្លេះ ម្លោះហើយផលិតផលសិប្បកម្មទាំងនោះ ជាជំនាញផ្តាច់មុខរបស់ក្រុមគ្រួសាប្រជាជនស្បែកខ្មៅដែលរស់នៅតំបន់នោះនៅឡើយ ។ យើងបានឈប់សំចតនាតូប២-៣កន្លែងមើលកន្ត្រកស្អាត១ជដែកជាមួយអ្នកក្រុងនៅនឹងកន្លែង ខ្លះក៏យកពីគេមកលក់ដើម្បីឱ្យបានយល់ពីជីវិតរស់នៅរបស់អ្នកភូមិភាគខាត្បូង តើគេរស់នៅរបៀបណា? មានទាក់ទងនឹងប្រជាពលរដ្ឋនៅឡូវែលនេះដែរឬទេ? មានខ្លះដែរ ដែលយើងនឹងរៀបរាប់ជូននៅលេខក្រោយទៀត ។ **(សូមអានភាគបន្តនៅលេខក្រោយ)**


Khmer Owned & Operated

Independence Home Care
Health Services LLC

ថែរក្សាសុខភាពដល់លំនៅដ្ឋានរបស់អ្នកទូទាំងរដ្ឋ

Licensed Home Care Provider / Companion Services

Certified Medicare/Medicaid • Joint Commission Accreditation • Home Nursing Care Provider Licensed by RI Department of Health

**Approved Provider of All State Programs:** Department of Elderly Affairs / Department of Human Services

**Skilled Nursing**
- Registered Nurses
- Home Health Aide
- Physical Therapy
- Occupational Therapy
- Speech Therapy
- Medical Social Worker

**Unskilled Nursing**
- Companionship
- Personal Care
- Bathing
- Dressing
- Safety
- Meal Preparation and Housekeeping
- Medication Reminders
- Errands and Assistance with Transportation

**Employment**
**Nurses & CNAs**
- Helping Over 100 Rhode Island Elderly Southeast Asians
- We Employ Over 50 Southeast Asians
- FREE ASSESMENT



*Let our family, take care of yours.*

CALL US TODAY!
(401) 437-8337
www.independencehs.com
Available 24/7



1179 Elmwood Ave.
Providence, RI 02907

- See our Khmer Video about Home Care at our website -

# រុក្ខជាតិពិសិដ្ឋ : ដើមពុកមាត់ឆ្មា?

**ដោយៈ តឹមភឿន**

ពុកមាត់ឆ្មារជារុក្ខជាតិម៉្យាងក្នុងគ្រួសារបន្លែ មានព្រុយសណ្ឋានដូចពុកមាត់ឆ្មាទើបគេឱ្យឈ្មោះថាដើមពុកមាត់ឆ្មាដែលគេប្រទះឃើញដុះក្នុងព្រៃស្រុកខ្មែរយើងនឹងនៅសឹងគ្រប់កន្លែងនៅអាស៊ីអគ្នេយ៍ ។ មិនទាន់មានការសិក្សាស្រាវជ្រាវរុក្ខជាតិនេះក៏គ្មានបានគេយកចិត្តទុកដាក់ស្គាល់វាហើយក៏ដុះដូចស្មៅធម្មជាតិអត់មានឈ្មោះបោះសម្លេងអ្វីទេមិនប្លែកអ្វីពីដើមម្រុំដើមញដើមផ្កាលផ្សេងៗនោះទេ ។ ក្រោយពីគ្រូថ្នាំបុរាណបានស្គាល់សារធាតុលក្ខណៈពិសេសរបស់វាក្នុងការព្យាបាលជំងឺអ្វីមួយហើយរុក្ខជាតិនោះនឹងមានឈ្មោះល្បីទៅតាមសារធាតុនឹងលក្ខណៈពិសេសទាំងនោះទៅ ។

ចុះដើមពុកមាត់ឆ្មាមានលក្ខណៈពិសេសអ្វីខ្លះ? បានជាឥឡូវនេះវាបានក្លាយពីស្មៅធម្មជាតិគ្មានឈ្មោះមកជារុក្ខជាតិពិសិដ្ឋទៅវិញហើយ? ដើម្បីបានយល់ដោយផ្ទាល់មិនមែនជឿតាមអត្ថបទចុះផ្សាយនេះទេ សូមលោកអ្នកអានស្វែងយល់លើគេហទំព័រនានាក្នុង Google Search ដោយវាយពាក្យថាៈ MisaiKucing ឬដោយពាក្យថា OrthosiphonStaminousBenth លោកអ្នកនឹងទទួលបានព័ត៌មាននឹងរូបភាពយ៉ាងច្រើនពី លក្ខណៈពិសេសនៃរុក្ខជាតិនេះ ។





ចំពោះលោកអ្នកដែលគ្មានមធ្យោបាយស្វែងយល់ខ្លួនឯងដោយកុំព្យូទ័រទេ ខ្ញុំសូមដកស្រង់ជូននូវព័ត៌មានសំខាន់ៗពីរុក្ខជាតិដ៏ពិសិដ្ឋនេះដូចតទៅៈ រុក្ខវិទូនៅប្រទេសឥណ្ឌា,ជប៉ុន,សហរដ្ឋអាមេរិកជាដើមបានស្រាវជ្រាវរកឃើញនូវលក្ខណៈពិសេសរបស់រុក្ខជាតិនេះក្នុងការជួយសម្រាលឱ្យបុព្វហេតុនៃជំងឺជាច្រើនក្នុងរាងកាយយើងចុះអនុភាពទើបគេបានបង្កើតជាតែកញ្ចប់សម្រាប់ឆុងពិសារក្រោយពេលអាហារនិមួយៗដើម្បីកាត់បន្ថយទម្ងន់ជំងឺទាំងនោះឱ្យបានធូរស្រាលរហូតដល់ជាសះស្បើយបាន ។ ហេតុនេះគេមិនចាត់ទុកតែនេះថា ជាថ្នាំទេវាជាអាហារបំពេញបន្ថែម ។ សារធាតុនៃរុក្ខជាតិនេះបានបង្កលក្ខណៈឱ្យដើមពុកមាត់ឆ្មាមានលក្ខណៈសម្បត្តិដ៏ច្រើនបណ្តាលឱ្យអ្នកស្រាវជ្រាវចាត់ទុកថា វាជារុក្ខជាតិដ៏ពិសិដ្ឋ ព្រោះវាជួយសង្គ្រោះមនុស្សឱ្យចេញផុតពីជំងឺសម័យបច្ចុប្បន្ននេះដែលវេជ្ជបណ្ឌិតទាំងឡាយលើពិភពលោកសឹងតែអស់សង្ឃឹមនឹងយកជ័យជំនះលើវាបានដូចជាជំងឺៈ សំពាធឈាមខ្ពស់ (លើសឈាម),ទឹកនោមផ្អែមឬសារធាតុស្ករច្រើនហួសកម្រិតក្នុងឈាម,ជំងឺហើមសន្លាក់ឬរលាកសន្លាក់ឆ្អឹងបណ្តាលមតពីសារជាតិអាស៊ីដអ៊ុយរិកនៅក្នុងឈាម,ជំងឺ

**តទៅទំព័រទី ២៥**


ហ្វេយ៍មឹកខេប ផ្ទះសម្រាប់ពិធីបុណ្យសព
Fay McCabe Funeral Home
105 Moore Street. Lowell, MA 01852
978-459-9222



បម្រើសហគមន៍ខ្មែរដោយការយកចិត្តទុកដាក់ កិត្តិយស
និងការគោរពជាង៣០ឆ្នាំមកហើយ

- Serving All Faiths បម្រើសេវាកម្មគ្រប់ជំនឿ
- Traditional Funerals កម្មវិធីបុណ្យសពជាលក្ខណៈប្រពៃណី
- Cremation Services មានផ្តល់សេវាបូជាសព
- Pre Arranged Funerals រៀបគំរោងមុនកម្មវិធីបុណ្យសព

*លោកអ្នកនឹងក្រុមគ្រួសារទទួលបាននូវការយកចិត្តទុកដាក់*
*និងការបម្រើល្អប្រពៃពីទីនេះ ។*

www.faymccabe.com

Locates 1 mile from Glory Buddhist Temple,
between Gorham St. & Lawrence St.
ទីកន្លែងនៅចំងាយ១ម៉ាយពីវត្តពន្លឺពុទ្ធចក្ក
ចន្លោះផ្លូវ Gorham St. & Lawrence St.

**មានបុគ្គលិកនិយាយភាសាខ្មែរ**

តមកពីទំព័រទី ២០

## វប្បធម៌សន្ទនា...

**២** – សម័យអង្គរ ៖ **ប្រាសាទបាយ័ន** កសាងនៅដើមសតវត្សទី១៣ ដោយព្រះបាទជ័យវរ្ម័នទី៧



សន្ទនាតាំងពីថ្នាក់ព្រះមហាក្សត្រដល់សាមន្តរាជ



ព្រហ្មវិហារធម៌ ជាគោលការណ៍



សច្ចភាព(កែវភ្នែក) និងភាពស្មោះត្រង់(ញញឹម)

**លទ្ធផល** ៖ ទឹកដីធំទូលាយ វប្បធម៌រុងរឿង កងទ័ពជើងគោក និងជើងទឹកដ៏ខ្លាំងពូកែ កសិកម្ម និងពាណិជ្ជកម្ម រីកចំរើនដ៏ខ្លាំងក្លា ។

**៣** – សម័យព្រះរាជាណាចក្រកម្ពុជា ក្រុងចតុមុខ ៖ **សង្គ្រាមស៊ីវិល** រវាងព្រះអង្គច័ន្ទរាជាទី១ និង ហ្លួងព្រះស្តេចកន រវាងឆ្នាំ១៥១៦និង១៥២៥

១៥/៤៥

សង្គ្រាម១៣ឆ្នាំ បានធ្វើឲ្យប្រទេសខ្ទេចខ្ទាំ ប្រជានុរាស្ត្រឥតបាយក្រហាយទឹក បង្កបង្កើនផល ធ្វើស្រែចំការមិនបាន ទ្រព្យសម្បត្តិវិនាសហិនហោច ក្រុមគ្រួសារញាតិមិត្តនិរាស្ត្រព្រាត់ប្រាស់ ដោយសារការទៅចុះចូលឬគោរពស្តេចម្ខាងៗតែរៀងៗខ្លួន ។ ដោយសារឃើញច្បាស់នូវទុក្ខរបស់ប្រជារាស្ត្ររកទីបំផុតគ្មាន ស្តេចទាំងពីរព្រះអង្គ ក៏សំរេចប្រាស្រ័យទាក់ទងគ្នា ដោយ ដំបូងភ្លាមកំណត់យក ៖

ខ១ – ច្បាំងគ្នាដោយគោរពនូវពេលវេលាច្បាស់លាស់ គឺចាប់ពី "ថ្ងៃរះរហូតដល់ថ្ងៃលិច" ។ ពេលយប់គឺកងទ័ពសំរាករៀងៗខ្លួន ។

ខ២ – ដល់រដូវធ្វើស្រែចំការ គឺត្រូវបញ្ឈប់ចំបាំងមួយអន្លើសិន លុះដល់ប្រមូលផលរួចរាល់ ទើបកំណត់គ្នាធ្វើចំបាំងបន្តទៀត ។

**លទ្ធផល** ៖ ព្រះអង្គច័ន្ទរាជាទី១បានច្បាំងឈ្នះហ្លួងព្រះស្តេចកន ដោយកិត្តិយស ដោយមិនមានការនិន្ទាពីប្រជានុរាស្ត្រឡើយ ។ ព្រះអង្គបានសាងប្រទេសឲ្យសំបូររុងរឿង។ ព្រះអង្គក៏បានទៅជួសជុលប្រាសាទអង្គរវត្ត (ព្រះពិស្ណុលោក) ឡើងវិញផងដែរ ។



១៦/៤៥

**សំគាល់ ៖**

១ – អង្គការសហភាពអន្តរសភា និង អង្គការសហប្រជាជាតិ បានប្រើ កំពុងប្រើ ហើយនឹងប្រើ ជានិច្ច នូវវប្បធម៌សន្ទនា ដើម្បីដោះស្រាយបញ្ហាផ្សេងៗនៅទូទាំងពិភពលោក ។

២ – ការចងចាំប្រវត្តិសាស្ត្រខ្លួន គឺធ្វើឲ្យយើងមានអនាគតល្អរុងរឿង។

៣ – ចូរយើងកាន់យក និង អនុវត្តវប្បធម៌សន្ទនានេះ ក្នុងជីវភាពប្រចាំថ្ងៃ ដើម្បីឲ្យក្លាយទៅជា " ទំលាប់ " ដែលជាហេតុជំរុញឲ្យយើងអាចសំរេចបំណងសង្គ្រោះជាតិយើងបាន ។

**តើមានកត្តាអ្វីខ្លះដែលគួរឲ្យយើងមានជំនឿទុកចិត្តនិងភ្ជាប់ក្តីសង្ឃឹមទៅលើវប្បធម៌សន្ទនា ហ៊ុនសែន-សមរង្ស៊ី ?**

១ – ការតស៊ូនៅតាមផ្លូវរយៈពេលមួយឆ្នាំ ឈានដល់ការបាត់បង់ជីវិត ទោះបីជាមិនទាក់ទងផ្ទាល់ទៅនឹងបាតុកម្មតវ៉ាពីរឿងលទ្ធផលបោះឆ្នោតក៏ដោយ ។

២ – យើងពុំមានមធ្យោបាយក្នុងការទប់ទល់ នឹងកំលាំងកងទ័ពដែលអាចប្រើប្រាស់ ដើម្បីបង្ក្រាបបាតុករនោះទេ ។

៣ – យើងទាំងអស់គ្នាជាមនុស្ស ។ កំលាំងកាយរបស់យើងម្នាក់ៗមានកំណត់ មិនអាចទ្រាំទ្រនឹងការប្រើប្រាស់ហួសកំរិតរបស់វាឡើយ ។

វីដេអូ ៖ https://www.youtube.com/watch?v=d8S3b_xl_F8

ឯកសារយោង ៖
http://km.wikipedia.org/wiki/អរិយធម៌ខ្មែរនៅសម័យអាណាចក្រភ្នំ
http://fr.wikipedia.org/wiki/Bayon_(Angkor)
http://fr.wikipedia.org/wiki/Monarques_du_Cambodge

១៧/៤៥

តនៅលេខក្រោយ

តមកពីទំព័រទី ១៧

## ជនភៀសខ្លួនក្រុមដំបូងមកពី...

មានការចាប់អារម្មណ៍លើគម្រោងរបស់ខ្លួន។

យោងតាមអង្គការតស៊ូមតិសម្រាប់ជនភៀសខ្លួនបានឱ្យដឹងថា ជនភៀសខ្លួនទាំងបួននាក់នេះត្រូវបានគេសន្យាផ្តល់ឱ្យនូវប្រាក់រាប់ពាន់ដុល្លារក្នុងម្នាក់ៗសម្រាប់ការយល់ព្រមមកតាំងលំនៅថ្មីនៅកម្ពុជា ។ ប្រទេសអូស្ត្រាលីក៏បានសន្យាបង្កើតគណនីធនាគារផ្តល់វគ្គបំពាក់បំប៉នការងារ និងជួយពួកគេក្នុងការស្វែងរកការងារស្ថិតថេរមួយផងដែរ។

អង្គការអន្តរជាតិទេសន្តរប្រវេសន៍បានលើកឡើងទៀតថា "ពួកគេនឹងត្រូវបានលើកទឹក និងជួយជំរុញឱ្យអាចរស់នៅដោយចុះសម្រុងក្នុងសហគមន៍កម្ពុជា ហើយអាចរស់នៅដោយពឹងលើខ្លួនឯងបានក្នុងពេលឆាប់ៗតាមដែលអាចធ្វើទៅបាន"។

អង្គការនេះបានលើកឡើងបន្ថែមថា ប៉ុន្តែក្នុងពេលនេះអង្គការអន្តរជាតិទេសន្តរប្រវេសន៍កំពុងខិតខំគ្រប់បែបយ៉ាងដើម្បីលាក់បាំងពួកគេ និងលាក់បាំងពួកគេពីប្រព័ន្ធផ្សព្វផ្សាយដោយធ្វើតាមសំណើផ្ទាល់របស់ជនភៀសខ្លួន។

កិច្ចព្រមព្រៀងដែលប្រទេសអូស្ត្រាលីបានឯកភាពជាមួយកម្ពុជាកាលពីខែកញ្ញាបានសន្យាអនុញ្ញាតឱ្យជនភៀសខ្លួនដាក់ពាក្យសុំសញ្ជាតិខ្មែរប្រសិនបើពួកគេចង់ធ្វើដូច្នេះ។ តែទោះជាយ៉ាងណាជនភៀសខ្លួនមួយភាគធំដែលតាំងទីលំនៅថ្មីនៅកម្ពុជាបានស្វែងរកប្រទេសទី៣ ឬក៏រត់ចេញពីប្រទេសកម្ពុជារួចទៅហើយ នេះបើតាមប្រសាសន៍របស់លោកស្រី ដេនីស ខហ្វឡេន (Denise Coghlan) ប្រធានអង្គការគ្រិស្តផ្តល់សេវាកម្មសម្រាប់ជនភៀសខ្លួន (Jesuit Refugee Service) ប្រចាំប្រទេសកម្ពុជា។

លោកស្រីបានមានប្រសាសន៍ថា "វាជារឿងគួរឱ្យចាប់អារម្មណ៍ក្នុងការរង់ចាំមើលថាតើមានជនភៀសខ្លួនប៉ុន្មាននាក់ក្នុងចំណោមជនភៀសខ្លួនទាំងនេះ ឱ្យមកពីប្រទេសណូរូ មានផែនការរស់នៅទីនេះ។ ខ្ញុំពិតជាចង់ឃើញខ្លាំងណាស់"។

ក្នុងចំណោមជនភៀសខ្លួនប្រហែល៦០នាក់ដែលបានរស់នៅក្នុងប្រទេសកម្ពុជារួចហើយនោះគ្មានជនភៀសខ្លួនមកពីប្រទេសអ៊ីរ៉ង់ឡើយ។ ឥឡូវនេះ ជនជាតិរ៉ូហ៊ីងយ៉ារាប់សិបនាក់មកពីប្រទេសភូមាកំពុងតែស្វែងរកប្រទេសទី៣៕

**ស៊ុយ ឈាង**

MARCOTTE LAW FIRM
ក្រុមហ៊ុនមេធាវី Marcotte
45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229
•សេចក្តីអន្តរាយដល់បុគ្គល
•ច្បាប់ធានារ៉ាប់រង
•សំណងបុគ្គល
•ការរំលោភបទព្រហ្មទណ្ឌ
•ពិការភាពដោយសន្តិសុខសង្គម
•គ្រោះថ្នាក់ចរាចរណ៍
•បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
•គ្រោះថ្នាក់នៅការដ្ឋាន
•ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
•បំណុលអចលទ្រព្យ
•បណ្តឹងវិវាទទូទៅ
•បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍
មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទមកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ
(978) 458-1229
www.marcottelawfirm.com

តមកពីទំព័រទី ១៦

## លោក ជា ស៊ីម ប្រធានគណបក្សប្រជាជន...

ឥទ្ធិពលរបស់លោក ជា ស៊ីម ដែលមានវ័យច្រើនជាងលោក ហ៊ុន សែន ២០ឆ្នាំ និងជាប្រធានសភា គឺស្តែងចេញកាន់តែច្បាស់ឡើង"។

កាសែតសរសេរថា "សម្ពន្ធមិត្តជិតស្និទ្ធដែលមិនកាន់មនោគមន៍វិទ្យាមួយចំនួនរបស់លោក ហ៊ុន សែន ត្រូវបានបណ្តេញចេញ ឬទុកចោលម្ខាងជំនួសមកវិញដោយមនុស្សដែលគេចាត់ទុកថា សម្របខ្លួនតាមដឹងគុណ ឬទាក់ទងនឹងលោក ជា ស៊ីម ដែលមានវ័យ៥៨ឆ្នាំ"។

សម្ពន្ធមិត្ររបស់លោក ជា ស៊ីម ក្នុងនោះរួមមានប្អូនថ្លៃរបស់លោក និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃបច្ចុប្បន្ន គឺលោក ស ខេង ផង ត្រូវបានដំឡើងតំណែង រីឯសម្ពន្ធមិត្ររបស់លោក ហ៊ុន សែន ក្នុងនោះមានលោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មានសព្វថ្ងៃត្រូវបានដកចេញពីតួនាទីរបស់ខ្លួន។

កាសែតញូវយ៉ក ថាមស៍ បានរាយការណ៍ថា "នៅពេលសួរជាច្រើនខែមុនអំពីតំណែងលោក ហ៊ុន សែន ជានាយករដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងការបរទេសខ្មែរវ័យក្មេងនិងគួរឱ្យកត់សម្គាល់នោះ មន្ត្រីខ្មែរម្នាក់បានញញឹមព្រាយ។ គាត់បាននិយាយថា កុំភ្លេច ហ៊ុន សែន គ្រាន់តែជាមនុស្សទី៣ប៉ុណ្ណោះក្នុងបក្ស។ ជា ស៊ីម ជាមនុស្សទី២"។

នៅពេលរដ្ឋឯកបក្សនេះ បានកែទម្រង់ខ្លួនឯងទៅជាគណបក្សប្រជាជនកម្ពុជាក្នុងឆ្នាំ១៩៩១ មុនការបោះឆ្នោតគាំទ្រដោយអង្គការសហប្រជាជាតិនៅឆ្នាំ១៩៩៣ លោក ជា ស៊ីម ដែលកំពុងមានប្រៀបទទួលការតែងតាំងជាប្រធានគណបក្ស។ លោក ហ៊ុន សែន បានក្លាយជាអនុប្រធានបក្ស និងលោក ហេង សំរិន ជា "ប្រធានកិត្តិយស" របស់គណបក្ស។

ប៉ុន្តែមិនដល់ប្រាំឆ្នាំផងស្ថានការណ៍បានផ្លាស់ប្តូរដោយលោក ហ៊ុន សែន បានបញ្ចៀសយ៉ាងប៉ិនប្រសប់នូវការប៉ុនប៉ងធ្វើរដ្ឋប្រហារមួយដែលដឹកនាំដោយលោក ស៊ិន សុង អតីតរដ្ឋមន្ត្រីក្រសួងមហាផ្ទៃតែដោយមានជំនួយពីកម្លាំងប្រដាប់អាវុធដែលផ្តល់ឱ្យដោយគូប្រជែងរបស់ខ្លួនក្នុងគណបក្សរាជានិយមហ៊្វុនស៊ិនប៉ិច។

លោក ប្រេដ អាដាម (Brad Adams) នាយកប្រតិបត្តិអង្គការឃ្លាំមើលសិទ្ធិមនុស្ស Human Rights Watch ប្រចាំតំបន់អាស៊ីបានសរសេរកាលពីឆ្នាំមុនទាក់ទិននឹងរដ្ឋប្រហារមិនបានសម្រេចនេះថា "មន្ត្រីគណបក្សប្រជាជនកម្ពុជាជាច្រើននាក់ដែលខ្ញុំមានសម្ភាសបាននិយាយថា ពិតណាស់ថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជាសឹងតែទាំងអស់បានដឹង និងគាំទ្ររដ្ឋប្រហារនេះក្នុងនោះមានទាំងសមាជិកជាន់ខ្ពស់ក្នុងភាគី ជា ស៊ីម-ស ខេង ផងដែរ"។

លោក ប្រេដ អាដាម បានរៀបរាប់ថា "ហ៊ុន សែន ទទួលបានតម្លៃច្រើនពី ជា ស៊ីម និង ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ នៅគ្រានោះប៉ូលិសជាកម្លាំងសន្តិសុខមានអំណាចបំផុតក្នុងប្រទេសនេះ ប៉ុន្តែពួកគេនៅក្រោមការគ្រប់គ្រងយ៉ាងរឹងមាំរបស់ភាគីលោក ជា ស៊ីម ក្នុងគណបក្សនេះ"។

លោកបានសរសេរថា "ងាយរងគ្រោះនឹងបទចោទថាបានចូលដៃក្នុងរដ្ឋប្រហារនេះ អ្នកទាំងពីរនាក់ត្រូវទទួលយកលក្ខខណ្ឌរបស់លោក ហ៊ុន សែន ដែលថាលោកនឹងតែងតាំងអគ្គស្នងការប៉ូលិសជាតិបន្ទាប់"។

ដោយលោក ហ៊ុន សែន ទទួលកាន់កម្លាំងសន្តិសុខពីលោក ជា ស៊ីម ហើយបន្ទាប់មកទៀតប្រែក្លាយអង្គភាពអង្គរក្សផ្ទាល់របស់លោកទៅជាកម្លាំងពិសេសនោះ តុល្យភាពគណបក្សបានផ្លាស់ប្តូរ។

លោក អាដាម បានសន្និដ្ឋានថា "នេះជាការផ្លាស់ប្តូរធំសម្បើមក្នុងគណបក្សប្រជាជនកម្ពុជាដែលបានធ្វើឱ្យលោក ហ៊ុន សែន ក្លាយជាបុរសមានអំណាចបំផុតយ៉ាងច្បាស់ក្រឡែតទាំងក្នុងគណបក្ស និងទាំងក្នុងប្រទេស"។

បើទោះជាចុះថយកម្លាំងសន្តិសុខក៏ដោយក៏លោក ស៊ីម កាលនោះអាយុ៦២ឆ្នាំ បន្តធ្វើជាប្រធានគណបក្សប្រជាជនកម្ពុជាផង និងជាប្រធានសភាផង ហើយនៅឆ្នាំ២០០៣ នៅតែជាមនុស្ស "មានទំនាក់ទំនងល្អបំផុត" ក្នុងរង្វង់គណបក្សប្រជាជនកម្ពុជា។

ទោះជាយ៉ាងនេះក្តីដោយត្រូវគេទុកឱ្យនៅមានតំណែងជាប្រធានព្រឹទ្ធសភាប្រថាប់ត្រារបស់ប្រទេសកម្ពុជានៅពេលស្ថាប័ននេះបង្កើតឡើងនៅខែមីនាឆ្នាំ១៩៩៩ លោក ស៊ីម មានឥទ្ធិពលតិចតួចក្នុងការគ្រប់គ្រងរដ្ឋាភិបាលកម្ពុជាបន្ទាប់ពីការដាច់សរសៃឈាមខួរក្បាលនៅខែតុលាឆ្នាំ២០០០។

ក្នុងការថយចុះអំណាចចុងក្រោយរបស់លោកនៅខែកក្កដាឆ្នាំ២០០៤ លោក ជា ស៊ីម ដែលនៅពេលនោះជាប្រមុខរដ្ឋស្តីទីក្នុងពេលព្រះរាជអវត្តមានព្រះមហាក្សត្រ នរោត្តម សីហនុ ត្រូវបានគេអមដំណើរចេញពីប្រទេសកម្ពុជា ហើយទៅប្រទេសថៃដោយអគ្គស្នងការនគរបាលជាតិ គឺលោក ហុក ឡង់ឌី ប្រហែលទៅព្យាបាលជំងឺ។

តំណាងរាស្ត្រគណបក្សប្រឆាំង និងអ្នកសង្កេតការណ៍បានសន្និដ្ឋាននៅពេលនោះថា ប្រធានគណបក្សប្រជាជនកម្ពុជាស្ទាក់ស្ទើរមិនចុះហត្ថលេខាលើការរៀបចំរដ្ឋធម្មនុញ្ញដំបូង

តទៅទំព័រទី ២៧


AccuCare
Home Care Agency
Group Adults Foster Care Program

កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

Homecare Agency
Group Adult Foster Care Program (GAFC)
MassHealth

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ



Compassionate Care & Reliable
Professional & Cultural Sensitive
Management & Staffs speak Khmer

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើង ដែលមានប ញ្ហារាំរ៉ៃផែកសុខភាព ឬជរាហើយមិនចង់ ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។

Accucare Homecare Agency is the perfect solution for seniors and others who are not ready to leave their home for an institutional setting or live with reltives because of illness or chronic conditions. We improve your life by providing one-on-one compassionate senior care in the comfort of your own home.

ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :
To be eligibled for GAFC you must:
-រស់នៅផ្ទះរដ្ឋ (live in subsidized or public housing)
-អាយុ ២២ ឆ្នាំឡើងទៅ (age 22 years and older)
-មាស់ហែលស្តង់ដា (eligible for Masshealth Standard)
-ត្រូវការជំនួយក្នុងការរស់នៅប្រចាំថ្ងៃយ៉ាងហោចណាស់មួយដូចជា មុជទឹក ស្លៀក-ពាក់ ពេលប្រើបន្ទប់ទឹក ចំអិនអាហារ ឬ ពេលដើរ (need daily assistance with one or more personal care tasks such as bathing, dressing, toileting, meal preparation and/or moving)
-មានការអនុញ្ញាតពីគ្រូពេទ្យផ្ទាល់ខ្លួនអ្នក (have physician statement of your condition)
-ត្រូវបានវាយតំលៃផ្នែកសុខភាព នឹងការអនុម័តយល់ព្រមពីកម្មវិធី (be screened and approved for the program )

ផលប្រយោជន៍ទទួលបាន :
Benefits you will get:
-ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ (personal care service in your home, up to one hour of service each day)
-ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក (Medication Managemant)
-ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីជើ (an individual care plan developed by a registered nurse and case manager)
-វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់ (ongoing monitoring of needs)
-សមាជិកអាចទាក់ទងមក ២៤ម៉ោង (24-hour access to services)

ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston

ដើម្បីចុះឈ្មោះសូមទាក់ទងមក
To register, please contact:

ឱក តុលាយុត្តិ ឡូវែល
Tolayuth Ok: Lowell
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

តមកពីទំព័រទី ១៦
## រុក្ខជាតិពិសិដ្ឋ : ដើមពុកមាត់ឆ្មា

មហារីកផ្សេងៗដែលបណ្តាលមកពីជាតិពុល នៅក្នុងសារពាង្គកាយនៃយើង(ចូលបានដោយចំណីអាហារនឹងការដកដង្ហើមរបស់យើង)។

និយាយឱ្យខ្លី,ងាយយល់គឺដើមពុកមាត់ឆ្មាមានលក្ខណៈសម្បត្តិបណ្តេញជាតិពុលបណ្តេញសារធាតុចង្រៃដែលបណ្តាលឱ្យរាងកាយយើងមានជំងឺ។ ឧទាហរណ៏: បណ្តេញសារធាតុស្ករដែលលើសពីតម្រូវការនៃរាងកាយឱ្យចេញមកក្រៅចោល(យើងបានសះស្បើយពីជំងឺទឹកនោមផ្អែម)។ វាបណ្តេញសារធាតុអាស៊ីដអ៊ុយរិកចេញពីរាងកាយចោលយើងក៏បានជាសះស្បើយពីជំងឺហើមឬរលាកសន្លាក់ឆ្អឹង(gout)។ បណ្តេញនូវសារជាតិខ្លាញ់យើងក៏បានស្រកទំងន់,ការពារកុំឱ្យរាងកាយធាត់រយីករយាក,វាក៏អាចបណ្តេញជាតិខ្លាញ់មានឈ្មោះថាទ្រីគ្លី សេរីដ (Trigliceride) ជួយឱ្យរាងកាយជាសះស្បើយពីជំងឺសំពាធឈាមខ្ពស់ដែលពាក្យសាមញ្ញហៅថា លើសឈាមនឹងជំងឺកុលេសតេរ៉ូលខ្ពស់ (High-cholesterol)។

លក្ខណៈពិសេសដែលបណ្តេញជាតិពុល ឬសារធាតុចង្រៃពីក្នុងរាងកាយមកក្រៅនេះធ្វើឱ្យដើមពុកមាត់ឆ្មាក្លាយជាមធ្យោបាយសម្រាប់បញ្ចុះនោមធម្មជាតិមួយយ៉ាងសក្តិសិទ្ធិបំផុត ហេតុនេះទទួលទានទឹកតែកញ្ចក់ពុកមាត់ឆ្មាអាចជួយការពារជម្ងឺទល់នោមនឹងគ្រួសក្នុងតម្រងនោមបាន។

ដំណឹងល្អមួយទៀតគឺប្រភេទតែកញ្ចប់នេះបានផលិតឡើងហើយនៅប្រទេសកម្ពុជាដោយ



រុក្ខវិទូខ្មែរធ្វើការនៅនាយកដ្ឋានរុក្ខានឹងប្រមាញ់នៃក្រសួងកសិកម្ម។ ប្រសិនលោកអ្នកអានទាំងឡាយមានចម្ងល់ ឬចង់បានព័ត៌មានបន្ថែមពីរឿងនេះ សូមទាក់ទងជាមួយខ្ញុំ គីម ភៀន ទូរស័ព្ទលេខ: ២៦៧ ៤២៣ ៨១៨៧ ដូចមានអស័យដ្ឋានខាងក្រោមនេះ: Mr. Phien Kim #1009. Philadelphia. PA 19111 ៕

តមកពីទំព័រទី ០៦
## ព័ត៌មានសំខាន់អន្តរជាតិ

ចំពោះការទាក់ទងពីអំពើពុករលួយដែលកើតមាននៅក្នុងអង្គការហ្វីហ្វា (FIFA)។ ចំពោះការសហការនេះនិងពិតជានាំមកដល់ពួកគេនូវភាពជោគជ័យលើករណីក្តីអំពើពុករលួយរបស់លោកប្លេតតឺ(Blatter)និងក្រុមរបស់គាត់។ ព័ត៌មានលំអិតសូមមេត្តាចូលទៅកាន់គេហទំពរ: http://www.fifa.com

**●ការសែត ញ៉ូយ៉ក ថៃម និងផ្តល់ព័ត៌មានផ្តាច់មុខនៃកម្មវិធីផ្តល់ពានរង្វាន់ថូនី (Tony) ក្នុងឆ្នាំ២០១៥យើងនេះ**

ថ្ងៃអាទិត្យ ទី៧ ខែមិថុនា ឆ្នាំ២០១៥

កាសែត ញ៉ូយ៉ក ឌ្មេម និងទទួលខុសត្រូវក្នុងការគ្របដណ្តប់នៃប្រពន្ធ័ផ្សព្វផ្សាយលើកម្មវិធីផ្តល់ពានរង្វាន់ថូនី(Tony)ប្រចាំឆ្នាំទី៦៩។ ពានរង្វាន់ ថូនី (Tony) គឺជារង្វាន់ផ្នែកល្ខោនដូរតន្ត្រីដែលផ្តល់ដោយសមាគម ប្រ៊ូដវ៉េ (Broadway)។ កម្មវិធីនេះប្រព្រឹត្តទៅដោយមានការថតរូបដ៏ច្រើនសំបើមពីកម្មវិធី"កំរាលព្រំពណ៌ក្រហម"នេះ និងមានការអត្ថាធិប្បាយពីសកម្មភាពទូទៅនៃកម្មវិធីទំាងមូល។ ការផ្សាយបន្តផ្ទាល់តាមរយៈប្រពន្ធ័ទូរទស្សន៍ និងចាប់ផ្តើមនៅវេលាម៉ោង៨យប់ (ម៉ោងនៅតំបន់ទិសខាងកើតនៃសហរដ្ឋអាមេរិក) នៅ រ៉ាដីយ៉ូ ស៊ីទី ម៉្យូសិក ហូល (Radio City Music Hall) នៃរដ្ឋញ៉ូយ៉ក (New York)។ ចំពោះឆ្នាំនេះ ហ្វាន ហូម (Fun Home) និងអាន អាមេរិកកានអ៊ិន ផារីស (An American in Paris) ផលិតកម្មដូតន្ត្រីទាំងពីរនេះត្រូវបានគេជ្រើសរើសច្រើនជាងគេបង្អស់ដើម្បីឱ្យឈរឈ្មោះក្នុងការប្រលងប្រជែងដើម្បីទទួលរង្វាន់ ថូនី ប្រចាំឆ្នាំយើងនេះ។ ចំណែក លោក ចន ខាមើរូន មិត់ឆិល (John Cameron Mitchell), លោក ថូមមី ទូន់ (Tommy Tune) និងលោក ស្ទីហ្វាន ស្វាត្ស (Stephen Schwartz) ជាបេក្ខជនក្នុងចំណោមភ្ញៀវពិសេសដែលទទួលនូវរង្វាន់ក្នុងវិធីដ៏អធិអធមនេះ។ ព័ត៌មានពិស្តារសូមមេត្តាចូលទៅកាន់គេហទំព័រ: http://www.radiocity.com


KHMERS KAMPUCHEA-KROM FEDERATION
Asia – Australia – Europe – North America
P.O. Box 0193 • Pennsauken • NJ • 08110 • U.S.A.
Tel: (856) 655-3838 • Fax: (856) 583-1503
www.khmerkrom.net / www.khmerkrom.org • Email: giap.tran@khmerkrom.org

The 66th Commemoration the loss of Kampuchea Krom
June 04, 1949 - June 4, 2015

Invitation

The KHMERS KAMPUCHEA-KROM FEDERATON of New England will host the 66th Commemoration on on June 20th, 2015. You, your families and friends are cordially invited to join us for this important event.

Sompao Meas Hall
450 Chelmsford Street
Lowell, MA 01851
Tel: (978) 421-5246 or (978) 421-5256

SCHEDULE

Saturday, June 20, 2015

- 8:00AM - 10 AM : Breakfast to the Buddhist Monks - Paying Respect to Triple Germ
- 10:00 AM - 12 : Chanting both the Paritta and the Para-bhavasutta; Taking the Five Precepts; Alms-giving.
- 12:00 Noon : Lunch served to everybody.
- 1:00 – 3:00 PM : The Start of the Ceremony, and KKF Special Report.
- 6:00 PM – 12 AM : Fundraising (MUSIC and DANCING)

The Khmer Krom dream for the rights of self-determination will not be possible without your support. Your presence to this event is very important.

With Best Regards,
KKF of N.E Representative

May 30, 2015

Vuth Ly

Direction from Boston , Mass
Take I-93 N, I-95 S and US-3 N to your destination in Lowell. Take exit 30C-31 from US-3 N

Direction from Springfield, Mass
Follow I-90 E/Massachusetts Turnpike, I-290 E and I-495 N to MA-110 E/Chelmsford St in Lowell. Take exit 35A-35B-35C from I-495 N

For More Information Call:

| New England Representatives | Springfield, MA | Worcester, MA | Lowell, MA | Lynn, MA | Rhode Island |
|---|---|---|---|---|---|
| Vanna Ly (603) 560-2721 | Many Ngoc Son (My) | Samith Thach | Bopea Sok | Trung Kim (Phorn) | Hui Ly |
| Vuth Ly (774) 329-6484 | (413) 364-9202 | (508) 791-5198 | (978) 551-1109 | (781) 244-8418 | (401) 256-9356 |



KhmerPost USA, LLC
សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក
អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852
លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092
អ៊ីម៉ែល info@khmerpost.us
អានកាសែតនៅគេហទំព័រ www.khmerpost.us
តាមដានយើងនៅទំព័រហ្វេសប៊ុក Like us at: www.facebook.com/KhmerPostUSA

ផ្សាយពាណិជ្ជកម្ម Advertising
អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*
លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)
អ៊ីម៉ែលsobenpin@khmerpost.us

អ្នកនិពន្ធ Editorials
និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*
(978) 942 - 1641 | rogerpin@khmerpost.us

អ្នកនិពន្ធកិត្តិយស **Contributed Writers:**
Kim Phien, Richard Howe,Jr.

ច្នៃសោភ័ណភាពកាសែត **Design Artist**
Heng Chhunleng
នាយករដ្ឋបាល Office Manager **978-677-7163**
Thach Vanna ថាច់ វណ្ណា

KhmerPost USA, LLC is an independent newspaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local community, and national news; and give an insight into Cambodian & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English. It published twice a month in Massachusetts serving Greater Lowell, Lynn, Revere, MA, Providence, RI, CT, NY, NJ, and Philadelphia, PA.

Mail subscription is available within the U.S. & Canada at 100.00 or 120 Euros in Europe per year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009

# ទូលព្រះបង្គំមិនហ៊ានរាយការណ៍ទេ ទាន ! (តពីភាគ២)

**ដោយៈ បញ្ញ សីលា**

**តពីលេខមុន**



ទេពអគ្គលេខាធិការក៏បែរមករកខ្ញុំនឹងលោកតាណូអែលដោយញញឹមមិនសូវសមហើយបណ្តើរទេពអប្សរចេញទៅបានបន្សល់ចោលមកខាងក្រោយនូវសំដីមិនពេញចិត្តរបស់ទេពអប្សរដោយតិចៗថាៈ "ចូរកុំបន្ទោសនាងខ្ញុំថាមិនចេះរកស៊ីណា៎!"។

លោកតាណូអែលសម្លឹងខ្ញុំញញឹមមិនចេញស្តី។ ឱហេតុអីក៏មានឱប្បត្តិហេតុយ៉ាងណឹងនំចាំមើលទៀតមើលមានរឿងអីនឹងកើតឡើងទៀត។ បន្ទាប់មកភ្លាមនោះមានបុគ្គលិកម្នាក់ពាក់អៀមជាចុងភៅកាន់ទាំងវ៉ែកឆាមកជាមួយផងដើរកាត់បន្ទប់យើងខ្ញុំតម្រង់ទៅជួបសមៈទេពអប្សរបាត់ទៅហើយសម្លេងជជែកគ្នាក៏បន្លឺតិចៗពីចម្ងាយមកៈ "អាតិថិជនលើកនេះចំជាលំបាកតម្រូវចិត្តខ្លាំងណាស់ ពួកគេទារសុទ្ធតែម្ហូបថ្លៃៗ ហើយពិបាកធ្វើខ្លាំងទៀតផង ពួកកូនកាំបិតក៏ទារតម្លើងប្រាក់ឈ្នួលជា២ជា៣ដងទៀតដែរ។ គេថាការងារលំបាកហើយមមាញឹកជាងមុន២ទៅ៣ដងឯបៀវត្សនៅតែដដែលតាំងតែពីពួកគេនៅក្មេងៗរហូតដល់ចាស់រៀងខ្លួនហើយនៅតែប៉ុណ្ណឹងដដែល គេចង់សុំឈប់សម្រាកទាំងអស់គ្នា ប្រសិនបើលោកអគ្គលេខាមិនព្រមគិតគូរដល់ពួកគេទៀត សូមទេពកញ្ញាមេត្តាទូលលោកអគ្គលេខាជ្រាបឱ្យទានផង"។ ពេលបន្ទាប់មកនាយចុងភៅដើរកាត់បន្ទប់យើងខ្ញុំព្រមទាំងកាន់វ៉ែកឆាមកវិញ។ គេឮសម្លេងរអ៊ូៗហាក់ដូចជាពាក្យស្តីបន្ទោសៈ"ចុះម៉េចព្រះនាងទេពកញ្ញាមិនព្រមគិតគូរឱ្យពួកវាបានសប្បាយចិត្តផង ព្រោះយើងរកបានកាក់កបណាស់ប៉ុន្មានរដូវនេះពីពួកគណប្រតិភូមកពីផែនដីសុវណ្ណភូមិបានសុទ្ធតែ មាស ពេជ្រ កែវកង ព្រមទាំងគ្រឿងអេឡិចត្រូនិចទំនើបៗ គួរឱ្យពេញចិត្តខ្លាំងណាស់ ខ្ញុំប្រាប់ហើយតើ! យើងបានបាយឱ្យគ្នាបានបបររាវលាយកាកខ្លះផង តិចពួកវាមិននៅស្ងៀមជ្រាបដល់ព្រះអង្គរឿងធំ! អត់មាត់ស្ងែះទាំងអស់គ្នា!"។

ឮពាក្យទាំងនេះលោកតាណូអែលបើកភ្នែកធំៗសម្លឹងខ្ញុំញញឹមដោយពុំចេញស្តី....

លោកតាណូអែលញញឹមជាប់រហូតក្នុងពេលដែលស្មារតីរបស់គាត់ខំផ្ទៀងស្តាប់ការសន្ទនារវាងទេពអគ្គលេខានឹង ទេព កញ្ញា ដែលមានពាក្យខ្លះឮច្បាស់ខ្លះឮមិនច្បាស់ៈ"ហេតុអីបានមានរឿងណឹងកើតឡើង? ខ្ញុំបានគិតទុករួចស្រេចបាច់អស់ហើយតើ ចាត់ចែងបើកឱ្យពួកវាម្នាក់ៗតាមតែការកំណត់របស់ខ្ញុំនោះទៅវាសុខបាត់ទៅហើយ ប្រយ័ត្នពួកវាមិននៅស្ងៀមព្រះអង្គច្បាស់ជាមិនអត់ឱនឱ្យយើងទេ កុំចង់ចំណេញដាច់ចំណេញណា៎!..."។ សម្លេងតិចៗហាក់ ដូចមិនពេញចិត្តបន្លឺឡើងៈ "នាងខ្ញុំទទួលចំណែកក៏មិនសមនឹងតួនាទីរបស់នាងខ្ញុំដែរ បើព្រះអង្គទ្រង់ជ្រាបមិនមែនតែនាងខ្ញុំទទួលគ្រោះកាចម្នាក់ឯងឯណា!..."។ សម្លេងហាក់ដូចបន្ថយទម្ងន់ពីដាក់ទោសមកអង្វរករវិញៈ "ចុះ ទេព កញ្ញា ចង់បានយ៉ាងណាមិនព្រមបង្ហើបឱ្យខ្ញុំដឹងអាចនិយាយគ្នាបានតើ?!..."។ ភ្លាមពេលនោះមានអតិថិជនពីរូបនាំគ្នាតម្រង់ទៅបន្ទប់នាងទេពកញ្ញាដោយរអ៊ូៗស្តាប់មិនច្បាស់ថា និយាយរឿងអីតែហាក់ដូចមានការមិនពេញចិត្តដែរ។ ទ្វារបន្ទប់នៅចំហរអ្នកទាំងពីរដើរចូលដោយតក់ក្រហល់មិនបាច់ឱ្យសញ្ញាវាក់អើនឹងទេពអគ្គេខានឹងទេពកញ្ញាកំពុងមានទឹកមុខមិនបានស្រស់ស្រាយទាល់តែសោះ។ ដោយគ្មានកោតញញើតពួកគេទាំងពីរចាប់និយាយទៅកាន់អ្នកតំណាងភពទេវតាថាៈ "ក្រាបថ្វាយបង្គំទេវបុត្តទេពធិតា!

**តទៅលេខក្រោយ**


## មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល

LOWELL ELDER CARE
978-596-1111

**345 Chelmsford St. Lowell, MA 01851/ – www.lowelleldercare.com**

### អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?

គឺជាលំនៅដ៏កក់ក្តៅមួយ ដែលផ្តល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យមានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ។ កម្មវិធីរបស់យើងធានានូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាសដូចជាផ្ទះរបស់ពួកគាត់ ។

### ទីតាំងនៃមណ្ឌល

ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និងមានពន្លឺគ្រប់គ្រាន់ បន្ទប់អានសៀវភៅ បន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។





### មណ្ឌលផ្តល់សេវាដល់មនុស្សចាស់

- មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
- ការពិនិត្យ និងថែទាំសុខភាព
- ការព្យាបាលតាមរយៈការហាត់ប្រាណ
- កិច្ចការសង្គម (ផ្តល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ)
- ម្ហូបខ្មែរក្តៅៗ និងចំណីផ្សេងៗ
- ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
- កម្មវិធីសិល្បៈ និងតន្ត្រី
- ការអប់រំពីសុខភាព
- ការពិភាក្សាលើព្រឹត្តិការបច្ចុប្បន្ន (និងការសំណេះសំណាលគ្នា)
- សកម្មភាព និងដំណើរកំសាន្តក្រៅមណ្ឌល

### Our Services

- Door-to-Door Transportation
- Medical Care and Support
- Physical Therapy
- Social Worker
- Khmer Meals and Snacks
- Adaptive Physical Exercise
- Music Programs
- Health Educational Seminars
- Discussions on current events, (and times of reminiscing)
- Outdoor Field Trips

**សូមហៅលេខទូរស័ព្ទ (978) 596-1111**



## ការវិភាគ

របស់ព្រះតេជព្រះគុណបណ្ឌិត ហុក សាវណ្ណ

<u>វៀតណាមនៅតែត្រួតត្រាលើប្រទេសកម្ពុជា</u>

ពាក្យថា **ឯករាជ្យ** (Independence) ប្រែថា គ្រប់គ្រងខ្លួនដោយខ្លួនឯងគ្មានចំណុះប្រទេសដទៃ។ ពាក្យថា **អធិបតេយ្យជាតិ** (Sovereignty)ប្រែថា មានអំណាចគ្រប់គ្រងខ្លួន ដោយគ្មានឥទ្ធិពលប្រទេសដទៃបញ្ជាពីលើ។ ប្រទេសដែលស្ថិតនៅក្រោមអាណានិគមបរទេសតែងតែទាមទារឯករាជ្យ។**ឯករាជ្យ**មានតម្លៃបំផុតសម្រាប់ចាត់ចែងវាសនានិងផលប្រយោជន៍ជាតិខ្លួន ឯអ្នកត្រួតត្រាគេតែងទាញយកផលប្រយោជន៍គេ។

វៀតណាមកាន់កាប់ប្រទេសកម្ពុជា ដោយចេញមុខពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៨៩ ដោយកម្លាំងទ័ព។ទោះប្រកាសដកទ័ព វៀតណាមនៅតែត្រួតត្រាលើប្រទេសកម្ពុជាតាមរយៈបក្សប្រជាជន ដោយជំនាញការសម្ងាត់ ពិសេសផ្លូវនយោបាយ។ដំបូង វាយកំទេចចលនាតស៊ូត្រីភាគីពីក្នុងទៅវិញ គណបក្សខ្មែរក្រហមនិងគណបក្សលោកតាសឺនសានបានត្រូវរលាយ ចំណែកគណបក្សហ្វុនស៊ិនប៉ិចដែលដំបូងឈ្នះឆ្នោតក៏ស្ទើររលាយដែរ។ ចំណែក គណបក្សសង្គ្រោះជាតិដែលបានអាសនៈច្រើនក្នុងអាណត្តិទី៥បើធ្វេសប្រហែសនៅពេលមុននិងក្រោយបោះឆ្នោត នឹងមានវាសនាដូចគណបក្សមុន។

ភ័ស្តុតាងដែលបង្ហាញថា វៀតណាមនៅតែត្រួតត្រាប្រទេសកម្ពុជា តាមរយៈបក្សប្រជាជន គឺសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ ព្រះមហាក្សត្របានត្រូវគម្រាមថា បើមិនព្រមចុះព្រះហត្ថលេខាទេ តើត្រូវទុករបបរាជានិយមឬប្រកាសរបបសាធារណរដ្ឋ។ នេះបញ្ជាក់ថា សុខចិត្តរំលាយស្ថាប័នដ៏ធំរបស់ជាតិ ឲ្យតែស្របតាមបញ្ជារបស់វៀតណាម។ បើខ្មែរណាហ៊ានតទល់នឹងវៀតណាមអំពីបញ្ហាព្រំដែននឹងធ្វើក្តារមឈូសចាំនិងចាប់ដាក់ក្នុងពន្ធនាគារ។ល។ ដូច្នេះ គណបក្សប្រជាជននៅក្រោមអំណាចឥទ្ធិពលវៀតណាម បើគណបក្សនេះនៅតែគ្រប់គ្រងអំណាចតទៅទៀត បញ្ហាព្រំដែនបញ្ហាអន្តោប្រវេសន៍វៀតណាមខុសច្បាប់ជាដើមមិនអាចដោះស្រាយបានឡើយ គប្បីយុវជនខ្មែរពិចារណា។

វត្តខ្មែរកាណាដា,ថ្ងៃ២៩ឧសភា២០១៥; www.hoksavann.org;savannhok@yahoo.com

តមកពីទំព័រទី ២៤

## លោក ជា ស៊ីម ប្រធានគណបក្សប្រជាជន...

ចម្រោស ដែលនឹងអនុញ្ញាតឱ្យលោក ហ៊ុន សែន បង្កើតរដ្ឋាភិបាលថ្មីមួយ បន្ទាប់ពីមានភាពទាល់ច្រករយៈពេលមួយឆ្នាំជាមួយគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្ស សម រង្ស៊ី។

ក្នុងពេលអវត្តមានរូបលោកលោក ញឹក ប៊ុនឆៃ ខាងគណបក្សហ៊្វុនស៊ិនប៉ិចដែលជាអនុ-ប្រធានព្រឹទ្ធសភារបស់លោក ជា ស៊ីម និងដែលបានក្លាយជារដ្ឋមន្ត្រីក្រសួងការពារប្រទេសក្នុងរដ្ឋាភិបាលថ្មីនេះ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងដោយបញ្ចប់ភាពទាល់ច្រក។

ក្នុងពេលជាច្រើនឆ្នាំចាប់តាំងពីពេលនោះមក លោក ហ៊ុន សែន បានគ្រប់គ្រងប្រទេសភាគច្រើនដោយគ្មានវត្តមានជាសាធារណៈរបស់លោក ជា ស៊ីម ដែលមានសុខភាពចុះខ្សោយមិនអាចកាន់តួនាទីកិត្តិយសរបស់លោកជាប្រធានព្រឹទ្ធសភាក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយរបស់លោក។

លោក សុខ ឥសាន អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាបានមានប្រសាសន៍កាលពីថ្ងៃច័ន្ទថា លោក ហ៊ុន សែន នឹងកាន់តំណែងប្រធានគណបក្សកាន់អំណាចនេះជាស្វ័យប្រវត្តិដោយបញ្ចប់ការផ្លាស់ប្តូរអំណាចដែលបានចាប់ផ្តើមនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០ ក្នុងពេលដែលលោកនិងលោក ជា ស៊ីម បានដឹកនាំរដ្ឋសង្គមនិយម។



ប៉ុន្តែ លោក ឥសាន បានមានប្រសាសន៍ថា គណបក្សប្រជាជនកម្ពុជានឹងមិនបំភ្លេចការរួមចំណែកដែលលោក ជា ស៊ីម បានធ្វើចំពោះប្រទេសកម្ពុជាសម័យទំនើបនេះទេ។

លោកបានមានប្រសាសន៍ថា "លោក ជា ស៊ីម បានប្រើដៃម្ខាងទប់ស្កាត់របបប្រល័យពូជសាសន៍ខ្មែរក្រហមដែលបានសម្លាប់ប្រជាជនមិនឱ្យកើតឡើងជាថ្មី និងប្រើដៃម្ខាងទៀតកាន់ចបនិងនង្គ័លដឹកនាំប្រជាជនកសាងប្រទេសជាតិឡើងវិញ បន្ទាប់ពីរងការបំផ្លិចបំផ្លាញដោយរបបប្រល័យពូជសាសន៍"។

រើន និងនិត (រាយការណ៍បន្ថែមដោយ ម៉ិច ដារ៉ា)







ដោយ : សាគូ សាមុទ

ភូមិវិទ្យានយោបាយប្រទេសខ្មែរ

ជំពូក៨

# ភូមិវិទ្យានយោបាយប្រទេសខ្មែរ

**តពីលេខមុន**

ភូមិវិទ្យានយោបាយប្រទេសខ្មែរ

## ជំរឿនប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨

០៣-០៣-២០០៨

| | ខេត្ត/រាជធានី | ប្រជាជន-នាក់ | ស្រុក ខ័ណ្ឌ* | ឃុំ សង្កាត់* | ចំនួនភូមិ* | ដង់ស៊ីតេ |
|---|---|---|---|---|---|---|
| ០១ | កំពង់ចាម | ១ ៦៧៩ ៩៩២ | ១៦ | ១៧៣ | ១ ៧៦៧ | ១៧១នាក់/គម$^2$ |
| ០២ | កណ្ដាល | ១ ២៦៥ ២៨០ | ១១ | ១៤៧ | ១ ០៨៨ | ៣៥៥នាក់/គម$^2$ |
| ០៣ | ភ្នំពេញ | ១ ៣២៧ ៦១៥ | ១២ | ១១០ | ៦៨៥ | ៣៣៦១នាក់/គម$^2$ |
| ០៤ | ព្រៃវែង | ៩៤៧ ៣៧២ | ១២ | ១១៦ | ១ ១៣៩ | ១៩៤នាក់/គម$^2$ |
| ០៥ | បាត់ដំបង | ១ ០២៥ ១៧៤ | ១៣ | ៩៦ | ៧៤១ | ៨៨នាក់/គម$^2$ |
| ០៦ | តាកែវ | ៨៤៤ ៩០៦ | ១០ | ១០០ | ១ ១១៧ | ២៣៧នាក់/គម$^2$ |
| ០៧ | សៀមរាប | ៨៩៦ ៤៤៣ | ១២ | ១០០ | ៩០៧ | ៨៧នាក់/គម$^2$ |
| ០៨ | កំពង់ស្ពឺ | ៧១៦ ៩៤៤ | ៨ | ៨៧ | ១ ៣៥១ | ១០២នាក់/គម$^2$ |
| ០៩ | បន្ទាយមានជ័យ | ៦៧៧ ៨៧២ | ៨ | ៦៤ | ៦៣៤ | ១០១នាក់/គម$^2$ |
| ១០ | កំពង់ធំ | ៦៣១ ៤០៩ | ៨ | ៨១ | ៧៣៦ | ៤៦នាក់/គម$^2$ |
| ១១ | កំពត | ៥៨៥ ៨៥០ | ៨ | ៩២ | ៤៨៣ | ១២០នាក់/គម$^2$ |
| ១២ | ស្វាយរៀង | ៤៨២ ៧៨៨ | ៧ | ៨០ | ៦៩០ | ១៦៣នាក់/គម$^2$ |
| ១៣ | កំពង់ឆ្នាំង | ៤៧២ ៣៤១ | ៨ | ៦៩ | ៥៦១ | ៨៥នាក់/គម$^2$ |
| ១៤ | ពោធិ៍សាត់ | ៣៩៧ ១៦១ | ៦ | ៤៩ | ៥០១ | ៣១នាក់/គម$^2$ |
| ១៥ | ក្រចេះ | ៣១៩ ២១៧ | ៥ | ៤៦ | ២៥០ | ៣២នាក់/គម$^2$ |
| ១៦ | ព្រះសីហនុ | ២២១ ៣៩៦ | ៣ | ២២ | ៩៤ | ២៥៥នាក់/គម$^2$ |
| ១៧ | កោះកុង | ១១៧ ៤៨១ | ៨ | ៣៣ | ១៣៣ | ១០នាក់/គម$^2$ |
| ១៨ | ព្រះវិហារ | ១៧១ ១៣៩ | ៧ | ៤៩ | ២០៨ | ១៧១នាក់/គម$^2$ |
| ១៩ | រតនគិរី | ១៥០ ៤៦៦ | ៩ | ៥០ | ២៤០ | ១២នាក់/គម$^2$ |
| ២០ | ស្ទឹងត្រែង | ១១១ ៦៧១ | ៥ | ៣៤ | ១២៨ | ១៤នាក់/គម$^2$ |
| ២១ | ឧត្តរមានជ័យ | ១៨៥ ៨១៩ | ៥ | ២៤ | ២២៧ | ១០នាក់/គម$^2$ |
| ២២ | មណ្ឌលគិរី | ៦១ ១០៧ | ៥ | ២១ | ៩១ | ៤នាក់/គម$^2$ |
| ២៣ | កែប | ៣៥ ៧៥៣ | ២ | ៥ | ១៦ | ១០៦នាក់/គម$^2$ |
| ២៤ | ប៉ៃលិន | ៧០ ៤៨៦ | ២ | ៨ | ៧៩ | ៨៨នាក់/គម$^2$ |
| ២៥ | បូគោ | - | - | - | - | - |
| ២៦ | ទន្លេសាប | - | - | - | - | - |
| | **ទាំងអស់** | **១៣ ៣៩៥ ៦៨២** | **១៩០** | **១ ៦៥៦** | **១៣ ៨៦៦** | **៧៤នាក់/គម$^2$** |

* តួលេខទាំងនេះជាសម្រង់តាមឯកសារដើមមិនអាចចាត់ទុកថាត្រឹមត្រូវទេ ព្រោះមានការកែប្រែជាច្រើនដោយរាជរដ្ឋាភិបាល



ភូមិវិទ្យានយោបាយប្រទេសខ្មែរ

ប្រភព Wikipedia **ផ្ទៃដី ខេត្ត/ក្រុងនិមួយៗ និង ប្រជាជន ឆ្នាំ ២០០៨**

| | Province | Population 2008 | superficie km2 | Chef-lieu |
|---|---|---|---|---|
| 1 | **Banteay Meanchey** | 678 033 | 6 679 | SiriSophorn |
| 2 | Battambang | 1 024 663 | 11 702 | Battambang |
| 3 | kampong cham | 1 680 694 | 9 799 | Kg.Cham |
| 4 | kampong chhnang | 471 616 | 5 521 | Kg.Chhnang |
| 5 | kampong speu | 716 517 | 7 017 | Chbar Môn |
| 6 | Kampong Thom | 630 803 | 13 814 | KrStung Sèn |
| 7 | Kampot | 585 110 | 4 873 | Kampot |
| 8 | Kandal | 1 265 805 | 3 568 | Takhmao |
| 9 | Koh Kong | 139 722 | 11 160 | Khémarakph, |
| 10 | Kèb | 35 753 | 336 | Kèb |
| 11 | Kratié | 318 523 | 11 094 | Kratié |
| 12 | Mondulkiri | 60 811 | 14 288 | Sènmonorom |
| 13 | Oddar Meanchey | 185 443 | 6 158 | Samrong |
| 14 | Païlin | 70 442 | 803 | Païlin |
| 15 | Phnom Penh | 2 000 064 | 320 | Phnom Penh |
| 16 | Preah Sihanouk | 199 902 | 868 | Sihanoukville |
| 17 | Preah Vihear | 170 852 | 13 758 | Kr. P.Vihear |
| 18 | Pursat | 397 107 | 12 692 | Pursat |
| 19 | Prey Vèng | 947 357 | 4 883 | Prey Vèng |
| 20 | Ratanak Kiri | 149 997 | 10 782 | Banlung |
| 21 | Siem Reap | 896 309 | 10 299 | Siem Reap |
| 22 | Stung Trèng | 111 734 | 11 092 | Stung Trèng |
| 23 | Svay Rieng | 482 785 | 2 966 | Svay Rieng |
| 24 | Takèv | 843 931 | 3 563 | Daun Kèv |
| | **Total** | **14 063 973** | **178 035** | |
| 25 | **Tonlé Sap** | | **3 000** | |
| | **Total** | | **181 035** | |
| | **Source : Wikipedia** | | | |
| | | | | |

សង្កេត-យើងបានយកផ្ទៃរាជធានីភ្នំពេញ ៣២០គម$^2$ ដើម្បីឲ្យបាន ១៧៨០៣៥គម$^2$+៣០០០គម$^2$

-ផ្ទៃរាជធានីភ្នំពេញមានចន្លោះពី២៩០គម$^2$ទៅ៧៥៨គម$^2$ព្រោះមានការពង្រីកមិនចប់ទៅខេត្តកណ្ដាល



ភូមិវិទ្យានយោបាយប្រទេសខ្មែរ

*Cambodia Population Chart*

**Population History**

| Year | Population | Change |
|---|---|---|
| 1950 | 4,433,000 | N/A% |
| 1960 | 5,720,000 | 29.03% |
| 1970 | 7,022,000 | 22.75% |
| 1980 | 6,699,000 | -4.60% |
| 1990 | 9,057,000 | 35.20% |
| 2000 | 12,223,000 | 34.95% |
| 2010 | 14,365,000 | 17.52% |

**Population Projections**

| Year | Population | Change |
|---|---|---|
| 2020 | 17,251,000 | 20.09% |
| 2030 | 20,219,000 | 17.20% |
| 2040 | 23,331,000 | 15.39% |
| 2050 | 26,835,000 | 15.02% |
| 2060 | 30,583,000 | 13.97% |
| 2070 | 34,719,000 | 13.52% |






ប្រជាភិវឌ្ឍន៍នៃប្រទេសកម្ពុជា

ជំពូក៩

## ប្រជាភិវឌ្ឍន៍នៃប្រទេសកម្ពុជា

### Peuplement du Cambodge






**ចប់បរិបូរណ៍**

# ដំណើរឆ្ពោះទៅទិសខាងត្បូងភាគ២បន្ត

**ដោយ : ថាច់វណ្ណា**

ក្រោយពេលព្រះបាទជ័យជេដ្ឋាទី២បានសោយទីវង្គត់នៅឆ្នាំគ.ស.១៦២៨, គំរប់៥ឆ្នាំរយៈពេលដែលដាយ-វៀតបានខ្ចីដីមូស្វាយនៃខេត្តអូកាប់ (Ba` Ria, Vung Tau) និងកោះក្របីនៃព្រៃនគរ ( Bên Nghe, Sai Gon) មិនបានសងមកខ្មែរវិញទេ ផ្ទុយទៅវិញ ដាយ-វៀតបានដណ្តើមសិទ្ធទាំងស្រុងនៅបណ្តាខេត្តព្រះសួគ៌ា (Thu Dau Mot ) បច្ចុប្បន្នជា ខេត្តបិនភឿក (Bình Phuc) ខេត្តរោងដំរី (Tây Ninh), ខេត្ត មរា ( Đong Nai) , ឧកញ៉ាឱញ,(Gia- Đinh)ចង្វាត្រពាំង,(Biên-Hoa) នៅភូមិភាគបូព៌ាទាំងស្រុង។

បន្ទាប់មក,ដាយ-វៀតបានពង្រឹងពាណិជ្ជកម្មជាមួយ និងជប៉ុន, យោងទៅតាមៈ National Archives of Japan។ មានសាររបស់ដាយ-វៀតផ្ញើឱ្យជប៉ុនក្នុងអំឡុងឆ្នាំ១៦២៨-១៦៣៤,

ក្នុងសាររបស់ស្តេចង្វៀនផ្ញើឱ្យជប៉ុន តូកូហ្កាវ៉ា (Tokugawa-Leyasu) បានបើកដែនសមុទ្រ និងកំពង់ផែទាំង៦នៅដាយ-វៀតឱ្យជប៉ុនចូលមកធ្វើជំនួញដើម្បីពង្រឹងសេដ្ឋកិច្ច។

នៅជប៉ុន,ស្តេចដាយ-វៀតក៏បានលើកកូនស្រីចិញ្ចឹមម្នាក់ឈ្មោះ ងុក-វ៉ា (Ngoc-Hoa) ឱ្យទៅឈ្មួញជប៉ុនឈ្មោះអារ៉ាគី-ស៊ូតារ៉ូ(Araki-Sutaru) នៅឆ្នាំ១៦១៩, ធ្វើជាភរិយា និងកិច្ចការ



កសាងសេដ្ឋកិច្ច, បន្ទាប់មក ឆ្នាំ១៦៣១ដាយ-វៀតក៏បានចាប់ផ្តើមធ្វើគ្រាប់រំសេវនៅ ស្រុកផាន-សា (Phan-Xa´) ខេត្តក្វាន-បីញ(Quang Bình) ដែលមេជាងជាបច្ចេកទេសចំនួន៦០នាក់, និង ៣០នាក់ផ្សេងទៀតជាមេជាងធ្វើកាំភ្លើងនៅខេត្តថ្វឹង-វ៉ា (Thuân-Hoa)។

យោងតាមសៀវភៅៈ L'Etat presente de L' Eglíse de la Chine ទំព័រទី១៤៧, បាននិយាយថាៈ ប្រទេសកម្ពុជាក៏បានស្រាវជ្រាវរកឃើញអ្នកបច្ចេកទេសធ្វើកាំភ្លើងម្នាក់គឺលោកអាចារ្យ ហ្សង់-ដឺ-ឡា-ក្រ័រ (Jean de la Croix) ជាជនជាតិព័រទុយហ្គាល់ (Portugues) ក្នុងអំឡុងឆ្នាំ ១៦៥៥-១៦៥៨, កម្ពុជាបានផ្តល់មុខងារដល់លោកអាចារ្យ ហ្សង់-ដឺ-ឡា-ក្រ័រ ជាមន្ត្រីម្នាក់នៃកម្ពុជា, ប៉ុន្តែត្រូវដាយ-វៀតចាប់ខ្លួនបាននៅឆ្នាំ១៦៥៨, រួចបញ្ជូនទៅស្រុកដាយ-វៀត, ដើម្បីផលិតកាំភ្លើងឱ្យដាយ-វៀតនៅក្នុងខេត្ត ថ្វឹង-វ៉ា (Thuân-Hoa)។

ឆ្នាំ១៦៥៨នេះ,ក៏ជាសម័យកាលមួយដែលមានភាពចលាចលវឹកវរជាខ្លាំង, ដោយបុត្រា២ព្រះអង្គនៃព្រះឧទ័យរាជាទី១ គឺអង្គសួរ និងអង្គនន់, បានរួមដៃដណ្តើមរាជ្យពីអង្គចន្ទទី២, អង្គសួរ និងអង្គនន់បានចូលទៅសុំឱវាទពីព្រះស្រីវរក្សត្រី, គឺៈ ង្វៀន ភុក ងុក វ៉ាន (Nguyên Phuc Ngoc Van ដែលជាអគ្គមហេសីនៃព្រះបាទជ័យជេដ្ឋាទី២, ព្រះស្រីវរក្សត្រីក៏បានបង្គប់ឱ្យទៅពឹងដាយ-វៀតលើកទ័ពមកជួយដណ្តើមរាជ្យ,អង្គសួរ និងអង្គនន់ក៏បានទៅពឹងស្តេចង្វៀន ភូក តឹន (Nguyn Phúc Tan: ត្រូវជាចៅនៃព្រះស្រីវរក្សត្រី, ស្តេច ង្វៀន ក៏បានយល់ព្រមលើកទ័ពចំនួន៣ពាន់នាក់ដឹកនាំដោយមេទ័ព ង្វៀន ភឿក អៀន (Nguyn Phuc Yen) ចូលមកក្នុងខេត្តអូកាប់(Bà Ria -Vung Tàu) នៃកម្ពុជាក្រោម។

រួចក៏បានធ្វើសង្គ្រាមនិងរាមាធិបតីទី១ គឺអង្គចន្ទទី២, ខណៈនេះ, ក៏ជាពេលដែលដាយ-វៀតចាប់បានលោកអាចារ្យ ហ្សង់-ដឺ-ឡា-ក្រ័រ (Jean de la Croix) ដែរ, សង្គ្រាមមិនបានមួយឆ្នាំក៏ចាប់បានអង្គចន្ទទី២ដាក់ទ្រុងដែកយកទៅប្រទេសដាយ-វៀតឃុំខ្លួនក្នុងខេត្ត ក្វាង-បីញ (Quang Bình) **តទៅទំព័រទី ៣១**







CENTURY PHARMACY & OPTICAL
937 Gorham St
ALL MAJOR INSURANCES ACCEPTED
Tel: 978-455-6554
យើងខ្ញុំសូមជូនពរមហាប្រសើរដល់លោកអ្នក
នាឱកាសចូលឆ្នាំមមែ ព.ស ២៥៥៩
យើងខ្ញុំមានផ្តល់សេវាបំរើការជូនឱសថដល់ទីលំនៅ ។
យើងខ្ញុំទទួលកាតម៉ាសហ៊ារ, និងកាតធានារ៉ាប់រងសុខភាពផ្សេងៗទៀត
សេវាបំរើការល្អ,អតិថិជនមានភាពជឿជាក់ ។
យកចិត្តទុកដាក់លើបញ្ហាផ្ទាល់ខ្លួននៃអតិថិជនរាល់រូប ។
វេចខ្ចប់ឱសថសមតាមបំណងនៃអតិថិជន ។
មានផលិតកម្មពិសេសរបស់អូធីស៊ីជារៀងរាល់ខែ ។
យើងខ្ញុំទទួលការផ្ញើថ្នាំតាមបទបញ្ជាជូនដល់អស់លោកអ្នក ។ ជាឱសថស្ថានមួយអាចផ្តល់ភាពជឿជាក់ដល់គ្រួសារអ្នក ។
CENTURY PHARMACY
យើងខ្ញុំនិយាយភាសាខ្មែរ ។
លេខទូរស័ព្ទ 978-455-6554
លេខហ្វាក់ 978-455-9476
937 Gorham St Lowell, MA, 01852

តមកពីទំព័រទី ២៩
## ដំណើរឆ្ពោះទៅទិសខាងត្បូង

ធ្វើទារុណកម្មរហូតដល់ឆ្នាំ១៦៥៩, ដាយ-វៀត បានឃើញសុខភាពរបស់ព្រះអង្គទ្រាំតទៅទៀតពុំបាន, ក៏បានដោះលែងចេញពីមន្ទីរឃុំឃាំង, ប៉ុន្តែមកដល់ពាក់កណ្តាលផ្លូវព្រះអង្គចន្ទទី២ក៏បានសោយទិវង្គត់ទៅ។ ឆ្នាំ១៦៥៩, ដាយ-វៀតក៏បានលើកអង្គសូរឡើងគ្រងរាជ្យទ្រង់នាមថា : បរមរាជាទី៩, នៅរាជធានីឧដុង្គ,

រីឯអង្គនន់លើកធ្វើជាអនុរាជ្យនៅក្រុងព្រៃនគរ, រួចក៏បានដាក់ប្រទេសកម្ពុជានៅក្រោមចំណុះប្រទេសដាយ-វៀតទៅវិញ។

ក្នុងខណះនេះ, ប្រទេសដាយ-វៀតក៏បានតាំងខ្លួនជាអ្នកមានគុណលើព្រះមហាក្សត្រ, ក៏បានបើកដៃឱ្យកងទ័ព និងប្រជារាស្ត្រដាយ-វៀត ដើរហើរដោយសេរីលើដែនដីកម្ពុជាក្រោម, ព្រោះហេតុតែដែនដីកម្ពុជាក្រោមសម្បូរណ៍ដោយធម្មជាតិ, វៀត-ណាម ធ្លាប់មានពាក្យដំណាលថា:( Miê`n Nam La`m Choi An Thât) មានន័យថា : (ដែនដីភាគខាងត្បូងធ្វើលេងៗបានផលញាំមែនទែន) ម្ល៉ោះហើយជនជាតិវៀត-ណាម ក៏បានចូលទៅភាគខាងត្បូងកាន់តែច្រើនឡើងៗ។

រហូតដល់ខែវិច្ឆិកា, ឆ្នាំ១៦៧២, ព្រះបរមរាជាទី៩ត្រូវធ្វើឃាតដោយស្រីជ័យជេដ្ឋា, ក្រោយបន្តមកទៀត រវាង២ឬ៣ឆ្នាំ និងមានការធ្វើឃាតដណ្តើមរាជ្យជាបន្តបន្ទាប់, តាំងពីឆ្នាំ១៦៧២-១៧៥៧, មានរយះពេលតែ៨៥ឆ្នាំប៉ុណ្ណោះ បានប្តូរផ្លាស់ស្តេចខ្មែរ២០លើក, មានស្តេចខ្លះទៅពឹងថៃឱ្យជួយ,ស្តេចម្ខាងទៀតទៅពឹងដាយ-វៀតឱ្យជួយក្នុងការធ្វើចម្បាំងដណ្តើមរាជបល្ល័ង្គ, ដាយ-វៀតចូលមកពីទិសខាងកើត, រីឯថៃចូលមកពីទិសខាងលិច។

ក្នុងសម័យនោះ, ប្រជារាស្ត្រខ្មែរពុំមានមេដឹកនាំណាពិតប្រាកដឡើយ, បណ្តោយឱ្យដាយ-វៀត និងថៃចូលលុកលុយតាមអំពើចិត្ត, នេះជាមូលហេតុនាំឱ្យបាត់បង់អធិបតេយ្យភាពមួយភាគធំនៅទិសខាងលិច និងមួយភាគធំនៅទិសអាគ្នេយ៍ គឺកម្ពុជាក្រោមផងដែរ។

ទោះបីជាយ៉ាងនោះក្តី, ព្រះរាជាគ្រប់ជំនាន់ពីសម័យនោះ មិនមានព្រះរាជាអង្គណាបានចុះព្រហស្តលេខាកាត់ទឹកដីនៃរាជាណាចក្រកម្ពុជាឱ្យទៅប្រទេសណាមួយឡើយ ៕







KhmerPost USA

IN PRINT. ONLINE
www.khmerpostusa.com

a free local newspaper reaching over 20,000 Cambodian readers in the Greater Lowell area every two weeks

Sample of our affordable pricing បញ្ជីតម្លៃពាណិជ្ជកម្មក្នុងតម្លៃសមរម្យ

| Page Size | Length x Width | 1 month 10% OFF |
|---|---|---|
| 1/2 page color | (6.5"x10") | $484 |
| 1/4 page color | (6.5"x5") | $264 |
| 1/8 Classify ad | (3.25"x5") | $100 |
| Business Card | | $50 |

Our 2015 Publishing Dates កាលវិភាគបោះពុម្ព

| | |
|---|---|
| July | 10th & 24th |
| August | 7th & 21st |
| June | 5th & 26th |

*all ad materials are due one week prior to publishing date.
រាល់គំរូពាណិជ្ជកម្មត្រូវបញ្ជូន១សប្តាហ៍មុនចូលរោងពុម្ព



Call or Visit our Sales Office
45 Merrimack Street. Suite 218A. Lowell, MA 01852
Tel: 978.677.7163. Cell: 978. 656.8141 Fax: 978.677.7092
Email: sobenpin@khmerpost.us or KhmerPostUSA@gmail.com
www.khmerpost.us | www.facebook.com/KhmerPostUSA


សុខភាពរបស់អ្នក
មិនអាចចាំបានទេ !
HEALTH CARE FOR ALL
តើថ្មីៗនេះ អ្នកបានទទួលសំបុត្រ ពី"ម៉ាស់ហែល"
ស្តីពីសុំការធានាព្យាបាលជម្ងឺសាជាថ្មីឬទេ ?
បើមាន អ្នកនៅមានតែប៉ុន្មានថ្ងៃប៉ុណ្ណោះទេ
សម្រាប់ដាក់ពាក្យសុំរក្សា"អេនស៊ូរិន"របស់អ្នក
សំខាន់ណាស់ ! ដែលអ្នកត្រូវតែធ្វើសកម្មភាព
ភ្លាមៗ ឱ្យបានមុនថ្ងៃ៣០ខែមិថុនានេះ
សួស្តី ! ខ្ញុំឈ្មោះ ហេណា មកពី
"សុខភាពសំរាប់ទាំងអស់គ្នា"
HelpLine
ធ្វើសកម្មភាពភ្លាមៗ ឱ្យបានមុនថ្ងៃ៣០ខែមិថុនានេះ
"សុខភាពសំរាប់ទាំងអស់គ្នា"
៨០០ ២៧២-៤២៣២
ឬ ទៅមើលនៅវេបសាយ www.hcfama.org
FOUNDATION
MASSACHUSETTS
BOSTON MEDICAL CENTER
HealthNet Plan
TUFTS Health Plan
FOUNDATION
Neighborhood
Health Plan
Your health. Our promise.